សៀវភៅណែនាំសម្រាប់ការបង្កើតពួកជំនុំ និងការបន្តពួកជំនុំឡើងវិញ

# ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់



ដោយប្រើប្រាស់តាម
គោលការណ៍ព្រះគម្ពីរ
ដែលគ្រមដណ្ដាប់លើ
គ្រប់វប្បធម៌ និង
សម័យកាលនានា

# ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់



# ផែនការព្រះ
# សម្រាប់
# ពួកជំនុំរបស់ទ្រង់

---

## សៀវភៅណែនាំ
## សម្រាប់ការបង្កើតពួកជំនុំ
## និងការផ្លាស់ប្រែរបស់ពួកជំនុំ

*ដោយប្រើប្រាស់តាមគោលការណ៍ព្រះគម្ពីរ*
*ដែលគ្រមដណ្តប់លើគ្រប់វប្បធម៌ និងសម័យកាលនានា*

ធីម ដាប់បែលយូ ប៊ុន
Tim W. Bunn

# ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់
## សៀវភៅណែនាំសម្រាប់ការបង្កើតពួកជំនុំ និងការផ្លាស់ប្រែរបស់ពួកជំនុំ

**បោះពុម្ពលើកទី ៤ ឆ្នាំ២០១៨**
រក្សាសិទ្ធិគ្រប់យ៉ាង © ២០០៥, ២០០៨, ២០១២, ២០១៨ ដោយ New Foundations International

បទគម្ពីរត្រូវបានដកស្រង់តាមព្រះគម្ពីរបកប្រែចាស់ លោកអ័ធើរ ហាម៉ុង ឆ្នាំ១៩៥៤
រក្សាសិទ្ធិ© ឆ្នាំ២០០១ ដោយ Crossway ការបោះពុម្ពផ្សាយដោយ Ministry of Good News Publisher
រក្សាសិទ្ធិគ្រប់យ៉ាង

ISBN: 978069217318

New Foundation International
http://www.newfoundationinternational.org/
សូមធ្វើទំនាក់ទំនងមកយើងខ្ញុំ ឬផ្ញើសំណូមពរតាមអាសយដ្ឋាន៖
newfoundationinternational@gmail.com

# មតិមួយចំនួនរបស់អ្នកដឹកនាំពួកជំនុំក្នុងជុំវិញពិភពលោក

"សៀវភៅនេះបានបើកភ្នែកខ្ញុំឲ្យបានមើលឃើញពីការពិតជាក់ស្តែងយ៉ាងដូចត់របស់ពួកជំនុំបច្ចុប្បន្នដែលដើរប្រាសចាកពីគំរូក្នុងព្រះគម្ពីរ។ ខ្ញុំបានរៀនដោយបើកឲ្យព្រះបន្ទូលនិយាយមកកាន់ខ្ញុំអំពីបញ្ហាផ្សេងនៃការបង្កើតពួកជំនុំ ក៏ដូចជាការចុះចូលបន្ថែមទៅនឹងអំណាច និងការដឹកនាំរបស់ព្រះបន្ទូលផងដែរ។ សៀវភៅនេះបានធ្វើជាអ្នកបើកប្រកពសម្រាប់ខ្ញុំ។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសអាល់ហ្សេរី**

"នេះគឺជាសៀវភៅនៃជីវិតផ្លាស់ប្រែសម្រាប់អ្នកដែលចង់ត្រឡប់ទៅកាន់ព្រះបន្ទូលព្រះ និងអនុវត្តតាម (ធ្វើតាម) ព្រះគម្ពីរសញ្ញាថ្មី ជាពិសេសនៅក្នុងកណ្ឌគម្ពីរ កិច្ចការ។ ដោយអនុវត្តតាមគោលការណ៍ទាំងនេះ យើងទទួលបានបទពិសោធន៍ក្នុងការផ្លាស់ប្រែឡើងវិញនៅក្នុងក្រុមគ្រួសារ និងពួកជំនុំនៅក្នុងប្រទេសហ្សំប៊ី ហើយក៏កំពុងតែរីកសុះសាយទៅប្រទេសមួយចំនួននៅក្បែរ។ បច្ចុប្បន្ននេះពួកជំនុំកំពុងតែធ្វើសកម្មភាពច្រើនដូចទៅនឹងពួកជំនុំមុនដំបូងក្នុងព្រះគម្ពីរកិច្ចការ។"

**គ្រូគង្វាល • ប្រទេសហ្សំប៊ី ទ្វីបអាហ្វ្រិក**

"ខ្ញុំអាចនិយាយបានថាសៀវភៅនេះគឺនៅជាប់នឹងព្រះគម្ពីរព្រះដែលមានទំនាក់ទំនងទៅនឹងពួកជំនុំ និងកិច្ចការងារបម្រើព្រះ។ បើសួរថា ហេតុអ្វី ឬក៏ដោយរបៀបណា? ខ្ញុំនិយាយថា "ព្រោះសៀវភៅនេះនាំអ្នកអានព្រះគម្ពីរដោយខ្លួនឯង ដើម្បីស្វែករកនូវវប្បធម៌ចម្រុះ និងគោលការណ៍ព្រះគម្ពីរដែលមិនចេះចប់ក្នុងការបង្កើតពួកជំនុំថ្មី។" សៀវភៅនេះក៏ជាឧបករណ៍មួយដែលព្រះអាចប្រើដើម្បីនឹងប្រទានឲ្យបងប្អូនរកឃើញនូវដំណើរការនៃការរីកលូតលាស់ និងពេញដោយអំណាចចេស្តារបស់ពួកជំនុំដែលព្រះទ្រង់សព្វព្រះទ័យឲ្យបងប្អូនប្រព្រឹត្តតាម"

**អ្នកបង្កើតពួកជំនុំ • ប្រទេសមីយ៉ាន់ម៉ា**

"សៀវភៅផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់ គឺបាននិងកំពុងត្រូវបានប្រើប្រាស់ក្នុងប្រទេសកម្ពុជា ដើម្បីពង្រឹង ហើយនិងបង្កើតពួកជំនុំ។ សៀវភៅនេះគឺជាឧបករណ៍មួយយ៉ាងមានឥទ្ធិពលដែលពោពេញទៅដោយគោលការណ៍នៃព្រះគម្ពីរជាច្រើនក៏បានតែងឡើងដោយព្រះបន្ទូលដ៏រស់នៅរបស់ព្រះដែលអាចយកទៅប្រើក្នុងជីវិតផ្ទាល់ខ្លួន ពួកជំនុំ និងបេសកកម្ម ជាពិសេសគឺដើម្បីបង្កើតពួកជំនុំថ្មីៗនៅទីកន្លែងណាដែលមិនមានទាល់តែសោះ។"

**ស្ថាបនិក បណ្ដាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា**

"ពួកជំនុំគឺជាកូនក្រមុំយ៉ាងស្រស់ស្អាតរបស់ព្រះគ្រីស្ទនៅក្នុងគ្រប់វប្បធម៌ទាំងអស់ ក៏ជាកន្លែងដែលព្រះយេស៊ូវទ្រង់បានផ្លាស់ប្រែរាស្ត្ររបស់ទ្រង់។ ហើយការហ្វឹកហ្វឺននេះគឺជាលំនាំតាមគោលការណ៍នៃព្រះគម្ពីរក្នុងការអនុវត្ត ដែលមកជាមួយការអនុវត្តផ្ទាល់។"

**បណ្ឌិត អាឡិន ករ នៅសាលាទេវសាស្ត្រ ហ្គោលឌិន ហ្គែត**

"សៀវភៅផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់ គឺជាការណែនាំមួយយ៉ាងអស្ចារ្យដែលអាចឲ្យយើងយកពួកជំនុំបច្ចុប្បន្នប្រៀបធៀបជាមួយព្រះគម្ពីរសញ្ញាថ្មី។ សៀវភៅនេះគ្មានភាពលំអៀង និងពឹងផ្អែកលើព្រះបន្ទូលព្រះ ១០០%។ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់សម្រាប់សៀវភៅនេះ ក្នុងការប្រើប្រាស់សម្រាប់សិក្សាផ្ទាល់ខ្លួន ក៏ដូចជាតាមពួកជំនុំផ្សេងៗ។ ខ្ញុំបានឃើញពីការអនុវត្តតាមមុនដំបូង ហើយក៏បានឃើញលទ្ធផលយ៉ាងអស្ចារ្យ។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសអាហ្វ្រិកខាងត្បូង**

"នៅក្នុងវគ្គសិក្សានេះ លោកជីម ប៊ុន បានសាងសង់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំតាមព្រះគម្ពីរគឺសម្រាប់ការចាប់ផ្តើមបង្កើតពួកជំនុំឲ្យមានសុខភាពល្អ និងការបង្កើតពួកជំនុំបន្ថែមទៀត។ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់អំពីវគ្គសិក្សានេះ គឺមិនត្រឹមតែសម្រាប់សិក្សា តែក៏ជាការអភិវឌ្ឍនូវយុទ្ធសាស្រ្តយ៉ាងរឹងមាំសម្រាប់អ្នកបង្កើតពួកជំនុំបច្ចុប្បន្ន។"

**បណ្ឌិត រូប៊ើត វ៉ាកូ • អ្នកប្រឹក្សាអំពីការបង្កើតពួកជំនុំអន្តរជាតិ**

"វាពិតជាអស្ចារ្យពីការដែលព្រះវិញ្ញាណនៃព្រះធ្វើការយ៉ាងពេញព្រះចេស្តាក្នុងការបង្កើតពួកជំនុំរបស់ទ្រង់ឡើងវិញបន្ទាប់ពីការប្រើប្រាស់សៀវភៅនេះ។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសប៊ូតង់**

"១៥ឆ្នាំចុងក្រោយនេះ ខ្ញុំបានសិក្សា ហើយប្រព្រឹត្តតាមទស្សនៈនៃព្រះគម្ពីរក្នុងជីវិតខ្ញុំ និងការងារបម្រើរបស់ខ្ញុំ។ នៅវេលាដែលខ្ញុំបានប្រើប្រាស់សៀវភៅណែនាំនេះក្នុងការងារបម្រើរបស់ខ្ញុំ ខ្ញុំបានប្រែក្លាយពីអ្នកសិក្សាព្រះគម្ពីរ ទៅជាអ្នកបង្កើតពួកជំនុំដែលតាមព្រះគម្ពីរ។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសឥណ្ឌា**

"នៅពេលបញ្ចប់ការសិក្សាសៀវភៅនេះ អ្នកនឹងមានមូលដ្ឋានព្រះគម្ពីរដោយខ្លួនឯង ដែលជាយុទ្ធសាស្ត្រនៃការបង្កើតពួកជំនុំ។ គោលការណ៍នៃការហ្វឹកហ្វឺន ត្រូវបានប្រើប្រាស់ដើម្បីចង្អុលបង្ហាញថា សៀវភៅណែនាំនេះគឺសាមញ្ញណាស់។ សំណួរនិមួយៗធ្វើឲ្យអ្នកសិក្សាចាំបាច់ពឹងពាក់លើព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឆ្លើយតាមសេចក្តីពិតចេញពីព្រះគម្ពីរ។ អ្វីដែលសំខាន់អំពីសៀវភៅនេះ គឺវាមានលក្ខណៈជាការអនុវត្តផ្ទាល់។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសនេប៉ាល់**

"ព្រះអម្ចាស់គឺប្រើប្រាស់សៀវភៅណែនាំនេះ ដើម្បីនឹងធ្វើការផ្លាស់ប្រែយ៉ាងខ្លាំងទៅលើពួកជំនុំក្នុងស្រុក នៅប្រទេសវៀតណាម។ វាមានភាពជាក់ច្បាស់ ពេញលេញ និងមានប្រយោជន៍ណាស់ក្នុងការហ្វឹកហ្វឺនពួកអ្នកបង្កើតពួកជំនុំ ឲ្យគេបង្កើតពួកជំនុំថ្មីៗ ក៏ដូចជាពង្រឹងពួកជំនុំដែលនៅមាននៅឡើយ។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសវៀតណាម**

"ការសិក្សានេះគឺបានប្រែក្លាយជាចំនុចមួយក្នុងការតម្រង់ទិសនៅក្នុងការងារបម្រើព្រះរបស់ខ្ញុំ។ ហើយបន្ទាប់ពីបានដឹង និងយល់អំពីការដែលព្រះទ្រង់ចង់ឲ្យខ្ញុំធ្វើក្នុងនាមជាអ្នកបង្កើតពួកជំនុំម្នាក់ ឥឡូវនេះខ្ញុំដើរតាមផែការរបស់ព្រះ។ ព្រះទ្រង់កំពុងសង់ពួកជំនុំរបស់ទ្រង់ឡើងសព្វថ្ងៃ ចាប់ពីស្រុកទៅដល់រដ្ឋ ហើយចាប់ពីរដ្ឋទៅដល់បណ្តាប្រទេសនានា។ សៀវភៅណែនាំនេះអាចជួយអ្នកបាន ក្នុងការស្វែងរកឲ្យបានឃើញនូវផែនការនេះ។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសបង់ក្លាដេស**

"អស្ចារ្យណាស់ សៀវភៅផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់នេះ ពិតជាឧបករណ៍តែមួយគត់ដែលមានមូលដ្ឋានគ្រឹះ ដោយពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះ ក៏ជាឧបករណ៍មួយយ៉ាងអស្ចារ្យដែលក្រៅពីព្រះគម្ពីរ។ សៀវភៅនេះបានកាត់ផ្តាច់នូវអស់មនុស្សទាំងអស់ដែលបានបូកបន្ថែមជាង ២០០០ឆ្នាំមកនេះ ហើយក៏បានធ្វើដំណើរត្រឡប់ទៅគោលការណ៍ដែលគ្មានពេលកំណត់នៃពួកជំនុំក្នុងព្រះគម្ពីរសញ្ញាថ្មី។ ព្រះទ្រង់បានធ្វើការក្នុងជីវិតរបស់ខ្ញុំតាមរយៈសៀវភៅនេះ ហើយខ្ញុំក៏បានឃើញថាព្រះបានធ្វើការក្នុងជីវិតមនុស្សជាច្រើនផងដែរ ក្នុងប្រទេសប៊ូតង់។"

**អ្នកបង្កើតពួកជំនុំ • ប្រទេសបង់ក្លាដេស**

"ខ្ញុំពិតជាទទួលបាននូវអភ័យឯកសិទ្ធិមួយក្នុងការអាន និងសិក្សាសៀវភៅ ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់ ហើយបានធ្វើការជាមួយនឹងក្រុមដែលមានការលះបង់ ដែលដឹកនាំដោយលោកគ្រូ ជីម ប៊ុន។ វគ្គសិក្សានេះជាមានសារៈប្រយោជន៍ខ្លាំង

ណាស់ទាំងខាងវិញ្ញាណ និងខាងការប្រព្រឹត្ត។ ខ្ញុំចង់ឲ្យបេសកជន និងសិស្សទាំងឡាយរៀនសៀវភៅនេះសម្រាប់ជាវគ្គសិក្សា សាលាចុងក្រោយ ដែលពួកគេនឹងបានដឹងអំពីគោលការណ៍នៃព្រះគម្ពីរដែលបានប្រទានមក សម្រាប់ការបង្កើតពួកជំនុំ និងធ្វើការចេញទៅ ហើយវិវត្តន៍ទៅជាអ្នកបង្កើតពួកជំនុំ និងគ្រូគង្វាលដែលមិនអាចបញ្ឈប់បាន។"

**លោកគ្រូគង្វាល ចូច អ៊ែតទី មកពី សាលាបាទីស្ទ • ប្រទេសលីបង់**

"ព្រះដ៏ជាព្រះបានប្រើប្រាស់សៀវភៅណែនាំនេះ ដើម្បីផ្លាស់ប្រែជីវិតរបស់ខ្ញុំ ក៏ដូចជាបានប្រទានដល់មនុស្សជាច្រើននៅជុំវិញខ្ញុំ នូវឫសយ៉ាងជ្រៅក្នុងបទគម្ពីរ។ ពួកជំនុំរបស់យើងគឺធ្វើការប្រព្រឹត្តកាន់តែដូចទៅនឹងអ្នកដែលបទគម្ពីរបានចែងមក ហើយមនុស្សជាបានពរក៏ដោយសារការនោះ។"

**គ្រូគង្វាល និងអ្នកជំនួញ • រដ្ឋការ៉ូឡាញណាខាងជើង**

"ដូចទៅអ្នកចំណងជើងដែលសៀវភៅណែនាំនេះបានសរសេរអំពី ការប្រើប្រាស់គោលការណ៍នៃព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះដែលមិនមានពេលវេលាបញ្ចប់ ដែលប្រើទៅក្នុងគ្រប់ទាំងវប្បធម៌ សម្រាប់ការបង្កើតពួកជំនុំ និងការពង្រឹងពួកជំនុំដែលមានរួចហើយ។ នៅក្នុងសៀវភៅនេះ មិនមានការលុបបំបាត់ ការប្រើបន្លំទាក់ទាញ ការលើកឡើងនូវប្រយោគរបស់បុគ្គលល្បីៗ ឬការអ្វីដែលនឹងត្រូវបាត់បង់ ហើយបំភ្លេចចោលក្នុងរយៈពេល ១០ឆ្នាំខាងមុខនោះទេ ពោលគឺត្រឹមត្រូវតាមលំដាប់លំដោយនៃព្រះបន្ទូលព្រះពីមេរៀនមួយទៅមេរៀនមួយទៀត ដែលបានប្រាប់អំពីការដែលពួកជំនុំជារូបកាយរបស់ព្រះគ្រីស្ទគួរធ្វើ ហើយអំពីការដែលមនុស្សម្នាក់ៗជាអ្នកជឿគួរតែប្រើប្រាស់ ក្នុងជីវិតរស់នៅរបស់ខ្លួនក្នុងក្រុមគ្រួសារនៃព្រះ។"

**គ្រូគង្វាល • សហរដ្ឋអាមេរិក**

# មាតិកាសង្ខេប


**ជំពូកទី១ ៖ ការប្រឈមមុខរបស់យើង - ការបែរទៅរកព្រះបន្ទូល** ទំព័រ.១៦

*ដើម្បីបែរទៅរក ហើយនឹងសាងសង់នូវភាពគ្រប់គ្រាន់ និងអំណាចនៃព្រះបន្ទូលព្រះ*

**ជំពូកទី២ ៖ ការប្រឈមមុខរបស់យើង - ការមើលឃើញពីបំណង និងផែនការរបស់ព្រះ** ទំព័រ.៣២

*ដើម្បីមើលឲ្យបានឃើញពីគោលបំណងនៃពួកជំនុំរបស់ទ្រង់ គឺការបំពេញផែនដីឡើងពេញ ដោយចំណេះដឹងជាសិរីល្អរបស់ទ្រង់*

**ជំពូកទី៣ ៖ ការប្រឈមមុខរបស់យើង - ការស្វែងយល់ពីផែនការរបស់ព្រះ** ទំព័រ.៤៤

*ដើម្បីឲ្យបានយល់ពីផែនការរបស់ព្រះ សម្រាប់ការពង្រឹងពួកជំនុំដែលមានរួចហើយ និងបង្កើតពួកជំនុំថ្មីៗ នៅទីកន្លែងដែលមិនមានសោះ*

**ជំពូកទី៤ ៖ ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍអ្នកដឹកនាំដ៏ស្មោះត្រង់** ទំព័រ.៧៥

*ដើម្បីអភិវឌ្ឍអ្នកដឹកនាំដ៏ស្មោះត្រង់ ឲ្យបានដូចទៅនឹងពួកសិស្សមុនដំបូង ដែលបានធ្វើឲ្យផែនដីក្រឡាបចាក់សម្រាប់ព្រះគ្រីស្ទ*

**ជំពូកទី៥ ៖ ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍពួកជំនុំរឹងមាំ** ទំព័រ.៩៧

*ដើម្បីអភិវឌ្ឍពួកជំនុំដែលរឹងមាំ ដោយការដើរតាមសាវកប៉ុល ជាអ្នកបង្កើតពួកជំនុំគំរូ ដែលគាត់បានធ្វើតាមព្រះគ្រីស្ទ*

**ជំពូកទី៦ ៖ ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍពួកជំនុំឲ្យមានសណ្តាប់ធ្នាប់** ទំព័រ.១៣៣

*ដើម្បីអភិវឌ្ឍពួកជំនុំឲ្យបានតាមលំដាប់ ដោយមានការរៀបចំដាក់តាមតួនាទីផ្សេងៗ របស់បុគ្គលិកម្នាក់ៗ និងក្រុមគ្រួសារនិមួយៗទៅតាមលំដាប់លំដោយ*

**ជំពូកទី៧ ៖ ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍការបង្កើតពួកជំនុំ និង យុទ្ធសាស្ត្រសម្រាប់ការបន្តជាថ្មី** ទំព័រ.១៧៩

*ដើម្បីអភិវឌ្ឍ និងយកមកអនុវត្តក្នុងការបង្កើតពួកជំនុំរបស់អ្នកផ្ទាល់ រួមទាំងយុទ្ធសាស្ត្រ សម្រាប់ការបន្តឡើងវិញ ដោយបានសង់ឡើងដោយព្រះបន្ទូលរបស់ព្រះ*

**ជំនួយបន្ថែម និងធនធានផ្សេងៗ** ទំព័រ.១៨៩

*ដើម្បីអភិវឌ្ឍការស្វែងយល់បន្ថែមទៀត នៅក្នុងគោលការណ៍ព្រះគម្ពីរយ៉ាងច្រើនសម្បូរបែប ដែលធ្វើឲ្យការបង្កើតពួកជំនុំឲ្យកាន់តែរឹងមាំ និងការបន្តឡើងវិញនូវពួកជំនុំដែលកើតរួចហើយ*

# សេចក្ដីណែនាំបឋម

ប្រសិនបើអ្នកជឿថា ព្រះកំពុងតែដឹកនាំអ្នក ដើម្បីធ្វើកិច្ចការនេះរហូតដល់បញ្ចប់សៀវភៅ ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់នេះ សូមអ្នកពិនិត្យមើលការណែនាំមួយចំនួននៅខាងក្រោម យើងខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកធ្វើកិច្ចការនេះ ដោយខ្លួនឯង ឬជាមួយនឹងដៃគូរតាមដែលអាចធ្វើទៅបាន។ បន្ទាប់ពីអ្នកបានបញ្ចប់រាល់ការណែនាំខាងក្រោម ឬការណែនាំមុនធ្វើកិច្ចការ ពួកយើងរំពឹងថានឹងជួបជាមួយអ្នកដោយផ្ទាល់ ហើយនឹងបំពេញមេរៀនទាំងនេះ ជាមួយនឹងការអនុវត្តផ្ទាល់ខ្លួនជាមួយគ្នា។ ប្រសិនបើមានសំណួរ លោកអ្នកអាចទំនាក់ទំនងមកយើងបាន តាមរយៈ **newfoundationsinternational@gmail.com**




ការអាន　　　　ការសរសេរ

សម្រាប់ **ការពិភាក្សា និងការអនុវត្ត** ហើយនិង **មេរៀនផ្សេងទៀត** នឹងត្រូវបានបំពេញនៅក្នុងអំឡុងពេលដែលយើងទាំងអស់គ្នាជួបប្រជុំដោយផ្ទាល់។ នៅពេលអ្នកបំពេញចប់ ការអានអំពី**ការសង្កេត** ផ្នែកនៃ**ការជញ្ជឹងគិត** និងការបំពេញចន្លោះ សូមអ្នកសរសេរកាលបរិច្ឆេទនៅកន្លែងដែលមានបន្ទាត់ នៅខាងដើមនៃមេរៀននៅទំព័រ vii-xii(8-11)។ ចន្លោះនៃ **ការពិភាក្សា** អ្នកអាចធ្វើកិច្ចបំពេញបាន ប្រសិនបើអ្នកមានគ្នា ឬក្រុមតូចដើម្បីធ្វើជាមួយអ្នក។ (**ចំណាំ៖** សូមមើលជំនួយបន្ថែមពី **<u>របៀបនៃការសិក្សាព្រះគម្ពីរ</u>** ក្នុងទំព័រ 192-194)។

សូមឲ្យយើងដឹងនៅពេលដែលអ្នកបានបំពេញការណែនាំខាងលើរួចរាល់ ហើយយើងនឹងធ្វើការរៀបចំក្នុងការជួបអ្នកមុខទល់មុខ។ យើងខ្ញុំសូមអធិស្ឋានសម្រាប់អ្នក ក្នុងការដែលលោកអ្នករង់ចាំឱកាសសម្រាប់ការចាប់ផ្តើមថ្មីនៃអំណាចចេស្តាសិរីភាព និងអំណរក្នុងការបម្រើព្រះសង្គ្រោះរបស់យើងរាល់គ្នា។

# កាលវិភាគនៃការបណ្តុះបណ្តាលៈ ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់

| **ការជួបជុំ** | **ការបរិយាយ** | **កិច្ចសិក្សា (ក្រុមតូច)** | **កិច្ចការ** | **រយៈពេល** |
|---|---|---|---|---|
| *លើកទី ១* | *ការណែនាំ* | *សេចក្តីផ្តើម/ទិដ្ឋភាពទូទៅ/ទស្សនៈ* | *ជំពូកទី ១ - ៣* | *២ ថ្ងៃ* |
| *លើកទី ២* | *ការតាមដាន* | *ជំពូកទី ១ - ៣* | *ជំពូកទី ៤ - ៥* | *៣ ថ្ងៃ* |
| *លើកទី ៣* | *ការតាមដាន* | *ជំពូកទី ៤ - ៥* | *ជំពូកទី ៦* | *៤ ថ្ងៃ* |
| *លើកទី ៤* | *ការចាប់ផ្តើម* | *ជំពូកទី ៦* | *"ចូរទៅ"* | *៤ ថ្ងៃ* |

| **ការជួបជុំ** | **ការបរិយាយ** | **កិច្ចសិក្សា (ក្រុមតូច)** | **កិច្ចការ** | **រយៈពេល** |
|---|---|---|---|---|
| *លើកទី ១* | *ការណែនាំ* | *សេចក្តីផ្តើម/ទិដ្ឋភាពទូទៅ/ទស្សនៈ* | *ជំពូកទី ១ - ៤* | *២ ថ្ងៃ* |
| *លើកទី ២* | *ការតាមដាន* | *ជំពូកទី ១ - ៤* | *ជំពូកទី ៥ - ៦* | *៤ ថ្ងៃ* |
| *លើកទី ៣* | *ការចាប់ផ្តើម* | *ជំពូកទី ៥ - ៧* | *"ចូរទៅ"* | *៥ ថ្ងៃ* |

| **ការជួបជុំ** | **ការបរិយាយ** | **កិច្ចសិក្សា (ក្រុមតូច)** | **កិច្ចការ** | **រយៈពេល** |
|---|---|---|---|---|
| *លើកទី ១* | *ការណែនាំ* | *ទិដ្ឋភាពទូទៅ & ជំពូកទី ១ - ៣* | *ជំពូកទី ៤ - ៦* | *៥ ថ្ងៃ* |
| *លើកទី ២* | *ការតាមដាន & ការចាប់ផ្តើម* | *ជំពូកទី ៤ - ៧* | *"ចូរទៅ"* | *៥ ថ្ងៃ* |

| **ការជួបជុំ** | **ការបរិយាយ** | **កិច្ចសិក្សា (ក្រុមតូច)** | **កិច្ចការ** | **រយៈពេល** |
|---|---|---|---|---|
| *លើកទី ១* | *ការរៀបចំ & ការចាប់ផ្តើម* | *ជំពូកទី ១ - ៧* | *"ចូរទៅ"* | *២៨-៣០ ថ្ងៃ* |

# មាតិកាលម្អិត និងកំណត់ត្រា

សូមអ្នកដាក់កាលបរិច្ឆេទដែលអ្នកបានបំពេញរួចនូវគម្រោង ឬមេរៀន នៅលើបន្ទាត់ខាងដើមមេរៀន។


**ជំពូកទី ១ ៖** **ទំព័រ**

**ការប្រឈមមុខរបស់យើង - ការបែរទៅរកព្រះបន្ទូល** 16

*កាលបរិច្ឆេទនៃការបញ្ចប់*

___________ **គម្រោង A "អេ"**: ការកំណត់សម្គាល់អ្នកបន្ថែមល្បឿន និងអ្នករារាំង 25

**ជំពូកទី ២ ៖**

**ការប្រឈមមុខរបស់យើង - ការមើលឃើញពីបំណង និងផែនការរបស់ព្រះ** 32

___________ **គម្រោង B "ប៊ី"**: ការបើកសម្ដែងពីបំណងព្រះហឫទ័យ និងផែនការរបស់ព្រះ 33

**ជំពូកទី ៣ ៖**

**ការប្រឈមមុខរបស់យើង - ការស្វែងយល់ពីផែនការរបស់ព្រះ** 44

___________ **គម្រោង C "ស៊ី"**: ការត្រិះរិះពីកត្តាជាចំខាត និងកត្តាមិនជាចខាត 45

___________ **មេរៀនទី ១** : ការរីកសុះសាយនៃពួកជំនុំ ៖ ក្រុងយេរូសាឡិម 48

___________ **មេរៀនទី ២** : ការរីកសុះសាយនៃពួកជំនុំ ៖ ស្រុកយូដា និងស្រុកសាម៉ារី 51

___________ **មេរៀនទី ៣** : ការរីកសុះសាយនៃពួកជំនុំ ៖ ក្រុងអាន់ទីយ៉ូក 53

___________ **មេរៀនទី ៤** : ការរីកសុះសាយនៃពួកជំនុំ ៖ ក្រុងអាស៊ីកណ្ដាល 56

___________ **មេរៀនទី ៥** : ការរីកសុះសាយនៃពួកជំនុំ ៖ តំបន់អ៊ែហ្សង់ 59

___________ **មេរៀនទី ៦** : ការរីកសុះសាយនៃពួកជំនុំ ៖ ចក្រភពរ៉ូម 62

___________ **មេរៀនទី ៧** : ការរីកសុះសាយនៃពួកជំនុំ ៖ ក្រុងយេរូសាឡិមរហូតដល់ចុងបំផុតផែនដី 65

___________ **មេរៀនទី ៨** : យុទ្ធសាស្ត្របេសកកម្មរបស់សាវកប៉ុល 66

___________ **មេរៀនទី ៩** : គំរូពួកជំនុំនៃទីក្រុងអាន់ទីយ៉ូក 68

___________ **គម្រោង D "ឌី"**: ការអភិវឌ្ឍយុទ្ធសាស្ត្ររបស់ខ្លួនអ្នកផ្ទាល់ 72

**ជំពូកទី ៤ ៖**

**ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍអ្នកដឹកនាំដ៏ស្មោះត្រង់នៅក្នុងពួកជំនុំ** 75

___________ **មេរៀនទី ១០** : តួនាទីសំខាន់ៗរបស់ពួកសាវក នៅក្នុងពួកជំនុំមុនដំបូង 77

___________ **មេរៀនទី ១១** : ព្រះត្រាស់ហៅអ្នកដឹកនាំដែលសំខាន់ 86

___________ **គម្រោង E "អ៊ី"**: ភាពផ្ទុយគ្នារវាងការហ្វឹកហ្វឺនអ្នកដឹកនាំបច្ចុប្បន្ន និងពួកជំនុំមុនដំបូង 94

**ជំពូកទី ៥ ៖**

**ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍពួកជំនុំរឹងមាំ** 97

___________ **មេរៀនទី ១២** : ការចំរើនកំលាំង ឬការតាំងមាំមួនដល់ពួកជំនុំ ៖ សំបុត្រប៉ុល 102

__________ **មេរៀនទី ១៣** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង • កាឡាទី 104

__________ **មេរៀនទី ១៤** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង • ថែស្សាឡូនីច ទី១ ទី២ 106

__________ **មេរៀនទី ១៥** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង • កូរិនថូស ទី១ 108

__________ **មេរៀនទី ១៦** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង • កូរិនថូស ទី២ 110

__________ **មេរៀនទី ១៧** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង • រ៉ូម 112

__________ **មេរៀនទី ១៨** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលនៅកណ្តាល ឬបន្ទាប់ • អេភេសូ 114

__________ **មេរៀនទី ១៩** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលនៅកណ្តាល ឬបន្ទាប់ • ភីលីព 116

__________ **មេរៀនទី ២០** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលនៅកណ្តាល ឬបន្ទាប់ • កូល៉ុស 118

__________ **មេរៀនទី ២១** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលនៅកណ្តាល ឬបន្ទាប់ • ភីលីម៉ូន 120

__________ **មេរៀនទី ២២** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលចុងក្រោយ • ធីម៉ូថេ ទី១ 122

__________ **មេរៀនទី ២៣** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលចុងក្រោយ • ទីតុស 124

__________ **មេរៀនទី ២៤** : ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលចុងក្រោយ • ធីម៉ូថេ ទី២ 126

__________ **គម្រោង F "ហ្វ៊ែ"**: របៀបនៃការបង្កើតពួកជំនុំឡើងឲ្យបានពេញលេញ 128

__________ **មេរៀនទី ២៥** : ការតាំងពួកជំនុំមាំមួនដែលបានកំណត់ក្នុងព្រះគម្ពីរ 129

__________ **គម្រោង G "ជី"**: ការបង្កើតពួកជំនុំតាមសញ្ញាថ្មី 131

**ជំពូកទី ៦ ៖**

**ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍពួកជំនុំឲ្យមានសណ្តាប់ធ្នាប់** 133

__________ **មេរៀនទី ២៦** : របៀបរៀបរយនៃក្រុមគ្រួសារនៅក្នុងផ្ទះ 137

__________ **មេរៀនទី ២៧**: ជីវិតរបស់អ្នក <u>នៅក្នុង</u> ព្រះគ្រីស្ទ 139

__________ **មេរៀនទី ២៨**: ជីវិតរបស់អ្នក <u>ជាមួយ</u> ព្រះគ្រីស្ទ 142

__________ **មេរៀនទី ២៩**: តួនាទីនៃអាពាហ៍ពិពាហ៍ 145

__________ **មេរៀនទី ៣០**: តួនាទីរបស់ ស្វាមី "ប្តី" 147

__________ **មេរៀនទី ៣១**: តួនាទីរបស់ ភរិយា "ប្រពន្ធ" 149

__________ **មេរៀនទី ៣២**: តួនាទីរបស់ ឪពុកម្តាយ 151

__________ **មេរៀនទី ៣៣**: តួនាទីរបស់ កូនៗ 153

__________ **គម្រោង H "ហេច"**: ការកំណត់គ្រួសារទៅតាមលំដាប់លំដោយ 155

__________ **មេរៀនទី ៣៤**: តួនាទីរបស់ ពួកអ្នកបម្រើកិច្ចការងារនៃដំណឹងល្អ 157

__________ **មេរៀនទី ៣៥**: តួនាទីរបស់ គ្រូគង្វាល/ពួកចាស់ទុំ/អ្នកត្រួតត្រា 159

__________ **មេរៀនទី ៣៦**: តួនាទីរបស់ ពួកអ្នកជំនួយ 161

__________ **មេរៀនទី ៣៧**: តួនាទីរបស់ បុរស និងស្ត្រី 163

____________ **មេរៀនទី ៣៨:** តួនាទីរបស់ ពួកបុរសវ័យចំណាស់ៗ 165
____________ **មេរៀនទី ៣៩:** តួនាទីរបស់ ពួកស្ត្រីវ័យចំណាស់ៗ 167
____________ **មេរៀនទី ៤០:** តួនាទីរបស់ ពួកបុរសវ័យក្មេងៗ 169
____________ **មេរៀនទី ៤១:** តួនាទីរបស់ ពួកស្ត្រីវ័យក្មេងៗ 171
____________ **មេរៀនទី ៤២:** តួនាទីរបស់ ស្ត្រីមេម៉ាយ 173
____________ **គម្រោង I "អាយ":** ការរៀបចំពួកជំនុំឲ្យមានរបៀបរៀបរយ 175

**ជំពូកទី ៧ ៖**
**ការប្រឈមមុខរបស់យើង - ការអភិវឌ្ឍការបង្កើតពួកជំនុំ និង យុទ្ធសាស្ត្រសម្រាប់ការបន្តជាថ្មី** 179
____________ **គម្រោង J "ជេ":** រចនាការបង្កើតពួកជំនុំដោយខ្លួនអ្នកផ្ទាល់ និងយុទ្ធសាស្ត្រ សម្រាប់ការបន្តជាថ្មី 180
____________ **គម្រោង K "ខេ":** យុទ្ធសាស្ត្រក្នុងបង្កើតពួកជំនុំ និងបន្តឡើងវិញនៃពួកជំនុំក្នុងរយៈពេល ១០ឆ្នាំ 185

**ជំនួយបន្ថែម និងធនធានផ្សេងៗ** 189
____________ វិញ្ញាបនបត្របញ្ចប់ការសិក្សា 188
____________ ដំណើរបេសកកម្មរបស់ប៉ុល 190
____________ ពិធីលៀងព្រះអម្ចាស់ 195
____________ ពិធីបុណ្យជ្រមុជទឹក 197
____________ ការដោះស្រាយជម្លោះ 199
____________ ការផ្តល់ឲ្យ និងបញ្ហាប្រាក់កាក់ 202
____________ ការបម្រើគ្នាទៅវិញទៅមក (សមាជិកភាពពួកជំនុំ) 204
____________ ទំនាក់ទំនងជាមួយនឹងលោកិយ និងរដ្ឋអំណាច 206
____________ ការស្រឡាញ់ភេទដូចគ្នា និងការរៀបការភេទដូចគ្នា 208
____________ ការវាយតម្លៃអំពីកិច្ចការបម្រើរបស់ពួកសាវក 210
____________ ការរៀបរាប់តាមព្រះគម្ពីរ អំពីកិច្ចការងារបម្រើរបស់អ្នកបង្កើតពួកជំនុំ 212
____________ ការផ្គត់ផ្គង់ជំនួយសម្រាប់អ្នកបង្កើតពួកជំនុំ 216
____________ ការវាយតម្លៃទៅលើលក្ខណៈសម្បត្តិសម្រាប់ ពួកអ្នកគង្វាល/ពួកចាស់ទុំ/អ្នកត្រួតត្រា 219
____________ ការវាយតម្លៃទៅលើលក្ខណៈសម្បត្តិសម្រាប់ អ្នកជំនួយ 222

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបានធ្វើការអភិវឌ្ឍសៀវភៅណែនាំអំពីការបង្កើតពួកជំនុំនេះ សម្រាប់ប្រើប្រាស់ដើម្បីថ្វាយសិរីល្អដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះដល់យើងរាល់គ្នា! ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងក្រៃលែងទៅដល់អ្នកដឹកនាំពួកជំនុំជាច្រើន ដែលបានពេញដោយព្រះពរពីការបោះពុម្ព និងការកែសម្រួលកន្លងមក ក៏ដូចជាការបកប្រែសៀវភៅណែនាំនេះជាច្រើនភាសា ដែលត្រូវបាន និងកំពុងប្រើប្រាស់ពាសពេញពិភពលោក។ ខ្ញុំសូមអំណរគុណចំពោះលោកស្ទើរម៉ាន ជ្រាយវើរ លោកជារី ម៉ានាហាន លោករ៉េឌី ម៉ាថាយ និងលោកត្រា ង៉ក់ បេ ជាបងប្អូនដែលបានចូលរួមសហការជាមួយគ្នា ហើយបានធ្វើឲ្យសៀវភៅនេះអាចចេញជារូបរាងឡើងតាមរយៈបញ្ញា ការលើកទឹកចិត្ត និងភាពជាដៃគូរបស់បងប្អូនក្នុងដំណឹងល្អ។

ខ្ញុំបានទទួលការប៉ះពាល់អស់រយៈពេលជាច្រើនឆ្នាំ ពីការងារបម្រើព្រះតាមរយៈលោករ៉ូឡែន អាលេន ជាអ្នកសំណប់របស់ព្រះ ដែលបានសរសេរសៀវភៅជាច្រើនអំពី បេសកកម្មបម្រើព្រះ មានដូចជា "គោលការណ៍បេសកកម្មរបស់សាវកប៉ុល ឬក៏យើងទាំងអស់គ្នា?" (បានបោះពុម្ពច្បាប់ដើមនៅទីក្រុងឡុង ដោយលោករ៉ូប៊ើត ស្កត ឆ្នាំ១៩១២)។ ប្រាកដណាស់ ខ្ញុំពិតជាមិនមានចេតនាណាមួយក្នុងការប្រមូលយកនូវសម្ភារៈរបស់អ្នកផ្សេងៗនោះទេ ថែមទាំងមិនមានបំណងណាមួយក្នុងទាញចេញ ឬកែពីអ្នកនិពន្ធដើម ឬក៏យកកេរ៏ឈ្មោះ ឬប្រយោជន៍ពីសម្ភារៈណាមួយនោះទេ។

ចំណូលដែលទទួលបានពីសៀវភៅណែនាំនេះ នឹងមិនត្រូវបានប្រើប្រាស់សម្រាប់ប្រយោជន៍បុគ្គល ឬអ្នកនិពន្ធឡើយ។ ពោលរាល់ចំណូលដែលទទួលបានទាំងអស់នឹងត្រូវបានប្រើប្រាស់ ដើម្បីធ្វើការផ្ដល់សម្រាប់ការបកប្រែជាភាសាផ្សេងៗជាច្រើនទៀតនៅលើសកលលោក ដើម្បីថ្វាយសិរីល្អដល់ព្រះអម្ចាស់នៃយើងរាល់គ្នា!

ពីខ្ញុំ ធីម ប៊ុន Tim Bunn

# បុព្វកថា

សៀវភៅនេះមិនដូចទៅនឹងសៀវភៅធម្មតាមួយចំនួន ឬសៀវភៅសម្រាប់សិក្សាព្រះគម្ពីរដែលអ្នកមាននោះទេ! សៀវភៅនេះនឹងដឹកនាំអស់អ្នកណាដែលសម្រេចចិត្តអនុញ្ញាតឲ្យព្រះគម្ពីរ មានបន្ទូលទៅក្នុងដួងចិត្តរបស់គេ ហើយក៏ចាប់ផ្ដើមធ្វើការផ្លាស់ប្រែមួយដែលមិនធ្លាប់មានពីមុនមក។

ខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួមក្នុងបេសកកម្មនេះជាមួយលោកជីម ប៊ុន ក្នុងឆ្នាំ២០០៧។ យើងមានការប្ដេជ្ញាចិត្តតែមួយគត់គឺ ត្រូវធ្វើការតាមរយៈមេរៀនទាំងអស់មុនដែលក្រុមរបស់យើងត្រូវចាកចេញ។ ជាច្រើនយប់ ដែលខ្ញុំបានចំណាយពេលវេលាទាំងហូញើស ស្វែងរកសំណួរផ្សេងៗជាច្រើនដែលមានក្នុងបទគម្ពីរ ហើយខ្ញុំក៏មិនអាចទប់ទឹកភ្នែករបស់ខ្ញុំ ដែលជាសេចក្ដីអំណរ និងភាពសោកស្ដាយឲ្យបាននោះទេនៅពេលដែលធ្វើការទាំងនេះ។ ខ្ញុំមានសេចក្ដីអំណរ ព្រោះខ្ញុំបានរៀនអំពីគោលការណ៍នៃសេចក្ដីពិតជាច្រើនពី ព្រះបន្ទូលព្រះ ហើយភាពសោកស្ដាយនោះគឺដោយ ព្រោះពីមុនមកក្នុងជីវិតរបស់ខ្ញុំគឺបានរៀនអំពីគោលការណ៍ជាច្រើនដែលមិនមានរូបរាងច្បាស់លាស់ និងមិនអាចអនុវត្តបានពីបទពិសោធន៍ពួកជំនុំពីមុនមក។

តើមានអ្វីដែលធ្វើឲ្យសៀវភៅនេះខុសពីគេ នោះគឺគោលការណ៍នៃការធ្វើស្វ័យសិក្សា និងស្រាវជ្រាវដោយខ្លួនឯង។ អំឡុងពេលដែលអ្នកមានពន្លឺខ្លះក្នុងការរៀនព្រះបន្ទូល ព្រះបន្ទូលនោះឯងដែលនិយាយមកកាន់អ្នកដោយព្រះវិញ្ញាណបរិសុទ្ធ។ ព្រោះ ព្រះគម្ពីរគឺជាឧបករណ៍មុនគេក្នុងការចាប់ផ្ដើម។ តាមរយៈបទពិសោធន៍របស់ខ្ញុំជាគ្រូបង្រៀន និងជាគ្រូគង្វាល ខ្ញុំសង្កេតឃើញថាមានមនុស្សតិចណាស់ដែលសិក្សាស្វែកយល់អំពីពួកជំនុំត្រូវធ្វើការអ្វីខ្លះ ដោយបានរំពឹងពីព្រះបន្ទូលតែម្យ៉ាង។ មនុស្សជាច្រើនបានចំណាយពេលក្នុងការអានសៀវភៅដែលបានសរសេរឡើងដោយមនុស្ស ជាជាងសាងសង់សេចក្ដីជំនឿ និងការប្រព្រឹត្តលើព្រះបន្ទូលតែមួយនោះទេ។

ជារឿយៗ ខ្ញុំតែងនិយាយថា សៀវភៅណែនាំនេះគឺផ្ដល់ឲ្យអ្នកបានឃើញនូវ រូបភាពយ៉ាងធំក្រៃលែងរបស់ព្រះ។ វាគឺងាយនោះទេដើម្បីឲ្យបានយល់ដឹងពីសេចក្ដីសុចរិតមួយចំនួន តែមិនមានការផ្សារភ្ជាប់ការនោះទៅកាន់គ្រប់ទាំងគំនិត។ យើងទាំងអស់គ្នាត្រូវតែមើលទៅបទគម្ពីរកិច្ចការ ២០:២៧ *"ពីគ្រប់ទាំងគំនិតរបស់ព្រះ"* ។ ក្នុងទស្សនៈនេះ អ្នកនឹងដើរឆ្លងកាត់កណ្ដាលគម្ពីរកិច្ចការទាំងមូល ជាទីកន្លែងដែលអ្នករកឃើញនូវ *"គោលការណ៍សំខាន់ៗ"* របស់ពួកជំនុំមុនដំបូង។ បន្ទាប់ពីឆ្លងកាត់ទិដ្ឋភាពទូទៅរួច លោកអ្នកនឹងរៀនអំពីការដឹកនាំនៅក្នុងពួកជំនុំមុនដំបូង និងលក្ខណៈសម្បត្តិរបស់បុគ្គលនិមួយៗដែលធ្វើឲ្យមានការរីកចម្រើនទ្វេដង និងជាអ្នកដឹកនាំដែលសម្រេចតាមព្រះគម្ពីរ។ យើងនឹងបានសិក្សាអំពីសំបុត្រទាំងឡាយរបស់លោកប៉ុល ទៅតាមលំដាប់លំដោយដែលលោកបានសរសេរ។ នៅក្នុង ៦សំបុត្រដំបូងគឺជាការចាក់គ្រឹះនៅក្នុងដំណឹងល្អនៃព្រះគុណបរិសុទ្ធ ហើយបន្ទាប់មកទៀត ៤សំបុត្រគឺដើម្បីពង្រឹង និងការរួបរួមបណ្ដាពួកជំនុំក្នុងដំណឹងល្អ ចុងក្រោយគឺការយល់ដឹងអំពីគ្រួសារនៃព្រះ ដែលបង្ហាយក្នុង ៣សំបុត្របញ្ចប់។

ពីដើមដល់ចប់នៃសៀវភៅណែនាំនេះ អ្នកនឹងត្រូវធ្វើការអនុវត្តពីការរកឃើញរបស់អ្នក ទៅក្នុងជីវិត ការរៀបការគ្រួសារ និងកិច្ចការងារបម្រើព្រះរបស់អ្នកផ្ទាល់។ មេរៀនសំខាន់ៗគឺការបានសិក្សាពីខគម្ពីរជាច្រើនលើប្រធានបទផ្សេងៗ ហើយឲ្យអ្នករំលឹកមេរៀន និងខគម្ពីរទាំងនោះយ៉ាងម៉ត់ចត់ ដើម្បីឲ្យបានដឹងអំពីព្រះគម្ពីរមានបន្ទូលដូចម្ដេចខ្លះពីការនោះ។

មេរៀនសំខាន់ក្នុងសៀវភៅណែនាំនេះគឺជំពូកទី ៧។ សិស្សដែលយកគ្រប់មេរៀនដែលគាត់បានរៀនពីព្រះបន្ទូលព្រះនឹងអាចរៀបរំឡើងនូវយុទ្ធសាស្ត្រមួយ ដែលមានគោលការណ៍ជាច្រើន ដែលត្រូវបានប្រើក្នុងគ្រប់វប្បធម៌ សម័យកាល និងគ្រប់ស្ថានការណ៍។ អ្នកទាំងនោះនឹងមិនអាចបញ្ឈប់បានឡើយ!

ការយល់ដឹង និងឥទ្ធិពលរបស់លោករ៉ូឡេន អាលេន មិនអាចមើលរំលងបានឡើយ។ លោកបាននិយាយថា "ក្រុមអ្នកជឿមុនដំបូងត្រូវតែរៀបចំបំពាក់ឲ្យបានពេញលេញនូវគ្រប់ទាំងអំណាចខាងឯវិញ្ញាណ ដើម្បីឲ្យប្រាកដថាពួកគេអាចមានសម្តតភាពពង្រីកអ្នកជឿទ្វេដងដោយខ្លួនឯង ដោយមិនត្រូវការជំនួយពីខាងក្រៅ ប្រសិនបើពួកជំនុំនោះនៅក្នុងស្រុករបស់គេ ពួកជំនុំនោះត្រូវតែដុះឡើងពីដីដែលជាការព្រោះគ្រាប់ពូជមុនដំបូង។" *ការរីកសុះសាយដោយឯកឯងរបស់ពួកជំនុំ និងមូលហេតុដែលរារាំងការនោះ។* បងប្អូនអាចទាញយកដោយឥតគិតថ្លៃពី៖

http://www.newfoundationsinternational.org/training-resources.html

នេះជាដំណើរខាងវិញ្ញាណមួយដែលខុសពីដំណើរដែលអ្នកធ្លាប់មានពីមុនមក។ ខ្ញុំទុកចិត្តថាព្រះវិញ្ញាណនៃព្រះ នឹងបញ្ឆេះការរីកលូតលាស់ឥតឈប់ឈរក្នុងចិត្តរបស់អ្នក ដែលជាលទ្ធផលពីការចាប់ផ្តើមការសិក្សានេះ។ យើងទាំងអស់គ្នានឹងអាចនាំដំណឹងល្អនៃព្រះគុណនេះ ទៅដល់គ្រប់ទាំងក្រុមមនុស្សដែលមិនទាន់បានសង្គ្រោះនៅគ្រប់ទិសទីនៅផែនដី ហើយទើបនឹងបានដល់ចុងបំផុត (ម៉ាថាយ ២៤:១៤)។

ពីខ្ញុំ ស្ទើយម៉ាន ខេ ដាយរីល

# សេចក្តីផ្តើម

ខ្ញុំសូមធ្វើការណែនាំពីសៀវភៅ *ផែនការព្រះសម្រាប់ពួកជំនុំរបស់ទ្រង់* ជាសៀវភៅណែនាំ និងសៀវភៅលំហាត់មួយសម្រាប់ការបង្កើតពួកជំនុំ និងការបន្តជាថ្មីឡើងវិញរបស់ពួកជំនុំ។ ខ្ញុំជឿជាក់ថាសម្ភារៈនេះគឺពាក់ពន្ធ័ពីពួកជំនុំបច្ចុប្បន្ន និងបណ្តាអ្នកដឹកនាំពួកជំនុំ ពីព្រោះសៀវភៅនេះ ៖

- **ការដាំ** នូវគ្រឹះដោយ **អំណាច និងភាពគ្រប់គ្រាន់របស់ព្រះបន្ទូល**
- **ការបើក** នូវឱកាសសម្រាប់ **ការធ្វើការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធ**
- **ការសម្តែង** ឲ្យបានឃើញអំពី **សារៈសំខាន់នៃគ្រួសារ** នៅក្នុងដំណើរការរបស់ពួកជំនុំ និងការបន្តជាថ្មី
- **ការមើលឃើញ** ដែលបង្ហាញឲ្យឃើញពីគោលការណ៍នៃផែនការព្រះសម្រាប់ពួកជំនុំទ្រង់ បន្ទាប់ពីថ្ងៃបុណ្យទី៥០មក
- **ការជួយ** អ្នកដឹកនាំ និងពួកជំនុំឲ្យប្រែក្លាយជាមាន **ព្រះគ្រីស្ទជាចំណុចកណ្តាល និងការជួយខ្លួនឯង** ដូចទៅនឹងលោកប៉ុលដែរ
- **ការប្រើប្រាស់** **អំណាចចេស្តាដែលគ្របដណ្តប់លើគ្រប់វប្បធម៌ និងសម័យកាលនានាពីគោលការណ៍**មានក្នុងព្រះគម្ពីរ
- **ការផ្តល់** **ដំណោះស្រាយតាមព្រះគម្ពីរ** ដើម្បីដោះស្រាយបញ្ហាដែលកំពុងជួបប្រទះក្នុងគ្រួសារ និងពួកជំនុំមាននៅពេលបច្ចុប្បន្ននេះ
- **ការបង្រៀន** **ពី គំរូនៃការដឹកនាំ និងបង្កើតពួកជំនុំ និងការបន្តជាថ្មីឡើងវិញ** ដែលជាគំរូ "**មិនអាចបញ្ឈប់បាន**" ហើយនិងអាចលូតលាស់ទៅមុខទោះជានៅក្នុងពេលដ៏លំបាក និងត្រូវការបៀតបៀនក៏ដោយ

សៀវភៅណែនាំនេះគឺមិនមែនជាទ្រឹស្តី ឬការបង្រៀនថ្មីរបស់លោកខាងលិច ឬខាងកើតឡើយ តែជាបន្ទាល់នៃពេលវេលាប្រវត្តិសាស្ត្រដែលបានបញ្ជាក់ពីគំរូនៅក្នុងកណ្ឌគម្ពីរ កិច្ចការ។ វាក៏មិនមែនជាការនិពន្ធ ដើម្បីបង្រៀនទ្រឹស្តីថ្មី ឬជំរុញបន្ថែមនូវទ្រឹស្តីចាស់ៗនោះទេ! តាមរយៈការដើរតាមគំរូរបស់ព្រះគ្រីស្ទ និងពួកសាវក ដោយពឹងអាងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ អ្នកនឹងអាចមើលឃើញពីការលូតលាស់របស់ពួកជំនុំ និងការបង្កើតពួកជំនុំដោយជោគជ័យ។ ដែលអ្នកសំឡឹងមើលទៅព្រះអម្ចាស់ អ្នកត្រូវដឹងប្រាកដថា ព្រះទ្រង់សព្វព្រះទ័យនឹង ជួបអ្នក ចញ្ចឹមអ្នកឲ្យធំឡើង រៀបចំបំពាក់តួនាទី ប្រទានអំណាច ហើយនិងចង្អុលបង្ហាញអ្នក ដើម្បីឲ្យអ្នកបង្កើតពួកជំនុំ និងបន្តពួកជំនុំជាថ្មីឡើងវិញជាការសម្រាប់ សិរីល្អរបស់ទ្រង់ដែលជាឱកាសសម្រាប់អ្នកក្នុងការផ្លាស់ប្រែនេះ។

## ជំពូកទី ១ ៖

### ការប្រឈមមុខរបស់យើង

# ការបែរទៅរក ព្រះបន្ទូលរបស់ព្រះ




"ខ្លួនខ្ញុំផ្ទាល់តែងតែ ស្វែងរកមធ្យាបាយ ហើយចោទជាសួរខ្លួនឯងពីសេចក្តីពិត រាល់ពេលដែលខ្ញុំសម្លឹងមើលទៅតថភាព និងយុទ្ធសាស្រ្តពួកជំនុំរបស់បេសកជនវ័យក្មេងនៅក្នុងកណ្ឌគម្ពីរកិច្ចការ ដូចដែលខ្ញុំបានស្វែងរកមើលតាមបទគម្ពីរម៉ាថាយ ២៨:១៩ *«ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍»*។ ដោយមានការពិចារណាពីបទគម្ពីរ នាំឲ្យយើងបានឃើញថា ពួកជំនុំដើមមិនបានត្រេកអរនឹងចំនួនតួលេខ ដែលពួកយើងមានដ៏ច្រើន ឬពីការរីកចម្រើននៃបច្ចេកវិទ្យា ដែលយើងអាចប្រាកដបាននោះ ពោលគឺពួកគេគ្មានការទាំងនេះទេ តែវាជាចម្ងល់មួយដែរ អំពីរបៀបដែលក្រុមពួកសិស្សតូចមួយនេះ និងពួកសាវកបានធ្វើការដែលមានការជះឥទ្ធិពលដ៏ខ្លាំងសម្បើម នៅក្នុងសម័យកាលរបស់ពួកគេ។ តើអ្វីដែលជាអាថ៌កំបាំងរបស់ពួកគេ? តើយើងអាចរៀនសូត្រអ្វីខ្លះ ពីយុទ្ធសាស្រ្តរបស់ពួកគេ?"

លោកគ្រូគង្វាល នៅប្រទេសអ៊ូហ្គង់ដា- *David Zac Niringiye, Uganda, Africa*

**សំណួរពិភាក្សា** ៖ ប្រសិនបើអ្នកមានក្រុមសិក្សា សូមអ្នកបំបែកទៅជាក្រុមតូចៗដើម្បីពិភាក្សាសំណួរនៅខាងក្រោមនេះ។ សូមសរសេរចម្លើយរបស់អ្នកនៅខាងក្រោមសំណួរពេលបញ្ចប់ការពិភាក្សា រួចត្រូវរាយការណ៍ទៅក្រុមទាំងមូល។

-តើអ្នកយល់យ៉ាងដូចម្តេច អំពីអាថ៌កំបាំងដែលធ្វើឲ្យការជះឥទ្ធិពលដ៏ខ្លាំង និងការរីកសុះសាយរបស់ពួកជំនុំមុនដំបូង?

____________________

____________________

____________________

____________________

____________________

-តើអ្នកអាចរៀនសូត្រអ្វីខ្លះ ពីយុទ្ធសាស្រ្តរបស់ពួកជំនុំមុនដំបូង? ____________________

____________________

____________________

____________________

____________________

____________________

## ការណែនាំអំពីគំរូរបស់លោក ប៉ុល តាមព្រះគម្ពីរ

សូមមើលផែនទីនៅខាងក្រោម! តើមានការរីកសុះសាយនៃដំណឹងល្អចាប់ពីក្រុងយេរូសាឡិម រហូតដល់ក្រុងរ៉ូម មានរយៈពេលប៉ុន្មានឆ្នាំ?________។ ចម្លើយគឺ ២៥ឆ្នាំ! ខ្ញុំសូមសួរថា តើអ្នកដឹងទេថាតើមានពួកជំនុំនៅក្នុងសហរដ្ឋអាមេរិក ឬក្នុងពិភពលោក ដែលកំពុងតែមានដំណើរការធ្វើការយ៉ាងមានឥទ្ធិពលបែបនេះដែលឬទេ?

សូមបើកទៅទំព័រ ០០០-០០០ ចំណុច **ជំនួយបន្ថែម** ហើយសូមមើលផែនទី ដោយកំណត់សម្គាល់ពីចំនួនប៉ុន្មានឆ្នាំ ដែលលោកប៉ុលបានធ្វើការបញ្ចប់ដំណើរបេសកកម្មទាំង៣របស់គាត់ដែលត្រូវបានចាប់ពីទីក្រុងអាន់ទីយ៉ូក អំឡុងឆ្នាំ ៤៧ គ.ស។ ________។ ពិតជាអស្ចារ្យណាស់! លើកសូមបើកទៅកាន់ទំព័រដដែលម្តងទៀត ហើយសូមមើលខាងក្រោមផែនទី តើមានចម្ងាយប៉ុន្មានគីឡូម៉ែត ដែលលោកប៉ុលបានធ្វើដំណើរបេសកកម្មទាំង៣លើករបស់លោក?______។ ត្រឹមត្រូវណាស់គឺ ៨,០០០ ម៉ៃ ឬជាង ១២,០០០ គីឡូម៉ែត។ តើអ្នកដឹងឬទេ ថាមាននរណាដែលកំពុងតែធ្វើការយ៉ាងមានឥទ្ធិពលបែបនេះ?__ _________។ តែប៉ុល មិនមានម៉ូតូ ឡាន យន្តហោះ ឬសម្ភារៈទំនើបទាំងនេះទេ។ ដូច្នេះវាពិតជាមានការលំបាកក្នុង ស្វែងរកគំរូដែលល្អជាងពួកជំនុំមុនដំបូង ដូចជាសាវកប៉ុល ក្នុងកិច្ចការងារបង្កើត ថែទាំ និងពង្រីកពួកជំនុំ។




### ចាប់ពីទីក្រុងយេរូសាឡិម ដល់ទីក្រុងរ៉ូមមានចម្ងាយ ៥,០០០ គម ឬ ៣,១០០ ម៉ៃ

នៅក្នុងរយៈពេលជាង ១០ឆ្នាំ ប៉ុលបានបង្កើតពួកជំនុំបាន ៤ខេត្តផ្សេងគ្នា៖ ក្រុងកាឡាទី ស្រុកម៉ាសុីដូនា ស្រុកអាខៃ និងអាសុីកណ្តាល។ នៅមុនឆ្នាំ ៤៧គ.ស នៅក្រុងស្រុកទាំងនោះមិនទាន់មានពួកជំនុំនៅឡើយទេ ប៉ុន្តែចាប់តាំងពីឆ្នាំ ៥៧ គ.ស ប៉ុលបាននិយាយអំពីកិច្ចការរបស់លោកនៅទីនោះដែលកំពុងហៀបនឹងបញ្ចប់ ដោយយោងតាម រ៉ូម ១៥:១៩-២០។

សព្វថ្ងៃនេះគ្រូគែអ្នកបង្កើតពួកជំនុំ អ្នកផ្សព្វផ្សាយដំណឹងល្អ និងពួកសិស្សអាចទទួលបានចំនួនអ្នកប្រែចិត្តជឿច្រើនជាងប៉ុល ក៏ប៉ុន្តែមានចំនួនតិចតួចណាស់ ដែលកំពុងតែធ្វើការការបង្កើតពួកជំនុំ និងបង្កើតពួកជំនុំឡើងវិញ។ ចំណែកពួកសិស្ស និងអ្នកបង្កើតពួកជំនុំជាច្រើនគឺបានធ្វើដំណើរពីទីកន្លែងមួយទៅទីកន្លែងមួយដោយពុំមានផែនការ ឬយុទ្ធសាស្ត្រតាមសៀវភៅណាទាល់តែសោះ។ មានកន្លែងជាច្រើន នៅក្នុងសម័យទំនើបយើងនេះ ពួកសិស្ស ហើយនឹងពួកបេសកជន គេមិនបានយល់ ថែម

ទាំងមិនបានធ្វើតាមយុទ្ធសាស្រ្តរបស់ប៉ុលក្នុងការងារដែលធ្វើឲ្យមានលូតលាស់ក្នុងការបង្កើតពួកជំនុំនោះទេ។ ប៉ុន្តែក៏មានមនុស្សមួយចំនួននិយាយថា "កាលពីជំនន់ប៉ុលគឺខុសគ្នា។" ហើយមានអ្នកខ្លះក៏សួរសំណួរទៀតថា "តើស្ថានភាពរបស់លោកប៉ុលបានជួយអ្វីខ្លះដល់ការជោយជ័យរបស់លោក?" ប្រាកដណាស់ នឹងត្រូវមានអ្នកដែលត្រូវតែទទួលស្គាល់ថា អ្នកដែលប៉ុលបានផ្សាយឲ្យជឿគឺសុទ្ធតែជាមនុស្សដែលកើត ហើយធំឡើងក្នុងបរិស្ថានសង្គមមួយដែលដូចទៅនឹងពិភពលោកយើងសព្វថ្ងៃដែរ។ ក្នុងសម័យរបស់ប៉ុល ការលះបង់របស់មនុស្សគឺធម្មតា ការជឿលើគ្រូធ្មប់ និងវិញ្ញាណអារក្សគឺជាទូទៅទៅហើយ។ ការទាំងនេះមិនអាចផ្លាស់ប្រែបានោះទេ ដែលព្រះវិញ្ញាណរបស់ព្រះគ្រីស្ទបានអនុញ្ញាតឲ្យពួកសិស្សធ្វើការបញ្ឈប់ការអាក្រក់ទាំងនោះពីក្នុងដួងចិត្តមនុស្ស។ ដូច្នេះការនាំឲ្យបានសង្គ្រោះ គឺមិនបានមកដោយយល់ព្រមនោះទេ តែតាម រយៈការប្រកាសពីភាពឧត្តមរបស់ព្រះគ្រីស្ទ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ! ដូច្នេះ វាមិនអាចទៅរួចនោះទេដែលមានការខ្វែងគំនិតគ្នាអំពីគោលការណ៍ណាមួយរបស់ប៉ុល មកធ្វើការគិតថាតើការនោះផ្តល់ផលប្រយោជន៍ ឬផលវិបាកមកលើអ្វីខ្លះនាស្ថានភាពបច្ចុប្បន្ននេះ ប្រសិនបើមានការគិតបែបនេះមែន នោះវានឹងមានផលវិបាកមែនហើយ ព្រោះបណ្តាមកពីការពឹងផ្អែករបស់យើងលើទ្រឹស្តីនិយមក្នុងពេលបច្ចុប្បន្ន។

**ដើម្បីឲ្យយើងបានសិក្សាស្វែងអំពីសេចក្តីផ្តើមនៃយុទ្ធសាស្រ្តបង្កើតពួកជំនុំរបស់ប៉ុល សូមបងប្អូនធ្វើការសង្កេតមើលវិធី ឬតំណាក់កាលទាំង៤នៃយុទ្ធសាស្រ្តរបស់គាត់ ដែលវាពាក់ព័ន្ធជាមួយរបៀបនៃការបង្កើតពួកជំនុំសព្វថ្ងៃ ៖**

## - វិធីទី១៖ ការផ្សាយដំណឹងល្អ Evangelizing

ការផ្សាយដំណឹងល្អរបស់ប៉ុល គឺពោរពេញទៅដោយការបញ្ចុះបញ្ចូលពីដំណឹងល្អដ៏បរិសុទ្ធ ដូចមានក្នុងបទគម្ពីរកូរិនថូស ទី១ ២:២ "ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង" នៅបទគម្ពីររ៉ូម ១:១៦។ ឈើឆ្កាង គឺជាប្រធានបទដ៏ធំបំផុតតែមួយគត់ ដែលប៉ុលប្រើមកភ្ជាប់ជាមួយការប្រែចិត្ត និងសេចក្តីជំនឿ មិនមែនជាទស្សនៈវិជ្ជា ឬចិត្តវិជ្ជា ឬកម្មវិធីមួយចំនួនដែលព្យាយាមធ្វើវាឲ្យមានភាពស្រដៀង ឬសម្របទៅនឹងវប្បធម៌របស់មនុស្សទេ។ ក្នុងការប្រកាសដំណឹងល្អរបស់លោកប៉ុល លោកតែងតែបញ្ជ្រាបតាមរយៈសេចក្តីសង្ឃឹម (កិច្ចការ ២៦:២៧)។ នេះគឺជាសាររបស់ផងគាត់។ ប្រសិនជាមនុស្សជាច្រើនបដិសេធន៍គាត់ ដូចពួកគេបានធ្វើដាក់ព្រះគ្រីស្ទ (លូកា ៩:៥) នោះគាត់ក៏រលាស់ធូលីដី ពីជើងចេញ រួចចេញទៅរកមនុស្សដែលមានដួងចិត្តទទួលដំណឹងល្អ ជាកន្លែងដែលព្រះធ្វើការ (កិច្ចការ ១៣:៥១)។ បើយើងនៅតែបន្តផ្សាយដំណឹងល្អនៅទីកន្លែងដែលព្រះទ្រង់មិនធ្វើបានការ ដូចជាយើងបន្ទាបដំណឹងល្អដ៏ខ្ពស់របស់ទ្រង់ ទៅដល់កម្រិតមួយដែលគ្រាន់តែជាការបង្រៀនដល់មនុស្សតាមបញ្ញាខ្លួនដូច្នោះដែរ។

ទិដ្ឋភាពមួយជ្រុងទៀតក្នុងការផ្សាយដំណឹងល្អរបស់ប៉ុល គឺគាត់មិនបានផ្សាយដំណឹងល្អដល់មនុស្សគ្រប់គ្នានៅក្នុងតំបន់ទាំងនោះដោយខ្លួនឯងនោះទេ។ បច្ចុប្បន្ននេះ ការផ្សាយដំណឹងល្អ គឺយើងតែងតែបញ្ជូនមនុស្សចេញទៅតែម្នាក់ៗ ឬជាក្រុម ឲ្យពួកគេព្យាយាមចូលទៅដល់មនុស្សនៅក្នុងតំបន់ដោយខ្លួនឯង និងតាមលទ្ធភាព។ ដោយសារការដែលយើងមិនអើពើអំពីយុទ្ធសាស្រ្តរបស់ប៉ុលក្នុងការបង្កើតពួកជំនុំ ដែលមានសម្តតភាពក្នុងការផ្សាយដំណឹងល្អ ទើបធ្វើឲ្យយើងធ្វើការមានកម្រិតមួយដែលកំណត់អំពីការធ្វើរបស់មនុស្សម្នាក់ ឬក្រុមនោះអាចធ្វើយ៉ាងមានកម្រិតបំផុត។ គោលដៅរបស់ប៉ុល គឺដើម្បីបង្កើត **<u>ពួកជំនុំដែលអាចបង្កើតពួកជំនុំបន្ថែម</u>** ដែលជាការបង្ហាញពីជីវិតរបស់ព្រះគ្រីស្ទនៅក្នុងតំបន់យុទ្ធសាស្រ្ត (កិច្ចការ ១១:២៦)។

សម្រាប់ពួកជំនុំដែលមានសព្វថ្ងៃគឺដាក់ជាសំណួរថា តើយើងត្រូវប្រើប្រាស់ពួកជំនុំឲ្យទៅក្នុងយុទ្ធសាស្ត្រផ្សាយដំណឹងល្អរបស់យើងឬទេ? ព្រោះពួកជំនុំជាកូនសោរយ៉ាងសំខាន់ ដែលបានចេញសកម្មភាពផ្សព្វផ្សាយពីដំណឹងល្អទៅដល់គ្រប់ទិសទីកន្លែង (ថែស្សាឡូនីច ទី១ ១:៦-៨)។

## - វិធីទី២៖ ការតាំងឡើង Establishing

របៀបទីពីរនៃយុទ្ធសាស្ត្ររបស់ប៉ុល គឺជា ការបង្កើត។ ប៉ុលបានបង្កើតពួកជំនុំនៅក្នុងស្រុកជាច្រើន ដែលអាចឈរ នឹងផ្គត់ផ្គង់ដោយខ្លួនឯងបាន។ ជំនួសឲ្យការទទួលជំនួយពីខាងក្រៅ ពួកជំនុំទាំងនេះបានព្យាយាមរៀនពឹងផ្អែកលើព្រះ មិនត្រឹមតែគ្រាន់តែការជួយក្នុងពួកបងប្អូនដោយក្តីមេត្តាស្រឡាញ់នោះទេ ពួកគេថែមទាំងជួយអ្នកដទៃផងដែរ (កូរិនថូស ទី២ ៨:១-៥)។ គំរូរបស់ប៉ុលពីការផ្គត់ផ្គង់ខ្លួនឯង ដោយដៃគាត់ទាំងពីរផ្ទាល់ គឺជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលធ្វើឲ្យពួកជំនុំទាំងនោះបានរៀនសូត្រយ៉ាងឆាប់រហ័សពីការប្រែក្លាយជា ពួកជំនុំដែលអាចឈរដោយខ្លួនឯងបាន។ ប៉ុល គឺមានការប្រុងប្រយ័ត្នយ៉ាងខ្លាំង ក្នុងការជៀសវាងការកើតឡើងនូវចំណូលលុយផ្សេងៗ ឬការទទួលបានប្រាក់លើកទឹកចិត្តណាមួយពីក្នុងការងាររបស់លោក។

បច្ចុប្បន្ននេះ ការធ្វើការរបស់ពួកជំនុំ និងអង្គការបេសកកម្មជាច្រើន បានប្រែក្លាយទៅជាស្ថាប័នហរិញ្ញវត្ថុដែលត្រូវការលុយជំនួយជាជាងរស់នៅជា រូបកាយដ៏រស់នៅរបស់ព្រះគ្រីស្ទ។ ទូទៅហើយដែលយើងតែងតែឮ ពីអង្គការ ឬស្ថាប័នជាច្រើន ថាមិនអាចមានលទ្ធភាពក្នុងការបង្កើតពួកជំនុំ ការពង្រីកបេសកកម្មរបស់ពួកគេ ឬក៏ការផ្គត់ផ្គង់សម្រាប់ការហ្វឹកហ្វឺនក្នុងស្ថាប័ន ឬអង្គការនោះទេ បើពុំមានជំនួយលុយសម្រាប់ធ្វើការទាំងនេះ ការទាំងអស់នេះកើតឡើងគឺដោយព្រោះពួកគេបានព្យាយាមក្នុងការពឹងផ្អែកទាំងស្រុងលើលុយកាក់ ជាជាងពឹងផ្អែកទុកចិត្តលើព្រះអម្ចាស់។ ជំនួយជាលុយនេះហើយ ដែលបង្កើតឲ្យមានរបៀបជាសាសនា ហើយផលិតបាននូវអ្នកជឿជាច្រើនបន្តបន្ទាប់ ជាអ្នកដែលរៀនតែពីការពឹងផ្អែកលើលុយកាក់ ជាជាងព្រះអម្ចាស់ ហើយនិងព្រះវិញ្ញាណបរិសុទ្ធ ។

ជាទំនៀមទំលាប់ ដែលបានជាគំនិតទស្សនៈ ដើម្បីឲ្យពួកជំនុំមានភាពនឹងនរ ពួកជំនុំត្រូវពឹងផ្អែកឲ្យមានអគារដោយខ្លួនឯង សាងសង់អគារផ្ទាល់ខ្លួន និងការទទួលបានជំនួយលុយពីខាងក្រៅ។ ហើយនៅពេលដែលអ្នកបាននូវអគារ ឬក៏ជំនួយលុយគ្រប់គ្រាន់ អ្នកនឹងមានគំនិតថា ពួកជំនុំ ឬបេសកកម្មមួយនេះគឺ បានបង្កើតរឹងមាំ ហើយក៏មានការទទួលស្គាល់ពីព្រះដែរ។ ការពិតជាក់ស្តែង អគារ លុយ គឺគ្មានអំណាចណាមួយដែលបង្កើតឲ្យចេញជាផលផ្លែខាងព្រះវិញ្ញាណនោះទេ ពោលអាចនឹងរាំងរាំងផលផ្លែ (លទ្ធផល) នៃព្រះវិញ្ញាណទៅវិញទេ។

## - វិធីទី៣៖ ការបំពាក់បំប៉ន Equipping

របៀបទី៣ នៃយុទ្ធសាស្ត្ររបស់ប៉ុល គឺការបំពាក់បំប៉ន ឬការរៀបចំ។ ជាធម្មតារៀងរាល់ពេលដែលប៉ុលបានអធិប្បាយនៅទីកន្លែងណាមួយជាច្រើនខែរួចមក មុនដែលលោកចាកចេញ លោកតែងទុកដាក់ឲ្យពួកជំនុំនៅក្នុងស្រុកទាំងនោះ មានសម្ថតភាពគ្រប់គ្រាន់ក្នុងការលូតលាស់ និងពង្រីកខ្លួនបានដោយខ្លួនឯង។ នៅក្នុងពួកជំនុំមួយចំនួនលោកបានទុកដាក់ពួកចាស់ទុំដែលមានសម្ថតភាព សម្រាប់រៀបចំពួកបរិសុទ្ធនៅក្នុងការងារបម្រើ។ ក្នុងដំណើរការមានឧបសគ្គដ៏លំបាកជាច្រើន តែប៉ុលបានមានសេចក្តីជំនឿក្នុងព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើឲ្យលោកមិនបានភ័យខ្លាចពីឧបសគ្គទាំងនោះទេ។ សឹងតែគ្រប់ពេល ដែលប៉ុលបានរៀបចំពួកជំនុំដែលនៅក្មេងខ្ចី និងពួកចាស់ទុំជាមួយនឹងប្រព័ន្ធដែលមិនកំណត់ជាកម្រិតស្តង់ដាណាមួយ ឬ

ទម្រង់សម្រាប់ការជួបជុំ ឬការប្រមូលផ្តុំនោះឡើយ គឺគ្រាន់តែការបង្រៀនអំពីដំណឹងល្អយ៉ាងងាយ អំពីលក្ខណៈសម្គាល់របស់អ្នកត្រួតត្រា ឬអ្នកគង្វាល ហើយនិងកិច្ចការពីរទៀត (សូមមើល **ជំនួយបន្ថែម** អំពី **ពិធិបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ នៅទំព័រ 195-197**)។

ប៉ុលបានបង្រៀនមនុស្សធម្មតាទាំងនោះ សុទ្ធសឹងតែជាអ្នកដែលមិនអាចអានបាន ដោយលោកប្រើប្រាស់ព្រះគម្ពីរសញ្ញាចាស់ និងពីការដែលពួកសាវកពីមុនៗមកបានមើលឃើញដោយភ្នែកពួកគេ និងបានឮដោយត្រចៀកពួកគេ។ ការបង្រៀនពីដំណឹងល្អដោយមានភាពសាមញ្ញ និងសង្ខេប គឺជាបានបង្កើតនូវអំណាចដល់ពួកជំនុំ។ ដោយសារការចាកចេញរបស់លោក ទើបជាកត្តាជំរុញឲ្យពួកជំនុំចេះគិត និយាយ និងធ្វើការបម្រើដោយខ្លួនគេផ្ទាល់ ទោះបីជាពួកគេមិនមានសិរីភាពពេញលេញពីតម្រូវការ ការលូតលាស់ និងការណែនាំ។ លោកប៉ុលបានបន្សល់ទុកឲ្យពួកចាស់ទុំនូវ មូលដ្ឋាននៃលក្ខណៈសម្បត្តិបុគ្គល និងសេចក្តីណែនាំសម្រាប់ការរៀបចំពួកបរិសុទ្ធ សម្រាប់ធ្វើការការងារបម្រើព្រះ (អេភេសូ ៤:១១-១២)។

ជារើយៗ ពួកជំនុំជាច្រើនសព្វថ្ងៃនេះ គឺមានការពឹងផ្អែកខ្លាំងណាស់ទៅលើមនុស្សតែម្នាក់ ដែលជាអ្នកបង្កើតពួកជំនុំនោះ ឬ "គ្រូគង្វាលតែម្នាក់" ដែលធ្វើការបម្រើនៅទីនោះ។ ជារើយៗ អ្នកជឿជាច្រើន និងច្រើនជំនន់នៅតែមានការពឹងផ្អែកទៅលើគ្រូគង្វាលតែម្នាក់ ឬសិស្ស និងអ្នកបន្តវេនរបស់គាត់។ នៅពេលដែលប៉ុលចាកចេញពីពួកជំនុំនៅពេលវេលាកំណត់ វាបានផ្តល់ឱកាសដល់អ្នកដឹកនាំពួកជំនុំនូវការបោះជំហានចូលទៅតួនាទី និងការទទួលខុសត្រូវផ្សេងៗ ក៏ជំរុញពួកគេឲ្យបានដឹងច្បាស់ថា ពួកគេមិនអាចពឹងផ្អែកទៅលើតែសាវកប៉ុលបាននោះទេ។

សព្វថ្ងៃនេះ យើងគឺមិនមានការហ្វឹកហ្វឺនពួកអ្នកជឿឲ្យប្រើប្រាស់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលបានផ្តល់ឲ្យពួកគេនោះទេ។ យើងមានការបកស្រាយច្រុលអំពីលក្ខណៈសម្បត្តិនៃអ្នកដឹកនាំដោយបញ្ញា ដោយធ្វើការផ្អែកយ៉ាងខ្លាំងលើ ការកំណត់ស្តង់ដាការអប់រំ។ ដូច្នេះរហូតមកទល់ពេលនេះស្តង់ដាលោកិយនេះអាចធ្វើឲ្យមានការកំណត់ ជាតម្រូវការយ៉ាងសំខាន់សម្រាប់ការធ្វើកិច្ចការងារបម្រើ និងការដឹកនាំ។

សម្រាប់ពួកជំនុំថ្មី គួតែមានការពឹងផ្អែកទៅលើធនធានរបស់ខ្លួនផ្ទាល់ ជាពិសេសគឺពឹងផ្អែកទៅលើព្រះ។ សព្វថ្ងៃប្រសិនបើមានបេសកជនណាដែលបានបង្កើតពួកជំនុំដូចនឹងគំរូប៉ុល គាត់ប្រាកដជាមានគេប្រាប់គាត់ថ្ងៃរបៀបទាំងនេះគឺគ្មានសង្ឃឹម ហើយនិងគ្រោះថ្នាក់ណាស់។ យ៉ាងណាមិញសេចក្តីពិតនៅតែជាក់លាក់ លោកប៉ុលគឺជាស្ថាបនិកនៃពួកជំនុំដែលមានជោគជ័យខ្លាំងបំផុត ដែលពិភពលោកនេះមិនដែលបានជួបពីមុនមក។

## - វិធីទី៤៖ ការរីកសុះសាយ ឬការពង្រីក Expanding

ជារបៀបចុងក្រោយ ដែលជាយុទ្ធសាស្ត្រនៃការរីកសុះសាយរបស់ប៉ុល គឺជាលទ្ធផលនៃការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ (កិច្ចការ ១៣:១-៤)។ វាពិតជាគួឲ្យចាប់អារម្មណ៍ នៅពេលដែលយើងសង្កេតពីរបៀបនៃការផ្សាយដំណឹងល្អចេញពីក្រុងយេរូសាឡិម ទៅកាន់ពិភពលោក ហើយការទាំងនេះបានចាប់ផ្តើមបន្ទាប់ពីពេលព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតលើពួកគេនៅថ្ងៃបុណ្យទី៥០ ។ ហើយអ្នកដែលបានទទួលជឿទាំងប៉ុន្មាននៅពេលនោះ បានប្រែក្លាយជាអ្នកផ្សាយដំណឹងល្អយ៉ាងអស្ចារ្យ ហេតុអ្វី? ព្រោះនៅពេលមនុស្សម្នាក់ដែលបានទទួលព្រះវិញ្ញាណ គាត់ចាប់ផ្តើមស្វែងរក និងនាំចំណេះដឹងក្នុងព្រះគ្រីស្ទដែលពួកគេមានទៅកាន់អ្នកដទៃទៀត ដូចមាននៅក្នុងកណ្ឌគម្ពីរ កិច្ចការ។ ជាប្រវត្តិសាស្ត្រ គ្រប់ទាំងសេចក្តីបង្រៀននៃការរស់ឡើងវិញពីបុគ្គលល្បីៗ ដូចជាគោលលិទ្ធិ ហេស្តេក (The Haystack) គ្រេត អាវេកឃីត (Great Awakenings) អ្នកមកពីតំបន់វេលស៍ (Welsh) ឬ ពួកជនជាតិកូរ៉េខាងត្បូង (the South Korean) សុទ្ធតែនៅក្នុងការធ្វើការផ្សាយដំណឹងល្អ និងការស្តាប់បង្គាប់នូវមហាបេសកកម្ម។ នេះគឺមិនមានអ្វីចម្លែកទេ ចាប់តាំងពីព្រះវិញ្ញាណដែលយើងទទួលបាន គឺជាវិញ្ញាណនៃបេសកកម្ម ជាព្រះ

វិញ្ញាណនៃអង្គព្រះយេស៊ូវ ដែលបានយាងមកពិភពលោកដើម្បីសង្គ្រោះព្រលឹងមនុស្សបាត់បង់ទៅឯព្រះវរបិតា។ យើងនឹងសិក្សាទាំងអស់គ្នាពីក្នុងកណ្ឌគម្ពីរកិច្ចការ ពីរបៀបពួកជំនុំដែលរឹងមាំក្នុងសេចក្ដីជំនឿ និងរីកចម្រើនច្រើនពីក្នុងទីក្រុងកាឡាទី ហើយនិងពីរបៀបនៃការផ្សព្វផ្សាយព្រះបន្ទូលនៃព្រះពីស្រុកម៉ាសេដូន និងស្រុកអាខៃ ពីក្រុងថែស្សាឡូនីច និងពីរបៀបផ្សព្វផ្សាយដំណឹងល្អទូទៅប្រទេសនៅជិតខាង ពីក្រុងអេភេសូ (ថែស្សាឡូនីច ទី១ ១:៥-៩)។

ប៉ុល បានដឹកនាំពួកអ្នកជឿថ្មីៗឲ្យយល់ដឹងអំពីសារៈសំខាន់នៃព្រះវិញ្ញាណបរិសុទ្ធនៃព្រះគ្រីស្ទ ជាព្រះដែលពួកគេស្មគ្រចិត្តថ្វាយ។ លោកបានធ្វើជាគំរូ ដែលស្របទៅនឹងព្រះហឫទ័យនៃព្រះគ្រីស្ទ។ ប៉ុល បានណែនាំពួកគេ អំពីការសណ្ឋិតនៅរបស់ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ដោយក្នុងការបញ្ចេះ និងអំណាចចេស្ដារបស់ទ្រង់ នឹងជួយឲ្យពួកជំនុំធ្វើការរីកចម្រើន។ នៅពេលការចាក់គ្រឹះរបស់ពួកជំនុំមិនត្រឹមត្រូវ ខ្ញុំប្រាកដថា វិញ្ញាណរបស់អ្នកផ្សាយដំណឹងល្អនឹងរលត់ទៅ ហើយចុងក្រោយពួកជំនុំនឹងនៅទ្រឹង។ នេះហើយជាហេតុ ដែលជំរុញឲ្យប្រើប្រាស់នូវគុសតាំងនៃគំរូ និងរបៀបនៃការហ្វឹកហ្វឺនរបស់ប៉ុល យើងរាល់គ្នាត្រូវបានប្រាប់ឲ្យដើរតាម ឬធ្វើត្រាប់តាមប៉ុល ដូចដែលលោកបានដើរតាមព្រះគ្រីស្ទ (កូរិនថូស ទី១ ១១:១)។

<u>**បណ្ដាពួកជំនុំសព្វថ្ងៃនេះ**</u> មានចំនួនច្រើន គឺនៅខ្សោយ ហើយនៅទ្រឹង បើសិនយើងប្រៀបធៀបទៅពួកជំនុំដើមនៅក្នុងកណ្ឌគម្ពីរ កិច្ចការ។ នៅខាងក្រោមនេះគឺជា ការបែងចែកអាការៈជា ៣ ដែលយើងឃើញកើតមាននៅក្នុងបណ្ដាពួកជំនុំ និងស្ថាប័នក្នុងពេលបច្ចុប្បន្ន។ មុនដំបូង យើងនឹងធ្វើការសង្កេតអាការៈនិមួយៗ រួចមកយើងនឹងធ្វើការពិភាក្សាចំនុចនិមួយៗនៅទំព័រទី ០០ យើងអាចរកឃើញដំណោះស្រាយផ្សេងៗ ដើម្បីដោះស្រាយបញ្ហាទាំង៣នេះ។

១. យើងមើលឃើញថាមានការប៉ះពាល់តិចតួចនៅក្នុងសហគមន៍ និងទីកន្លែងផ្សេងៗ ដូចនៅក្នុងពួកជំនុំដើម (កិច្ចការ ១៧:៦)។ ពួកជំនុំជាច្រើនពុំមានការពង្រីក ពួកសិស្សក៏មិនមានការកើនឡើង ហើយព្រះបន្ទូលនៃព្រះអម្ចាស់គឺពុំមានការផ្សព្វផ្សាយចេញទៅដូចកើតមានក្នុងពួកជំនុំដើម (កិច្ចការ ៦:៧)។ សូមមើលផែនទីម្ដងទៀតនៅទំព័រទី១៧ ហើយសូមសង្កេតមើលឆ្នាំ ដែលភ្ជាប់ជាមួយដំណើរការនៃភូមិសាស្ត្រ នៃការផ្សាយដំណឹងល្អ។

២. យើងមិនទាន់បានទទួលជោគជ័យក្នុងការបង្កើតពួកជំនុំក្នុងស្រុកពិតប្រាកដនោះទេ។ ប្រទេសជាច្រើនក្រៅពីលោកខាងលិច សេចក្ដីជំនឿគ្រីស្ទាន គឺនៅត្រូវបានចាត់ទុកជាសាសនាបរទេស ឬសាសនារបស់លោកខាងលិច។ ឧទាហរណ៍ ពីពួកជំនុំយូដាសម័យមុន ជាជនជាតិយូដា ចង់ឲ្យពួកសាសន៍ដ៏ទៃ ក្លាយទៅជាសាសន៍យូដា ដើម្បីបានចូលក្នុងនគរព្រះ។ ក្នុងពួកជំនុំលោកខាងលិចបច្ចុប្បន្ន នៅមានបេសកជនខ្លះ ដែលនៅតែមានភាពស្មោះត្រង់ ក៏ប្រហែលជាមិនមានការពិចារណា គេបានលួងលោមអ្នកជឿថ្មីឲ្យប្រែក្លាយជាពួកលោកខាងលិច ដើម្បីឲ្យបានចូលក្នុងនគរព្រះ ឬពួកជំនុំ។ (សូមមើល <u>**ការពន្យល់**</u> នៅទំព័របន្ទាប់)



**<u>ការពន្យល់</u>** ៖ កាលពីសម័យនោះប៉ុល បានប្រឆាំងដាច់ខាតអំពីការឲ្យពួកសាសន៍ដទៃត្រូវតែក្លាយជាសាសន៍យូដាជាមុនសិន ទើបអាចចូលក្នុងនគរព្រះបាន។ ទោះជាអ្វីក៏ដោយដែលបានដាក់បន្ថែម ឬប្រាសចាកពីដំណឹងល្អនៃព្រះគុណគឺសុទ្ធសឹងតែមិនត្រឹមត្រូវ។ ពីព្រោះប៉ុលបានបង្រៀនពីការនេះថា "ដោយជំនឿតែមួយគត់" ក្នុងព្រះគ្រីស្ទ ដែលអាចអនុញ្ញាតឲ្យមនុស្សម្នាក់អាចចូលទៅក្នុងនគរព្រះបាន។ លោកប៉ុល គឺមានជំហរយ៉ាងរឹងមាំទៅលើព្រះគុណ ដែលជាគ្រប់ពូជនៃដំណឹងល្អ ដែលបានចាប់ផ្តើមធ្វើការចេញទៅពីក្នុងបរិបទរបស់សាសន៍យូដា ទៅកាន់បរិបទរបស់សាសន៍ដទៃក្នុងរង្វង់រយៈពេល ២០ឆ្នាំ ទៅ៣០ឆ្នាំ (កាឡាទី ១:៦-៩) ។ បើទោះបីជាជាងរាប់រយឆ្នាំ នឹងសព្វថ្ងៃនេះ ដំណឹងល្អបានផ្សព្វផ្សាយទូទៅក្នុងបណ្តាលប្រទេសជាច្រើន ក៏ពួកជំនុំទាំងនោះ នៅតែមិនមែនជាពួកជំនុំក្នុងស្រុកនៅឡើយទេ។

បែបដូច្នេះហើយ ជាលទ្ធផលដែលបានមកពីការផ្តាច់ញ្ញាចិត្តរបស់ប៉ុលលើដំណឹងល្អនៃព្រះគុណ នោះធ្វើឲ្យមានការរីកសុះសាយនៃដំណឹងល្អយ៉ាងអស្ចារ្យពីក្រុងយេរូសាឡិមដែលជាស្រុករបស់សាសន៍យូដា ទៅដល់ដែនដីរបស់ពួកសាសន៍ដទៃ។ សូមមើលផែនទី និងកាលវេលាក្នុងទំព័រ ១៧។ ចំណែកក្នុងសម័យទំនើបនេះ មានស្ថាប័បេសកកម្មជាច្រើន ពុំមានចេតនាស្មោះត្រង់នោះទេ ដោយធ្វើការណែនាំ ឬការឲ្យជាយោបល់ទៅកាន់ពួកអ្នកជឿថ្មីៗ ថាគួរតែប្រព្រឹត្តបែបនឹងពួកជំនុំនៅលោកខាងលិច ឬបរទេស ទើបក្លាយជាពួកជំនុំពិតប្រាកដបាន។ ទោះបីជាព្រះបាន និងកំពុងបន្តប្រើប្រាស់បណ្តាបេសកកម្មទាំងនោះ ប្រាកដណាស់ទ្រឹស្តី និងវប្បធម៌របស់លោកខាងលិចនៅតែជាការរារាំងនូវសន្ទុះនៃការរីកសុះសាយរបស់ពួកជំនុំក្នុងស្រុកដ៏ធំ ជាពិសេសនៅក្នុងចំណោមមនុស្សនៅក្នុងស្រុកទី៣។

៣. បណ្តាពួកជំនុំ ឬស្ថាប័នការងារបម្រើព្រះជាច្រើននៅក្នុងស្រុកទី៣ភាគច្រើន គឺមិនអាចទ្រទ្រង់ដោយខ្លួនឯងបាននោះទេ។ ពួកគេទាំងនោះមិនអាចបំពេញតម្រូវការរបស់ខ្លួន ដូច្នេះបណ្តាឲ្យកើតមានការស្វែងរកជំនួយជាលុយកាក និងរបស់ផ្សេងៗទៀតជាបន្តបន្ទាប់។ បើគ្មានជំនួយពីបរទេស សម្រាប់ផ្គត់ផ្គង់ពួកជំនុំ ឬបេសកកម្មនោះនឹងធ្វើការទាំងនោះរលត់សូន្យទៅ ការទាំងអស់នេះហើយ សុទ្ធសឹងតែជាការភ័យខ្លាចរបស់ពួកជំនុំទាំងនេះ ហើយការនេះក៏មិនស្របតាមព្រះគម្ពីរផងដែរ។ ដូច្នេះរូបភាពខាងក្រោមជាឧទាហរណ៍ ចាប់ផ្តើមពីសហរដ្ឋអាមេរិក ទៅទ្វីបអាស៊ី រូបនេះបង្ហាញអំពីការពឹងពាក់ ឬពឹងផ្អែកទៅលើលុយ។ សម្រាប់ជាជំនួយបន្ថែមសូមអ្នកសិក្សាពីការជំនួយបន្ថែមនៅទំព័រ 202-203 "**<u>ការផ្តល់ឲ្យ និងបញ្ហាប្រាក់កាក់</u>**"



**បញ្ឈប់លុយជំនួយ = បញ្ឈប់ការងារបម្រើព្រះ ?**

នៅក្នុងរូបភាពខាងលើ បានបង្ហាញអំពីពេលដែលពួកជំនុំ ការងារ និងបេសកកម្មណាដែលបានសង់ ទាំងការភ្ជាប់គ្រឹះជាមួយនឹងលុយកាក់ នោះធ្វើឲ្យ "ចរន្តជីវិត" របស់ពួកជំនុំ ឬស្ថាប័នបេសកកម្មនោះគឺជា លុយផងដែរ។ ដូច្នេះមានន័យថា នៅពេលដែលបញ្ឈប់លុយជំនួយ គឺការងារបម្រើព្រះនឹងត្រូវបញ្ឈប់ដូចគ្នា។ លុយ អាចក្លាយទៅជាពាក្យជំនួសឲ្យ ព្រះវិញ្ញាណបរិសុទ្ធ និងបណ្តាលឲ្យអារុធដ៏ខ្លាំងពូកែរបស់ព្រះក្លាយទៅជា អស់អំណាចចេស្តា និងគ្មានភាពស័ក្តិសិទ្ធិ។ ពិតណាស់នៅពេលដែលពួកជំនុំណាបានផ្សារភ្ជាប់នឹងព្រះវិញ្ញាណបរិសុទ្ធ ពួកជំនុំនោះនឹងរីកលូតលាស់យ៉ាងលឿន ទ្រទ្រង់ដោយខ្លួនផ្ទាល់បាន និងទទួលបានអំណាចដែលសូម្បីតែទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះឡើយ (ម៉ាថាយ ១៦:១៨)។

<u>បញ្ជាក់</u> ៖ គោលបំណងតែមួយគត់សម្រាប់សៀវភៅសិក្សានេះ ដើម្បីជួយលោកអ្នកក្នុងការបែរត្រឡប់ទៅរកផ្លូវរបស់ព្រះគ្រីស្ទ ក៏ជាផ្លូវដែលព្រះវិញ្ញាណបរិសុទ្ធ ធ្វើការជាមួយពួកសាវក ទើបអាចធ្វើឲ្យពួកជំនុំបច្ចុប្បន្នរំដោះខ្លួនចេញពីការពឹងពាក់ទៅលើរបស់ ឬលុយ ឬនរណាម្នាក់ ទៅរកការប្រែក្លាយទៅជាពួកជំនុំដែលមិនអាចបញ្ឈប់បានក្នុងពិភពលោកសព្វថ្ងៃ។ ការសម្រេចចិត្តរបស់សាវកប៉ុល សម្រាប់ពួកជំនុំក្រុងថែស្សាឡូនីច គឺឲ្យពួកគេដើរក្នុងផ្លូវដែលគួរគប្បី នៅមុខមនុស្សខាងក្រៅ និង **"មិនត្រូវពឹងផ្អែកលើនរណាម្នាក់"** លើកតែព្រះវិញ្ញាណបរិសុទ្ធ (ថែស្សាឡូនីច ទី១ ៤:១២)។ សូមចាំទុកក្នុងចិត្តថា បើបងប្អូនបង្កើតពួកជំនុំតាមបែប "លោកខាងលិច" នោះបងប្អូននឹងត្រូវការលុយជាមិនខាន។

## ភាពផ្ទុយគ្នារវាងពួកជំនុំដើម និងពួកជំនុំបច្ចុប្បន្ន

<u>សូមពិភាក្សា</u> សំណួរខាងក្រោមរួមគ្នា (ប្រសិនបើអ្នកមានបងប្អូនដទៃទៀតរៀនជាមួយ) ហើយសរសេរចម្លើយរបស់អ្នកចូលទៅក្នុងចន្លោះទទេនៅខាងក្រោមសំណួរ។ សូមកុំមានការរុញរារក្នុងការចែករំលែកនូវគំនិត និងការព្រួយបារម្ភរបស់លោកអ្នកឡើយ។

១) ហេតុអ្វីភាគច្រើនពួកជំនុំសព្វថ្ងៃ ពុំមានការរីកចម្រើន និងពុំមានឥទ្ធិពលដូចនឹងពួកជំនុំដើមក្នុងការផ្សាព្វផ្សាយព្រះបន្ទូលដែលពួកគេបានធ្វើឲ្យដែនដីរបស់ពួកគេត្រូវក្រឡាបចាក់សម្រាប់ព្រះគ្រីស្ទ? ______________________________

______________________________

______________________________

______________________________

២) តើលោកអ្នកនឹងធ្វើការងារ ឬដឹកនាំពួកជំនុំរបស់លោកអ្នកបន្តដែរឬទេ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធត្រូវបានដកចេញ? តើមានការផ្លាស់ប្រែអ្វីខ្លះកើតឡើង? ______________________________

______________________________

______________________________

៣) ហេតុអ្វីបានជាពួកយើងមិនធ្វើការបង្កើតពួកជំនុំ ឬការងារបម្រើព្រះក្នុងស្រុកដែលជោគជ័យក្នុងពេលបច្ចុប្បន្ន ឲ្យដូចទៅនឹងពួកជំនុំដើម ជាសាសន៍យូដា ដែលបានធ្វើទៅក្នុងដែនដីរបស់ពួកសាសន៍ដទៃ? ______________________________

______________________________

______________________________

______________________________

៤) ហេតុអ្វីបានជាពួកជំនុំ ក្រុមបេសកកម្ម និងការងារបម្រើព្រះសព្វថ្ងៃ នៅតែមិនទាន់អាច់ទ្រទ្រង់ដោយខ្លួនផ្ទាល់បានឲ្យដូចទៅនឹងពួកជំនុំជាច្រើនដែលប៉ុលបានបង្កើត? ______________________________

*ទោះជាពួកយើងរកឃើញយ៉ាងណា ពេលវេលាបច្ចុប្បន្ននេះព្រះកំពុងតែធ្វើការដែល* ***មិនធ្លាប់មាន*** *ពីមុនមកក្នុងប្រវត្តិសាស្ត្រនៃពួកជំនុំទាំងអស់។ ពិតជាអស្ចារ្យណាស់ដែលបានរស់នៅក្នុងជំនាន់នេះ! សព្វថ្ងៃនេះមាន "ចលនាបង្កើតពួកជំនុំ" ជាច្រើនដែលអស្ចារ្យនៅជុំវិញពិភពលោក ហើយក្នុងថ្ងៃនេះ ព្រះកំពុងតែហៅលោកអ្នកមកចូលក្នុងចលនានេះ។ ជាមុនដំបូង សូមលោកអ្នកមកមើលនិយមន័យនៃ "ចលនាបង្កើតពួកជំនុំ៖"*

ចលនានៃការបង្កើតពួកជំនុំ គឺជាការបន្ថែមល្បឿនឲ្យលឿនថែមទៀតនៃការបង្កើតពួកសិស្ស និងពួកជំនុំបង្កើតពួកជំនុំនៅក្នុងស្រុក។ ចលនានេះមានដំណើរការឆ្លងកាត់តាមរយៈក្រុមគ្រួសារ ក្រុមមនុស្ស និងជាទូទៅមានការលូតលាស់ជាខ្លាំងសម្រាប់ពួកអ្នកដែលត្រូវបានផ្សាយដំណឹងល្អរួច។ មិនត្រឹមតែជាចលនាប្រវត្តិសាស្ត្រដ៏គំរូរបស់ពួកជំនុំដើម តែនៅសម័យទំនើបនេះក៏មានប្រទេសចិន ដែលបានធ្វើជាគំរូសម្រាប់យើង។ ជាច្រើនឆ្នាំមុន ហូសុន ថៃឡ័ង ( Hudson Taylor 1832-1905 ) លោកជាបេសកជនទៅកាន់ប្រទេសចិន ដើម្បីនឹងផ្សាយដំណឹងល្អទៅដល់ជនជាតិចិន ហើយមកដល់សព្វថ្ងៃនេះចលនានៃការបង្កើតពួកជំនុំនៃព្រះនៅក្នុងប្រទេសចិនមានការរីកចម្រើនយ៉ាងខ្លាំង ដោយពុំមានការផ្សំចូលគ្នានូវវប្បធម៌លោកខាងលិចឡើយ។ ឥឡូវនេះ សូមយើងមកមើលព្រះគម្ពីរវិញម្តង ពាក់ព័ន្ធនឹងពួកជំនុំ និងការរីកចម្រើននៃនគរព្រះ។

ទី១៖ ច្បាស់ណាស់សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ដែលទ្រង់ដឹងអំពីការរីកចម្រើនយ៉ាងលើសលប់ អំពីនគររបស់ទ្រង់។ ការឧទាហរណ៍មួយនៅក្នុងចំណោមឧទាហរណ៍ផ្សេងៗអំពីសេចក្តីបង្រៀននេះ គឺជាការប្រៀបប្រដូចអំពីគ្រាប់ពូជម្យ៉ាងនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១៣:៣១-៣២។ គ្រាប់ពូជម្យ៉ាងនោះ គឺមានគ្រាប់ល្អិតជាងគ្រាប់ពូជទាំងអស់ពិតមែនតែកាលណាបានដុះឡើយ នោះក៏ធំជាងតិណជាតិទាំងអស់ ហើយក៏ត្រឡប់ជាដើមធំ ដល់ម្លេះបានជាសត្វហើរលើអាកាសមកទំនៅលើមែកផង។ ជាលទ្ធផលចុងក្រោយរបស់គ្រាប់ពូជដែលល្អិតនោះ គឺជាដើមឈើយ៉ាងធំសម្បើម។

ទី២៖ ព្រះគ្រីស្ទហាក់បីដូចជាបានចង្អុលបង្ហាញប្រាប់ពី ដំណឹងល្អដែលជាគ្រាប់ពូជគឺការដាក់ចូលទៅក្នុងវប្បធម៌របស់ស្រុកនិមួយៗ ដូចយើងបានពិភាក្សាពីមុនមក។ មានបងប្អូនម្នាក់នៅប្រទេសភូមា បានប្រាប់ខ្ញុំថា ពួកយើងធ្វើការយកដើមផ្កាទាំងមូលដែលបានដាំ ដាក់ចូលក្នុងថូ ជាជាងការព្រោះពូជ។ ម៉ាថាយ ១៣:៣៣ ប្រើ "ពាក្យរូបភាព" ដោយធ្វើការប្រៀបធៀបដំណឹងល្អទៅនឹងការបង្កើតពួកជំនុំចូលទៅក្នុងវប្បធម៌ ដែលជាដំបែ ដោយយកមកលាយចូលគ្នានឹងចំនុះម្សៅយ៉ាងច្រើន។ ចំនួនម្សៅទាំងមូលដែលមាន គឺត្រូវបានទទួលឥទ្ធិពលពីដំបែយ៉ាងតូចទៅវិញ។ យើងបានពិភាក្សារួចមកហើយអំពីការកត់ត្រាទុក ដែលបានបង្ហាញនៅក្នុងកណ្ឌគម្ពីរកិច្ចការ មានពីការផ្សាយដំណឹងល្អទៅក្នុងវប្បធម៌ចម្រុះ នៅពេលដែលធ្វើចលនាឲ្យពួកជំនុំយូដាទៅក្នុងពួកជំនុំនៃសាសន៍ដទៃនៅចន្លោះពី ២០ ទៅ ៣០ឆ្នាំផងដែរនោះ។ ប៉ុន្តែបន្ទាប់ពីរយៈរាប់រយឆ្នាំមកនេះ គ្រីស្ទាននៅតែជាសាសនាលោកខាងលិច ឬបរទេសដ៏ធំនៅក្នុងតំបន់១០ ដល់៤០ (សូមមើលផែនទីទំព័រ 17) ជាតំបន់ដែលដំណឹងល្អមិនទាន់ទៅដល់ក្រុមមនុស្សនៅឡើយសព្វថ្ងៃនេះ។ នៅពេលដែលជំនឿលើព្រះគ្រីស្ទត្រូវបានចាត់ទុកជាជំនឿរបស់បរទេស ឬជាជំនឿសាសនា យើងអាចសន្និដ្ឋានបានថាការយល់ឃើញគឺបានធ្វើឲ្យដំណឹងល្អត្រូវបានរាំងស្ទះមិនឲ្យមានការលូតលាស់យ៉ាងខ្លាំង។ ដូច្នេះ តើយើងអាចធ្វើដូចម្តេចបាន? ការ

ដែលយើងអាចធ្វើបាន គឺនឹង "ពន្លឿន" ចលនានៃព្រះ និងការដែលយើងអាច ឬមិនអាចធ្វើនោះ គឺជា "ការរារាំង" ចលនានៃព្រះ។ ហើយយើងហៅការពន្លឿននោះថាជា"**អ្នកបន្ថែមល្បឿន**" និងការរារាំងនោះថាជា "**អ្នករារាំង**"។

**អ្នកបន្ថែមល្បឿន** គឺប្រៀបដូចទៅនឹងកង់ម៉ូតូ ឬឡានដែលមានខ្យល់ ពួកគេតំណាងឲ្យសកម្មភាពនៃការបង្កើតពួកជំនុំ ឬការបន្តឡើងវិញដែលមិនអាចរស់បាន ឬក៏ការពុំមានសកម្មភាពទាំងនេះទើបបណ្ដាលឲ្យបង្កើតផលផ្លែយឺតយ៉ាវ តែជាលទ្ធផល គឺការបង្កើតបាននូវពួកជំនុំរឹងមាំ ហើយនៅស្ថិតស្ថេរជាមួយនគរព្រះត្រូវបានកើតឡើងផងដែរ។ <u>**បញ្ជាក់៖**</u> **គោលបំណងមួយក្នុងចំណោមគោលបំណងទាំងអស់ក្នុងសៀវភៅណែនាំនេះគឺ ដើម្បីជួយពន្លឿនដល់ការបង្កើត និងទ្រទ្រង់ចលនាបង្កើតពួកជំនុំ តាមរយៈការប្រើប្រាស់គោលការណ៍ព្រះគម្ពីរដែលជាគោលការណ៍ចម្រុះវប្បធម៌ និងឥតពេលកំណត់។** ការនេះនឹងត្រូវបានសម្រេចជោគជ័យ ដោយការកសាងឡើងនូវផ្លូវតាមគោលការណ៍ព្រះគម្ពីរ សម្រាប់ការដំណើរការនៃចលនាបង្កើតពួកជំនុំ ក៏ស្របពេលជាមួយនឹងការដាំគ្រឹះតាមគោលការណ៍ព្រះគម្ពីរ សម្រាប់ជាចលនាដើម្បីការឈរឡើងឲ្យបានមាំមួន។

**អ្នករារាំង** គឺប្រៀបដូចជាកង់ម៉ូតូ ឬឡានដែលគ្មានខ្យល់ ពួកគេតំណាងឲ្យសកម្មភាពបង្កើត ឬការបន្តឡើងវិញរបស់ពួកជំនុំ ដែលអាចរស់បាន ហើយមានលទ្ធផលនៅក្នុងរយៈខ្លី ដល់ទីបំផុតការធ្វើការរារាំងពួកជំនុំពីការបង្កើតផលផ្លែជាបរិបូរ និងចលនានៃរីកលូតលាស់ក្នុងព្រះគ្រីស្ទក៏ពុំអាចមានលទ្ធផលបានយូរដែរ។ ជាឧទាហរណ៍នៃមនុស្សទាំងនេះអាចរកឃើញនៅក្នុងក្រុមពួកជនជាតិម៉ុង ក្នុងប្រទេសវៀតណាម និងកន្លែងជាច្រើនទៀតជុំវិញពិភពលោក។ បងប្អូនអាចរកករណីសិក្សាស្រាវជ្រាវនេះបាននៅក្នុងសៀវភៅ **ចលនានៃការបង្កើតពួកជំនុំ** និពន្ធដោយលោក ដារីឌ ហ្គារីសិន (ក្នុង www.newfoundationsinternational.org Training Resources លោកអ្នកអាចទាញយកបានដោយឥតគិតថ្លៃ)។ នៅខាងក្រោមនេះ យើងបានរៀបចំនូវតារាងពីរ មួយជាអ្នកពន្លឿន និងមួយទៀតជាអ្នករារាំង ការដែលបានរាយទាំងនេះអាចនឹងត្រឹមត្រូវ ឬមិនត្រឹមត្រូវទៅតាមវប្បធម៌របស់លោកអ្នក តែការទាំងនេះនឹងផ្ដល់ឲ្យលោកអ្នកនូវការគិតមួយ ជាស្ពានសម្រាប់យើងទាំងអស់គ្នាយកគំរូពីព្រះដែលទ្រង់ជាព្រះនៃគ្រប់ជាតិសាសន៍ និងអសកល្បមកអនុវត្តនៅក្នុងពួកជំនុំបច្ចុប្បន្ន (សូមមើល ស្ពានជ្យាក្រាម នៅទំព័រទី 30)។

## គម្រោង A "អេ" - ការកំណត់សម្គាល់ ពួកអ្នកបន្ថែមល្បឿន និងពួកអ្នករារាំង

សូមលោកអ្នកបំពេញប្រអប់នៅខាងក្រោម ដោយដាក់តាមប្រអប់ អ្នកបន្ថែមល្បឿន និងអ្នករារាំង ដែលស្រដៀងទៅនឹងស្ថានភាព និងវប្បធម៌របស់លោកអ្នក។ វានឹងជួយដល់លោកអ្នក បើលោកអ្នកអាចពិភាក្សាជាមួយអ្នកណាដែលមានសភាពប្រហាក់ប្រហែលនឹងស្ថានភាព ឬវប្បធម៌របស់លោកអ្នក។ សូមចងចាំថា ពួកអ្នកបន្ថែមល្បឿន និងពួកអ្នករារាំងនេះអាចនឹងមានការប្រែប្រួលទៅតាមពេលវេលា និងវប្បធម៌ផ្សេងៗ។ លោកអ្នកអាចសួរសំណួរខ្លួនឯងថា "តើមានអ្វីខ្លះដែលអាចនឹងធ្វើការពន្លឿន ឬរារាំងការផ្សាយដំណឹងល្អ ចលនារបស់ព្រះវិញ្ញាណបរិសុទ្ធ និងការបង្កើត ឬបន្តពួកជំនុំជាថ្មីឡើងវិញ នៅក្នុងស្រុកដែលខ្ញុំកំពុងរស់នៅ?"

| **អ្នកបន្ថែមល្បឿន** | **អ្នករារាំង** |
|---|---|
| អំណាច និងភាពគ្រប់គ្រាន់របស់ព្រះបន្ទូលព្រះ | ព្រះគម្ពីរមិនគ្រប់គ្រាន់ទេ |
| ព្រះគ្រីស្ទចម្រើនឡើង ហើយមនុស្សបន្ទាបចុះ | មនុស្សចម្រើនឡើង |
| ពួកជំនុំបង្កើតពួកជំនុំ | មានអ្នកផ្សាយដំណឹងមួយៗដាច់ដោយឡែក |
| ការបណ្តុះបណ្តាល "នៅក្នុង" ការងារបម្រើព្រះ | ការបណ្តុះបណ្តាល "សម្រាប់" ការងារបម្រើព្រះ |
| អ្នកដឹកនាំជាអ្នកក្នុងស្រុក | អ្នកដឹកនាំជាបរទេស |
| ការទ្រទ្រង់ដោយខ្លួន និងគ្មានបំណុល | ពឹងផ្អែកលើលុយ និងជំពាក់បំណុល |
| ព្រះគ្រីស្ទជាសិរសារបស់ពួកជំនុំ | គ្រូគង្វាល ឬមនុស្សជាក្បាលរបស់ពួកជំនុំ |
| មានអត្តសញ្ញានៅក្នុងស្រុក | មានអត្តសញ្ញាជាបរទេស |
| ការចាត់ឲ្យពួកសិស្ស និងពួកអ្នកដឹកនាំចេញទៅ | រក្សាទុកពួកសិស្ស និងពួកអ្នកដឹកនាំឲ្យនៅមួយកន្លែង |
| ការបៀតបៀន និងរងទុក្ខ | ភាពងាយស្រួល ភាពរីករាយ និងការកំសាន្ត |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

**នៅក្នុងថ្ងៃនេះព្រះវិញ្ញាណបរិសុទ្ធ ទ្រង់កំពុងធ្វើចលនាទៅកាន់អ្នករៀងៗខ្លួន ហើយហៅអ្នកដើម្បីចូលរួមជាមួយទ្រង់ ក៏ជាផ្នែកមួយក្នុងដំណើរបេសកកម្មដ៏ពិសេសមួយនេះរបស់ទ្រង់!**

**តើអ្នកនឹងចូលរួមជាមួយទ្រង់ឬទេ? បាន__________ ទេ__________?**

# តើគោលបំណងនៃ *ផែនការព្រះសម្រាប់ពួកជំនុំ* ជាអ្វី ?

គោលបំណងរបស់វគ្គសិក្សានេះគឺ ដើម្បីកំណត់នូវសេចក្ដីបង្រៀន និងគោលការណ៍ផ្សេងៗដែលបានប្រើប្រាស់ដោយពួកជំនុំដើម ដែលបានបង្កើតនូវលទ្ធផលយ៉ាងអស្ចារ្យក្នុងរយៈពេលដ៏ខ្លី ក៏ដើម្បីយកគោលការណ៍ទាំងអស់នោះមកធ្វើជាស្ពាននៅក្នុងពួកជំនុំបច្ចុប្បន្ន ដែលនឹងធ្វើឲ្យយើងអាចឃើញពីសិរីល្អរបស់ព្រះវរបិតាទៅលើប្រជាជននៅគ្រប់ទិសទីក្នុងពិភពលោក។

## តើពួកយើងចង់សម្រេចអ្វី នៅពេលដែលបំពេញសៀវភៅនេះចប់ទៅ?

១. **ការស្ដារឡើងវិញ** ឬបន្តជាថ្មីនូវភាពក្លាហាន និងទំនុកចិត្តនៅក្នុងអំណាច និងភាពគ្រប់គ្រាន់នៃព្រះបន្ទូល និងព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបណ្ដុះបណ្ដាល ហើយបង្កើតពួកជំនុំឲ្យមានការលូតលាស់ឡើង។

**ឈប់ ៖** មុននឹងទៅមេរៀនខាងមុខ សូមលោកអ្នកអាន **ជំនួយបន្ថែម** <u>**របៀបសិក្សាព្រះគម្ពីរ**</u> នៅទំព័រទី 192-194។





____________________________________________________________

នៅក្នុងពួកជំនុំសម័យដើម ការអភិវឌ្ឍន៍អ្នកដឹកនាំ និងរីកចម្រើនជាពហុគុណគឺសំខាន់ណាស់ ក្នុងការធ្វើឲ្យមានដំណើរការ និងឥទ្ធិពលនៅលើស្រុកតំបន់នាជំនាន់នោះ។ មោះហើយ ចូរយើងធ្វើដំណើរត្រឡប់ក្រោយ ដោយធ្វើការសង្កេតពីពួកសិស្សមុនដំបូង ដែលជាពួកអ្នកធ្វើឲ្យស្រុកពួកគេក្រឡប់ចាក់សម្រាប់ព្រះគ្រីស្ទ។ ចូរយើងចាប់ផ្ដើមពីហោរា ដែលបានរៀបចំផ្លូវថ្វាយព្រះយេស៊ូវ តើអ្នកដឹងថាគាត់ឈ្មោះអ្វី?_______។ លោកបានរៀបចំទុកមុន និងបើកបង្ហាញនូវគោលការណ៍សំខាន់ដែលជាគ្រឹះនៃប្រភេទនៃអ្នកដឹកនាំ ដែលជាអ្នកបម្រើនាសម័យពួកជំនុំដំបូង ដែលយើងចាំបាច់ត្រូវការសម្រាប់បច្ចុប្បន្ននេះ។ គោលការណ៍នៃអ្នកដឹកនាំ ដែលលើសពីគ្រប់វប្បធម៌ និងសម័យកាលរបស់លោកយ៉ូហានគឺថា ព្រះយេស៊ូវ <u>ត្រូវតែ</u> ដំកើងឡើងគ្រប់វេលា ហើយយ៉ូហាន (គឺពួកយើង) <u>ត្រូវតែ</u> ថយចុះគ្រប់វេលាវិញ (យ៉ូហាន ៣:៣០)។ បន្ទាប់ពីនោះមក តើនរណាជាសិស្សមុនដំបូងដែលព្រះយេស៊ូវបានហៅ?______ បន្ទាប់មកគាត់បានទៅហៅបងប្រុសរបស់គាត់គឺលោកពេត្រុស ហើយទើបពួកសិស្សទាំង១២ ដែលបានជ្រើសរើស និងហៅមក "ជាមួយ" ព្រះយេស៊ូវ ដូច្នេះទ្រង់អាចចាត់ឲ្យពួកគេឲ្យចេញទៅ(ម៉ាកុស ៣:១៤)។

នៅពេលដែលពួកជំនុំដំបូងក្នុងក្រុងយេរូសាឡិម រកមើលអ្នកសំខាន់ដើម្បីចាត់ទៅក្រុងអាន់ទីយ៉ូក ពួកគេបានជ្រើសរើសអ្នកដែលពេញដោយព្រះវិញ្ញាណ និងសេចក្ដីជំនឿ គាត់ឈ្មោះថា បាណាបាស ជាអ្នកដែលពេត្រុសបានបង្រៀនច្រើនជាគេ។ គឺតាមរយៈការចេញទៅរបស់បាណាបាស ទៅជួបជាមួយសាវកប៉ុល ដែលមកពីក្រុងទីរ៉ូស ក៏ជាអ្នកបានបង្កើត និងពង្រឹងពួកជំនុំអាន់ទីយ៉ូក នៅត្រង់ពេលជួបជុំនេះហើយ ដែលជាការចាប់ផ្ដើមដំណើរការនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូល។

ចាប់ផ្ដើមជាមួយព្រះយេស៊ូវហៅអនទ្រេ ហើយយើងនឹងសិក្សាតាមខ្សែស្រឡាយនៃអ្នកដឹកនាំតាមរយៈពេត្រុស និងបាណាបាស ដែលតភ្ជាប់ ឬផ្ដុំចូលគ្នាពីការរីកសុះសាយរបស់ពួកជំនុំមុនដំបូងចាប់ពីយេរូសាឡិម ទៅកាន់ពិភពលោក។ យើងនឹងសិក្សាពីរបៀបដែលអ្នកដឹកនាំពួកជំនុំ ដូចជាពួកចាស់ទុំ និងពួកសាវក ដែលផុសចេញពីពួកជំនុំ ឬគ្រួសារនៃព្រះសម្រាប់អ្នកជំនាន់ក្រោយ (ធីម៉ូថេ ទី២ ២:២)។ សូមមើលពាក្យស្លោកនេះ "**បើកអ្នកប្រាថ្នាចង់ទៅឲ្យបានលឿន កុំធ្វើដំណើរតែម្នាក់ឯង បើអ្នកប្រាថ្នាចង់ទៅឆ្ងាយ ត្រូវទៅឲ្យបានគ្នា។**" សូមសិក្សាពីដ្យាក្រាមខាងក្រោមនេះ៖



ឥឡូវចូរយើងបកទៅបទគម្ពីរនៅក្នុងមេរៀន១០-១១ និងពីរបៀបដែលអ្នកដឹកនាំបានផុសផុលឡើង និងអភិវឌ្ឍន៍ខ្លួន ហើយចាត់ឲ្យចេញទៅកាលពីសម័យពួកជំនុំដំបូង។ យើងនិងបានមើលឃើញពីរបៀបដែលពួកសាវកបានអភិវឌ្ឍន៍ពួកចាស់ទុំ និងហ្វឹកហ្វឺនពួកសាវកដ៏ទៃទៀតសម្រាប់ជំនាន់ក្រោយៗមកទៀត។

### មេរៀនទី ១០

# តួនាទីសំខាន់ៗរបស់ពួកសាវក នៅក្នុងពួកជំនុំមុនដំបូង

I. *ពួកសាវកបានផុសផុលឡើងនៅក្នុងពួកជំនុំដំបូង - កិច្ចការ ៤:៣៦ - ១១:៣០*

**ការណែនាំ៖** ចូរសរសេរឆ្លើយសម្រាប់សំនួរនៅខាងក្រោម ដោយពឹងផ្អែកតាមខគម្ពីរដែលនៅខាងចុងសំនួរ។

*ការបញ្ជាក់ពីលក្ខណៈសម្បត្តិរបស់បាណាបាស ( កិច្ចការ ៤:៣៦, ៩:២៦-២៧)*

១. តើអ្នកអាចរៀនអ្វី បានពីឈ្មោះ បាណាបាស?(៤:៣៦) ____________________

____________________

២. តើការអ្វីដែលធ្វើឲ្យអ្នកគិតថា បាណាបាសគឺជាស្រឡាញ់ព្រះអម្ចាស់ខ្លាំងណាស់?(៤:៣៧) ____________________

____________________

៣. តើតាមរយៈការអ្វី ដែលបង្ហាញថា បាណាបាសជាអ្នកនៅក្រោមអំណាចចេស្តាព្រះ?(៤:៣៧) ____________________

____________________

៤. ហេតុអ្វីបានជា បាណាបាសចាប់ដៃគូដែលល្អនៅក្នុងកិច្ចការងារបម្រើព្រះ?(៩:២៦-២៧)____________________

____________________

____________________

*បាណាបាស ត្រូវបានពួកជំនុំក្រុងយេរូសាឡិមចាត់ឲ្យចេញទៅ ( កិច្ចការ ១១:១៩ - ២៣)*

៥. ហេតុអ្វីបានជាអ្នកគិតថា ពួកជំនុំនៅក្រុងយេរូសាឡិមចាត់បាណាបាសឲ្យទៅអាន់ទីយ៉ូក?(១១:១៩-២៣)__________

____________________

____________________

៦. តើបាណាបាសបានធ្វើអ្វី នៅពេលដែលគាត់បានទៅដល់អាន់ទីយ៉ូក?(១១:២៣)____________________

____________________

*លក្ខណៈសម្បត្តិរបស់បាណាបាស សម្រាប់ការបង្កើតពួកជំនុំ ( កិច្ចការ ១១:២៤ - ២៦)*

៧. តើបាណាបាស ជាមនុស្សបែបណាដែរ?(១១:២៤)____________________

____________________

៨. តើបាណាសបានពេញដោយអ្វី យោងតាម ១១:២៤?____________ ហេតុអ្វីបានជាការពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងសេចក្ដីជំនឿមានលក្ខណៈសម្បត្តិសំខាន់សម្រាប់កិច្ចការងារបម្រើ?____________________

____________________

៩. ហេតុអ្វីបានជាលក្ខៈសម្បត្តិនៃការពេញដោយព្រះវិញ្ញាណបរិសុទ្ធគឺត្រូវបានបំភ្លេចជាញឹកញាប់សម្រាប់សព្វថ្ងៃនេះ?_____

______________________________________________

១០. បាណាបាសជាអ្នកមានពេញដោយសេចក្ដីជំនឿ តើការមានពេញដោយសេចក្ដីជំនឿមានន័យយ៉ាងដូចម្ដេច?(១១:២៤)

______________________________________________

១១. តើនរណា ដែលបាណាបាសទៅរកឲ្យជួយ?_________ ហេតុអ្វី?(១១:២៦,២៦)________________________

______________________________________________

១២. តើបាណាបាស និងប៉ុលនៅអាន់យ៉ូករយៈពេលប៉ុន្មាន?______ តើពួកគេបានធ្វើអ្វីនៅទីនោះ?(១១:២៦) ________

______________________________________________

១៣. តើពួកសិស្សត្រូវហៅជាលើកទីមួយនៅអាន់ទីយ៉ូកជាអ្វី?(១១:២៦) ____________________ ហេតុអ្វីបានជាអ្នកគិតថាពួកគេត្រូវបានហៅថាគ្រីស្ទាន?______________________________

______________________________________________

**ការពិភាក្សា៖** តើទិដ្ឋភាពអ្វី ដែលសំខាន់នៅក្នុងជីវិតរបស់បាណាបាស ដែលបានធ្វើឲ្យគាត់អាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការចាត់ទៅអាន់ទីយ៉ូក ដោយពួកជំនុំក្រុងយេរ៉ូសាឡិម?______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

ហេតុអ្វីបានជា ការសិក្សាអប់រំជារើយៗត្រូវបានលើកជាសំខាន់ជាជាងបុគ្គលិកលក្ខណៈ និងការពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងសេចក្ដីជំនឿទៅទៀត?______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

**ការចញ្ចឹកចិត្ត៖** ផ្អែកតាមខគម្ពីរ ចូរអ្នកសរសេរសង្ខេបខ្លីៗពីគោលការណ៍ និងមុនងារសំខានៗ ដែលបានមានប្រយោជន៍នៅក្នុងពួកសាវក ដើម្បីពង្រីកពួកជំនុំនាសម័យនោះ។ ______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

## II. *ពួកសាវកត្រូវបានចាត់ឲ្យទៅដោយពួកជំនុំមុនដំបូង - កិច្ចការ ១៣:១ - ១៤:២៧*

### *ពួកសាវកបានអភិវឌ្ឍន៍ និងបង្ហាត់បង្រៀនរួចហើយ មុនចាត់ឲ្យចេញទៅ* (*កិច្ចការ ១៣:១ -៤*)

១. តើនរណាខ្លះ ជាអ្នកដឹកនាំ គ្រូអធិប្បាយ និងគ្រូបង្រៀន នៅក្នុងពួកជំនុំអាន់ទីយ៉ូក?(១៣:១)

២. តើអ្នកគិតថាអ្នកដឹកនាំទាំងនេះ បានបង្ហាត់បង្រៀននៅទីកន្លែងណា?(១៣:១)

៣. តើអ្នកគិតថានរណា ជាអ្នកដឹកនាំសំខាន់២នាក់ នៅក្នុងក្រុមនេះ?(១៣:១-២)

៤. តើពួកគេបានធ្វើអ្វី នៅពេលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលទៅពួកគេ?(១៣:២)

៥. តើនរណា ជាអ្នកចាត់បាណាបាស និងប៉ុលចេញ?(១៣:២-៤)

៦. តើនរណាខ្លះ ដែលបានចូលរួមក្នុងដំណើរការចាត់ចេញទៅនេះ?(១៣:១-៤)

៧. ចូររៀបរាប់អំពីដំណើរការនៃការចាត់ចេញទៅតាមលំដាប់លំដោយ។ (១៣:១-៤)

### *ពួកសាវកបានមានយុទ្ធសាស្ត្រ* (*កិច្ចការ ១៤:២១ -២៧*)

៨. តើការទីមួយដែលពួកសាវកបានធ្វើជាអ្វី នៅពេលពួកគេទៅដល់ទីក្រុង?(១៣:៣២, ៣៨, ១៤:៦-៧, ១៥, ២១)

៩. តើការប្រកាសដំណឹងល្អរបស់ពួកសាវក ទទួលបានលទ្ធផលយ៉ាងដូចម្ដេច?(១៤:២១)

១០. ហេតុអ្វីបានជាពួកសាវកវិលត្រឡប់ទៅឯលីស្ត្រា អ៊ីកូនាម និងអាន់ទីយ៉ូកវិញ?(១៤:២២)

១១. តើពួកសាវកបានរើសតាំងឡើងនរណា នៅក្នុងគ្រប់ទាំងពួកជំនុំ?(១៤:២៣)

១២. តើពួកគេរើសតាំងពួកចាស់ទុំដោយរបៀបណា?(១៤:២៣)

១៣. តើពួកសាវកបានប្រគល់ពួកគេឲ្យទៅនរណា?(១៤:២៣)

១៤. តើពួកសាវកបានវិលត្រឡប់ទៅទីណា នៅពេលពួកគេបានបញ្ចប់ដំណើរបេសកកម្មរបស់ខ្លួន? ហេតុអ្វី?(១៤:២៦-២៧)

**<u>ការឆ្លុះគំនិត៖</u>** ផ្អែកតាមខគម្ពីរ ចូរអ្នកសរសេរសង្ខេបខ្លីៗពីគោលការណ៍ និងមុនងារសំខានៗ ដែលបានមានប្រយោជន៍នៅក្នុងពួកសាវក ដើម្បីអភិវឌ្ឍន៍ពួកជំនុំនាសម័យនោះ។

**<u>ការអនុវត្ត៖</u>** តើអ្នកនឹងធ្វើការឆ្លុះបញ្ចាំងនូវគោលការណ៍ទាំងនេះនៅពេលណា និងដោយរបៀបណា?

## III. ពួកសាវកអភិវឌ្ឍន៍ពួកចាស់ទុំនៅក្នុងពួកជំនុំដំបូង - កិច្ចការ ២០:១៧ - ៣៨

### *យុទ្ធសាស្ត្រហ្វឹកហ្វឺនរបស់ប៉ុល សម្រាប់ពួកចាស់ទុំ ( កិច្ចការ ២០:១៧ -២៦)*

១. តើប៉ុលរស់នៅទីណាក្នុងទីក្រុងអេភេសូ ?(២០:១៨) ______

២. តើប៉ុលបានបម្រើពួកជំនុំអេភេសូដោយរបៀបណា ?(២០:១៩) ______

______

៣. តើប៉ុលបានប្រាប់សេចក្តីអ្វី ទៅពួកគេ ?(២០:២០) ______

______

៤. តើប៉ុលបានបង្រៀនពួកគេ នៅទីណា ?(២០:២០) ______

______

៥. តើប៉ុលបានធ្វើបន្ទាល់ពីអ្វី? (២០:២១) ______

______

៦. តើប៉ុលមិនឲ្យតម្លៃទៅលើអ្វី ?______ ហេតុអ្វីបានលោកមិនឲ្យតម្លៃលើជីវិតរបស់ខ្លួនដូច្នេះ ?(២០:២៤)______

______

៧. តើគោលបំណងនៃការងារបម្រើរបស់ប៉ុល ជាអ្វី ?(២០:២៤) ______

______

### *សេចក្តីបង្រៀនរបស់ប៉ុល ទៅពួកចាស់ទុំ ( កិច្ចការ ២០:២៧ -៣២)*

៨. តើប៉ុលបានប្រាប់អ្វីទៅពួកគេ ?(២០:២៧) ______

______

៩. តើប៉ុលប្រាប់ពួកគេឲ្យប្រុងប្រយ័ត្នមុនគេជានរណា ?(២០:២៨) ______

______

១០. តើពួកជំនុំត្រូវបានលោះមកដោយអ្វី ?(២០:២៨) ______

ដូច្នេះ តើនរណាជាម្ចាស់នៃពួកជំនុំ ? ______

១១. តើនរណា នឹងមកក្នុងពួកជំនុំបន្ទាប់ពីប៉ុលចាកចេញ ?(២០:២៩) ______

១២. តើពួកគេនឹងធ្វើអ្វី ទៅដល់ពួកជំនុំ ?(២០:៣០) ______

______

១៣. តើឆ្កែព្រៃដ៏សាហាវ ពួកវាមកពីណា ?(២០:៣០) ______

១៤. តើប៉ុលបានប្រដៅទូន្មានអ្វីខ្លះ ដល់ពួកចាស់ទុំ ?(២០:៣១) ______

១៥. តើប៉ុលបានប្រដៅទូន្មានពួកចាស់ទុំ ដោយរបៀបណា ?(២០:៣១) ______

______

១៦. តើប៉ុលទុកចិត្តផ្ញើ និងទូន្មានពួកគេឲ្យទៅនឹងនរណា ?(២០:៣២) ______

______

### *គំរូរបស់ប៉ុល សម្រាប់ពួកចាស់ទុំ (កិច្ចការ ២០:៣៣-៣៥)*

១៧. តើប៉ុលមិនដែលចង់បានអ្វី?(២០:៣៣, ៣៤) ______________________________

១៨. ហេតុអ្វីបានជាអ្នកប្រាកដថា ប៉ុលបានធ្វើការ?(២០:៣៤) ______________________________

______________________________

**ចំណាំ៖** សូមមើលជំនួយបន្ថែម **<u>ការផ្គត់ផ្គង់ជំនួយសម្រាប់អ្នកបង្កើតពួកជំនុំ</u>** ទំព័រ 216។

១៩. តើប៉ុលបានបង្ហាញអ្វី ទៅពួកគេតាមការធ្វើការ និងហេតុអ្វី?(២០:៣៥) ______________________________

______________________________

### *ទំនាក់ទំនងរបស់ប៉ុល នឹងពួកចាស់ទុំ (កិច្ចការ ២០:៣៦-៣៨)*

២០. តើប៉ុលបានធ្វើអ្វីជាមួយពួកចាស់ទុំ នៅពេលគាត់ចាកចេញទៅពីពួកគេ?(២០:៣៦) ______________________________

______________________________

២១. ពិពណ៌នាអំពីទំនាក់ទំនងរបស់ប៉ុល នឹងពួកចាស់ទុំ។ (២០:៣៧-៣៨) ______________________________

______________________________

**<u>ការពិភាក្សា៖</u>** តើប៉ុលបាននៅជាមួយពួកជំនុំអេភេសូប៉ុន្មានឆ្នាំ?________ នៅពេលនោះគឺគ្មានគ្រឹះស្ថានហ្វឹកហ្វឺននោទេ តើប៉ុលបានបង្ហាត់បង្រៀនពួកចាស់ទុំ ឬអ្នកគង្វាលនៅក្នុងអេភេសូ និងពួកជំនុំដំបូងដោយរបៀបណា?______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

ហេតុអ្វីបានជាការហ្វឹកហ្វឺនបែបជាគ្រឹះស្ថាន និងបែងចែកកម្រិតត្រូវបានចាត់ទុកថា គួរទទួលយក និងជាជម្រើសសម្រាប់ពេលបច្ចុប្បន្ន ជាជាងការបង្កើតទំនាក់ទំនង ក៏ដូចជាការបង្រៀនផ្ទាល់ជាមួយនឹងក្រុមគ្រួសារពួកជំនុំយ៉ាងដូច្នេះ?

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

## IV. *ពួកសាវកអភិវឌ្ឍន៍ពួកសាវកដទៃទៀត - កិច្ចការ ១៦:១ - ២០:៣១, ធីម៉ូថេ ទី១ និង២, ទីតុស*

**ចំណាំ៖** សូមមើលជំនួយបន្ថែម **ការរៀបរាប់តាមព្រះគម្ពីរ អំពីកិច្ចការងារបម្រើរបស់អ្នកបង្កើតពួកជំនុំ** ទំព័រ 212

### *ប៉ុលជ្រើសរើសពួកសិស្ស ជាអ្នកបានបង្ហាត់បង្រៀន និងសាកល្បង នៅក្នុងពួកជំនុំ (កិច្ចការ ១៦:២ -៥)*

១. តើសិស្សដែលប៉ុលបានជួបនៅលីស្ត្រានោះមានឈ្មោះអ្វី?(១៦:១) ____________________

២. តើសេចក្ដីជំនឿដំបូងរបស់ធីម៉ូថេរស់នៅឯណា?(២ធីម៉ូថេ ១:៥) ____________________

៣. ហេតុអ្វីបានជាអ្នកគិតថា ប៉ុលជ្រើសរើសធីម៉ូថេ?(កិច្ចការ ១៦:២) ____________________

____________________

៤. តើប៉ុលចង់ធ្វើអ្វី ជាមួយនឹងធីម៉ូថេ?(១៦:៣) ____________________

____________________

៥. តើប៉ុលបានបង្រៀបធីម៉ូថេ ដោយរបៀបណា?(១៦:៣-៤) ____________________

____________________

៦. តើដំណើរការបង្ហាត់បង្រៀននេះ ទទួលបានលទ្ធផលយ៉ាងដូចម្ដេច?(១៦:៥) ____________________

____________________

### *ប៉ុលបានកសាងក្រុម ដើម្បីជាជំនួយសម្រាប់គាត់ (កិច្ចការ ១៨:២៤ -២៨, ២០:៤)*

៧. តើនរណាខ្លះ ដែលជាអ្នកជំនួយសម្រាប់ប៉ុល?(១៨:២៤-២៨, ២០:៤) ____________________

____________________

____________________

៨. តើពួកគេបង្រៀនក្នុងសេចក្ដីបង្រៀនត្រឹមត្រូវ ដោយរបៀបណា?(១៨:២៤-២៦) ____________________

____________________

____________________

៩. ពិពណ៌នាអំពីប្រសិទ្ធភាពក្នុងការងារនៃព្រះបន្ទូលព្រះ?(១៨:២៧-២៨) ____________________

____________________

____________________

១០. តើរវាងការបង្រៀន ***សម្រាប់*** ការងារបម្រើ និងការបង្រៀន ***នៅក្នុង*** ការងារបម្រើមានភាពខុសគ្នាយ៉ាងដូចម្ដេច?(កិច្ចការ ២០:៤, ១៨, ៣១) ____________________

____________________

____________________

____________________

១១. តើព្រះយេស៊ូវបានបង្រៀន ឬអភិវឌ្ឍន៍ពួកសិស្សទ្រង់ដើម្បីចាត់ចេញទៅ ដោយរបៀបណា?(ម៉ាកុស ៣:១៤)________

____________________

*ការទូន្មានរបស់ប៉ុលបានរៀបរាប់អំពីអត្តចរិតរបស់ធីម៉ូថេ និងទីតុស (ធីម៉ូថេ ទី១ ទី២ និង ទីតុស)*

១២. ចូរធ្វើការរំលឹកឡើងវិញ (ធីម៉ូថេ ទី១ ទី២ និងទីតុស) ហើយរាយនូវពាក្យមួយចំនួន ដែលប៉ុលបានប្រើ ដើម្បីរៀបរាប់ពីបុគ្គលិកលក្ខណៈនៃអ្នកដឹកនាំ។ ______

១៣. ចូរត្រឡប់ទៅក្រោយ ដោយមើលពីបុគ្គលិកលក្ខណៈរបស់បាណាបាស (ចំនុចទី១ ទំព័រ ៧៦) ហើយចូររាយនូវបុគ្គលិកលក្ខណៈរបស់បាណាបាសទៅតាមដែលអាចធ្វើបាន។ លោកអ្នកនឹងនឹកប្លែកអំពីគាត់ ដែលបានមាននៅក្នុងព្រះគម្ពីរ។ ______

*ប៉ុលបានប្រើពួកសិស្ស ដើម្បីបង្កើតពួកជំនុំដែលមានរួចហើយ (ទីតុស)*

១៤. ហេតុអ្វីបានជាប៉ុល ទុកទីតុសនៅកោះក្រេត?(១:៥) ______

១៥. តើពាក្យថា "នឹងរៀបចំការ" មានន័យយ៉ាងដូចម្តេច?(១:៥-៩) ______

១៦. តើប៉ុលបានប្រាប់ទីតុសឲ្យបង្រៀនពីអ្វី?(២:១) ______

១៧. ពិពណ៌នាអំពីន័យពាក្យដែលប៉ុលនិយាយថា "បង្រៀនសេចក្តីត្រឹមត្រូវ"។ ______

**<u>ការពិភាក្សា៖</u>** ហេតុអ្វីបានជាបុគ្គលិកលក្ខណៈមានសារៈសំខាន់នៅក្នុងការងាររបស់អ្នកដឹកនាំ ដោយយោងតាម ធីម៉ូថេ ទី២ ២:២០-២២? ______

ហេតុអ្វីបានពួកជំនុំសព្វថ្ងៃនេះ ចូលចិត្តផ្តុកផ្តាក់លើការសិក្សាអប់រំ និងស្ថានភាពជាក់ស្តែង លើសជាងបុគ្គលិកលក្ខណៈទៅវិញ? ______

## V. *ការបង្ហឹកបង្រៀនពួកសាវក គឺសម្រាប់អ្នកជំនាន់ក្រោយ - (ធីម៉ូថេ ទី២)*

### *បង្រៀនអ្នកដែលស្មោះត្រង់ (ធីម៉ូថេ ទី២ ២:២)*

១. តើមនុស្សប្រភេទណា ដែលសាកសមនឹងទុកចិត្តទៅតាមការបង្រៀនរបស់ប៉ុល?(២:២) ____________________

____________________________________________________________

២. តើពួកគេគួរតែអាចនឹងធ្វើអ្វី?(២:២) ____________________

ហេតុអ្វីបានការដែលពួកគេអាចបង្រៀនអ្នកដ៏ទៃ មានសារសំខាន់? ____________________

____________________________________________________________

### *កិច្ចការរបស់ធីម៉ូថេ (ធីម៉ូថេ ទី២ ៤:១-៥)*

៣. តើប៉ុលបានផ្តាំធីម៉ូថេឲ្យធ្វើអ្វី?(៤:១-២) ____________________

____________________________________________________________

____________________________________________________________

ហេតុអ្វីការផ្តាំនេះមានសារៈសំខាន់?(៤:៣-៥) ____________________

____________________________________________________________

### *ការចាកចេញរបស់ប៉ុល (ធីម៉ូថេ ទី២ ៤:៦-១៨)*

៤. តើប៉ុលយល់យ៉ាងដូចម្តេច អំពីជីវិត អតីតកាល របស់គាត់?(៤:៦-៧) ____________________

____________________________________________________________

៥. តើប៉ុលយល់ឃើញយ៉ាងដូចម្តេច អំពីជីវិត អនាគត របស់គាត់?(៤:៨) ____________________

____________________________________________________________

៦. តើសិស្សរបស់ប៉ុល ដេម៉ាស មានរឿងអ្វី?(៤:៩-១០) ____________________

____________________________________________________________

៧. បន្ទាប់ពីមានរឿងកើតឡើងនៅក្នុងកិច្ចការ ១៥:៣៧-៤០ ហេតុអ្វីបានជាប៉ុល ឲ្យនាំម៉ាកុសមកជាមួយ?(៤:១១) ______

____________________________________________________________

៨. តើប៉ុលដោះស្រាយនិងអ័លេក្សានត្រុសដោយរបៀបណា?(៤:១៤-១៥) ____________________

**ការពិភាក្សា៖** ហេតុអ្វីបានជាការបង្ហឹកបង្រៀនអ្នកដឹកនាំដ៏ស្មោះត្រង់មានសារៈសំខាន់ ក្នុងការដែលពួកគេបង្ហឹកបង្រៀនអ្នកដឹកនាំដ៏ស្មោះត្រង់ដ៏ទៃទៀត?____________________

____________________________________________________________

**ការអនុវត្ត៖** តើអ្នកកំពុងតែបង្ហឹកបង្រៀនសិស្សដែលស្មោះត្រង់ ដែលជាអ្នកអាចបង្ហឹកបង្រៀនអ្នកឯទៀតដែរឬទេ? បាទ ឬក៏អត់ទេ ព្រោះអ្វី? បើអត់ តើអ្នកនឹងប្តេជ្ញាចិត្តក្នុងអធិស្ឋាន ហើយស្វែងរកធីម៉ូថេ ដែលអ្នកអាចបង្ហឹកបង្រៀនបានដែរឬទេ? ___

____________________________________________________________

____________________________________________________________

**មេរៀនទី ១១**

# ព្រះត្រាស់ហៅអ្នកដឹកនាំសំខាន់ៗ

## I. *ព្រះជ្រើសរើសអ្នកដឹកនាំដែលជាមនុស្សធម្មតា*

ព្រះមិនដែលត្រាស់ហៅ ឬជ្រើសរើសអ្នកដឹកនាំដោយផ្អែកលើកម្រិត ឬស្តង់ដារបស់លោកីយនេះឡើយ។ រឿងដែលគួរឲ្យចាប់អារម្មណ៍នោះគឺ នៅពេលព្រះយេស៊ូវជ្រើសរើសសិស្សទាំង១២ សម្រាប់នឹងទទួលភារកិច្ចដែលសំខាន់របស់ព្រះវរបិតាទ្រង់ ពោលគឺទ្រង់មិនជ្រើសរើសអ្នកដឹកនាំចេញពីមនុស្សដែល "កើតចេញពីទំនៀមទម្លាប់សាសនា" នោះទេ។ ដើម្បីឲ្យកាន់តែច្បាស់ នៅក្នុងគ្រប់ផ្នែកនៃព្រះគម្ពីរ វិធីដែលព្រះអាទិករធ្វើការជ្រើសរើសអ្នកដឹកនាំគឺមានភាពខុសគ្នាខ្លាំងណាស់ បើប្រៀបទៅនឹងវិធីរបស់មនុស្ស ហើយនិងលោកីយនេះ។

១. តើពួកបងប្អូនប្រភេទណា ដែលព្រះមិនបានត្រាស់ហៅ យោងតាម ១កូរិនថូស ១:២៦? ____________________

____________________________________________

២. តើព្រះទ្រង់ហៅនរណា យោងតាម ១កូរិនថូស ១:២៧-២៨? ____________________

____________________________________________

____________________________________________

៣. ហេតុអ្វីបានជាព្រះទ្រង់ជ្រើសរើស និងត្រាស់ហៅមនុស្សប្រភេទទាំងនេះមក យោងតាម ១កូរិនថូស ១:២៩?__________

____________________________________________

៤. តើគេឌានបានធ្វើអ្វី នៅពេលទេវតានៃព្រះអម្ចាស់លេចមកឯគាត់ ក្នុងពួកចៅហ្វាយ ៦:១១? ____________________

____________________________________________

៥. តើគេឌានបានធ្វើការឆ្លើយតបយ៉ាងដូចម្តេច ទៅនឹងការត្រាស់ហៅរបស់ព្រះ យោងតាមពួកចៅហ្វាយ ៦:១៥? ________

____________________________________________

____________________________________________

៦. តើព្រះបានឆ្លើយតបទៅគេឌានវិញយ៉ាងដូចម្តេច យោងតាមពួកចៅហ្វាយ ៦:១៦? ____________________

____________________________________________

៧. ហេតុអ្វីបានជាមនុស្សត្រឹមតែ ៣២,០០០នាក់គឺច្រើនក្នុងការប្រយុទ្ធជាមួយមនុស្សរយពាន់អ្នករបស់ពួកម៉ាឌានដូច្នេះ យោងតាមពួកចៅហ្វាយ ៧:២?____________________

____________________________________________

៨. តើព្រះបានទុកមនុស្សចំនួនប៉ុន្មាននាក់សម្រាប់គេឌាន ដើម្បីចេញទៅប្រយុទ្ធនឹងម៉ាឌាន យោងតាមពួកចៅហ្វាយ ៧:៧? _

____________________________________________

៩. តើម៉ូសេបានប្រើលេះអ្វីខ្លះ ក្នុងការឆ្លើយតបពីការត្រាស់ហៅរបស់ព្រះ យោងតាមនិក្ខមនំ ៣:១១, ៤:១, ១០, ១៣? ______

____________________________________________

____________________________________________

១០. តើព្រះបានឆ្លើយតបទៅកាន់ម៉ូសេយ៉ាងដូចម្ដេចខ្លះ យោងតាមនិម្ខនំ ៣:១២, ៤:១១, ១២? ________________

______________________________________________

______________________________________________

______________________________________________

១១. ហេតុអ្វីបានជាព្រះរើសដាវីឌ ជាក្មេងគង្វាលម្នាក់ ហើយក៏មិនមែនជាកូនច្បងរបស់អ៊ីសាយទៀត យោងតាម ១សាំយូអែល ១៦:៦-១៣? ________________________________

______________________________________________

______________________________________________

១២. តើការត្រាស់របស់ព្រះ និងការត្រាស់របស់មនុស្សមានភាពខុសគ្នាយ៉ាងដូចម្ដេចខ្លះ (១សាំយូអែល ១៦:៧)? ______

______________________________________________

______________________________________________

១៣. តើពួកចាស់ទុំ ពួកអាចារ្យ និងពួកសង្ឃគិតយ៉ាងណា ចំពោះពេត្រុស និងយ៉ូហាន ក្នុងកិច្ចការ ៤:១៣? __________

______________________________________________

១៤. តើពួកគេបានទទួលស្គាល់ (បានយល់ឃើញ) អំពីពេត្រុស និងយ៉ូហានអំពីថាជាអ្វី ក្នុងកិច្ចការ ៤:១៣? __________

______________________________________________

**ការពិភាក្សា៖** តើលោកអ្នកនៅគិតថាព្រះទ្រង់រើស "អ្នកដឹកនាំដែលជាមនុស្សធម្មតា" ឬទេសព្វថ្ងៃ? ______________

______________________________________________

______________________________________________

______________________________________________

ហេតុអ្វីបានជាអ្នកគិតថា ព្រះរើសមនុស្សល្ងង់ មនុស្សទន់ខ្សោយ ទន់ទាប និងអ្នកគេបោះបង់ចោល?______________

______________________________________________

______________________________________________

______________________________________________

**ការអនុវត្ត៖** ហេតុអ្វីបានជាអ្នកគិតថា ព្រះបានត្រាស់ហៅអ្នក? ______________________________

______________________________________________

______________________________________________

______________________________________________

តើអ្នកសម្រេចពីគោលបំណងនៃការត្រាស់ហៅរបស់អ្នក ដោយរបៀបណា?______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

## II. *ព្រះល្បងលអ្នកដឹកនាំដែលខ្លាំង*

នៅក្នុងបទគម្ពីរយើងមើលឃើញអំពីអ្នកដឹកនាំដែលខ្លាំងៗជាច្រើន ដែលព្រះបានប្រើ ក៏ជាអ្នកដែលត្រូវបានសាកល្បង និងបានបញ្ជាក់រួចរាល់។ តាមរយៈការធ្វើ និងចំនេះដឹងគឺ មិនអានផ្លាស់ប្តូរនឹងការសាកល្បង សម្រាប់តែភាពបរិសុទ្ធ ចេស្តា និងការមានប្រយោជន៍សម្រាប់ថ្វាយទ្រង់នោះឡើយ។ យ៉ាងណាមិញ ពួកយើងមានអំណរក្នុងការសាកល្បងរបស់យើង ក៏ពីក្នុងភាពទន់ខ្សោយរបស់យើងផងដែរ ដែលពួកយើងនឹងមានពិសោធន៍ដែលមានចេស្តា ភាពបរិសុទ្ធ និងជាប្រយោជន៍លើសជាងមុន ដែលសម្រាប់ថ្វាយសិរីល្អព្រះ។

១. តើមានអ្វីដែលមកសណ្ឋិតលើព្រះយេស៊ូវ បន្ទាប់ពីទ្រង់ទទួលបុណ្យជ្រមុជទឹក យោងតាមម៉ាថាយ ៣:១៦? ___________

___________________________________________

២. តើនៅពេលនោះ បន្ទាប់ពីជ្រមុជទឹករួច ព្រះវិញ្ញាណបរិសុទ្ធបាននាំព្រះយេស៊ូវទៅឯណា (ម៉ាថាយ ៤:១)? ___________

___________________________________________

ហេតុអ្វី? ___________________________________________

៣. ក្រោយដែលព្រះយេស៊ូវបានផុតពីពេលល្បងល្អនៅក្នុងវាលរហោស្ថានរួច តើទ្រង់ចាប់ផ្តើមធ្វើអ្វី យោងតាមម៉ាថាយ ៤:១៧? ___________________________________________

៤. ម៉ូសេបានរស់នៅសរុប១២០ឆ្នាំ។ បន្ទាប់ពីលោកបានចំរើនវ័យរយៈពេល៤០ឆ្នាំដំបូងនៅក្នុងអេស៊ីព្ទ តើម៉ូសេបានប្រែជាអ្វី យោងតាមនិក្ខមនំ ២:១០? ___________________________________________

៥. តើម៉ូសេបានប្រើពេល៤០ឆ្នាំបន្ទាប់នៅឯណា យោងតាមនិក្ខមនំ ២:១៥? ___________________

ហេតុអ្វី? ___________________________________________

៦. តើលោកបានធ្វើអ្វីខ្លះ អំឡុងពេលនៅក្នុងទីរហោស្ថាន យោងតាមនិក្ខមនំ ៣:១? ___________________

___________________________________________

៧. នៅពេលលោកបានឆ្លងកាត់ "ការសាកល្បងលើវាលខ្សាច់" តើម៉ូសេបានចំណាចពេល៤០ឆ្នាំរបស់គាត់យ៉ាងដូចម្តេច (និក្ខមនំ ៣:១០)? ___________________________________________

___________________________________________

៨. តើពេត្រុសបាននិយាយយ៉ាងដូចម្តេច នៅពេលព្រះយេស៊ូវបានប្រាប់ពួកគេថា "ពួកគេនឹងរវាតចិត្ត" (ម៉ាកុស ១៤:២៦-៣១)? ___________________________________________

___________________________________________

៩. តើមានអ្វីកើតឡើង នៅពេលពេត្រុសបានធ្លាក់ការសាកល្បងរបស់គាត់ យោងតាមម៉ាកុស ១៤:៧២? ___________

___________________________________________

១០. តើមានលទ្ធផលយ៉ាងដូចម្តេច ពីការទ្រាំទ្រក្នុងការសាកល្បងរបស់ពេត្រុស យោងតាមកិច្ចការ ២:៣៨-៤១? ________

___________________________________________

___________________________________________

___________________________________________

១១. តើពួកថែស្សាឡូនីចបានទទួលព្រះបន្ទូលយ៉ាងដូចម្តេច យោងតាម ១ថែស្សាឡូនីច ១:៦? ___________________

___________________________________________

១២. តើលទ្ធផលនៃការសាកល្បង ឬទុក្ខវេទនារបស់ពួកគេជាអ្វី យោងតាម ១ថែស្សាឡូនីច ១:៧-៨? ____________________

១៣. ហេតុអ្វីបានប៉ុលត្រូវបានសាកល្បង យោងតាម ២កូរិនថូស ១២:៧? ____________________

១៤. ចូរពិពណ៌នាអំពី "បន្លា" របស់ប៉ុលដែលបានមានដល់គាត់។ (២កូរិនថូស ១២:៧) ____________________

១៥. ជំនួសពីមកដកចេញនូវ "បន្លា" តើព្រះអម្ចាស់ប្រទានអ្វីទៅដល់ប៉ុល (២កូរិនថូស ១២:៩)? ____________________

១៦. តើអ្វី ដែលធ្វើឲ្យកំឡាំងនៃព្រះបានពេញខ្នាតនៅក្នុងអ្នកជឿគ្រប់គ្នា (២កូរិនថូស ១២:៩)? ____________________

១៧. ដូច្នេះហើយ ហេតុអ្វីបានប៉ុលអួតអំពីសេចក្តីកំសោយរបស់គាត់ទៅវិញ (២កូរិនថូស ១២:៩)? ____________________

១៨. ចុះ តើការអ្វីខ្លះ ដែលធ្វើឲ្យប៉ុលបានពេញចិត្ត និងអរសប្បាយនៅក្នុង យោងតាម ២កូរិនថូស ១២:១០? ____________________

**ការពិភាក្សា៖** ហេតុអ្វីបានជាអ្នកគិតថា ព្រះទ្រង់សាកល្បងពួកអ្នកដឹកនាំរបស់ទ្រង់ ដែលជាអ្នកដឹកនាំជាអ្នកបម្រើទៅវិញ? ____________________

**ការអនុវត្ត៖** តើអ្នកធ្លាប់បានសាកល្បងពីមកឬទេ? ________ តើការនោះបានរៀបចំអ្នកសម្រាប់ការងារបម្រើឬទេ? ______ តើការទាំងនោះបានរៀបចំអ្នកយ៉ាងដូចម្តេចខ្លះ? ____________________

## III. *ព្រះទ្រង់រៀបចំអ្នកដឹកនាំឲ្យមានប្រសិទ្ធិភាព*

លោកប៉ុល មានមនុស្សសំខាន់ៗនៅជុំវិញខ្លួនគាត់ ដែលអ្នកទាំងនោះជាអ្នករួមចំណែកក្នុងការជោគជ័យក្នុងការនាំដំណឹងល្អទៅសាសន៍ដទៃ។ មនុស្សគ្រប់រូប ដែលព្រះបាននាំមកក្នុងជីវិតរបស់ប៉ុលគឺ មានប្រយោជន៍នឹងសម្រាប់ជាយុទ្ធសាស្ត្រក្នុងការសំលៀងគ្រូនៃអ្នកបង្កើតពួកជំនុំ និងអ្នកដឹកនាំនៃព្រះនេះឯង។ ចំពោះអ្នកវិញក៏ដូចគ្នា អ្នកនឹងត្រូវការមនុស្សបែបនេះនៅក្នុងជីវិតរបស់អ្នក ដើម្បីនឹងសំរួចពីការបង្កើតពួកជំនុំ និងការផ្លាស់ប្រែជាថ្មីរបស់អ្នកឲ្យទទួលបានជោគជ័យ។

១. តើអ្នកគិតយ៉ាងដូចម្តេច អំពីការដែលព្រះបានប្រើទីបន្ទាល់នៃការអត់ទោសបាបរបស់ស្ទេផាន នៅក្នុងការប្រែចិត្តរបស់ប៉ុលយោងតាម កិច្ចការ ៧:៥៨-៦០? ______________________________

______________________________

______________________________

២. តើតួនាទីអ្វីខ្លះ របស់បាណាបាស ដែលអ្នកគិតថាបានដើរនៅក្នុងជីវិតរបស់ប៉ុល យោងតាម កិច្ចការ ៩:២៦-២៧, ១១:២៥-២៦? ______________________________

______________________________

៣. តើតួនាទីរបស់ធីម៉ូថេ និងការចូលរួមរបស់គាត់ នៅក្នុងជីវិតរបស់ប៉ុលមានអ្វីខ្លះ យោងតាម ២ធីម៉ូថេ ២:២? __________

______________________________

______________________________

៤. តើតួនាទីរបស់ម៉ាកុសអ្វីខ្លះ ដែលបានដើរនៅក្នុងជីវិត និងការងាររបស់ប៉ុល យោងតាម ២ធីម៉ូថេ ៤:១១? __________

______________________________

៥. តើអ្នកគិតយ៉ាងដូចម្តេច ដែលម៉ាកុសមានប្រយោជន៍សម្រាប់ប៉ុល តាំងពីធ្លាប់បែកគ្នាមក? __________

______________________________

៦. យើងដឹងហើយថាលូកា ជាអ្នកនិពន្ធគម្ពីរកិច្ចការ ប៉ុន្តែតើមានហេតុផលផ្សេងឬទេ ដែលអ្នកគិតថាប៉ុលមានជាមួយលូកា យោងតាម ២ធីម៉ូថេ ៤:១១? ______________________________

______________________________

៧. តើទីតុសបានយ៉ាងជួយប៉ុលយ៉ាងដូចម្តេចខ្លះ យោងតាម ២ធីម៉ូថេ ៤:១០ និងទីតុស ១:៥? __________

______________________________

______________________________

៨. ក្នុង ២ធីម៉ូថេ ហេតុអ្វីបានជាប៉ុលលើកពីឈ្មោះដេម៉ាស ក្នុងពាក្យចុងក្រោយរបស់គាត់ទៅកាន់ធីម៉ូថេយ៉ាងដូច្នេះ? ______

______________________________

តើអ្នកធ្លាប់មានសិស្សណាម្នាក់ ដែលបានចាកចេញ ហើយត្រឡប់ទៅលោកីយវិញឬទេ? __________
តើការនេះបានធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេច? ______________________________

______________________________

៩. លើសពីនេះទៅទៀត ក្នុង ២ធីម៉ូថេ ៤:១៤-១៥ ហេតុអ្វីបានជាប៉ុលលើកពីឈ្មោះអ័លេក្សានគ្រុស? __________

______________________________

តើអ្នកធ្លាប់មានមនុស្សបែបអ័លេក្សានត្រុសក្នុងជីវិតរបស់អ្នក និងការងារបម្រើព្រះរបស់អ្នកឬទេ? ________________
តើប៉ុលបានដោះស្រាយនឹងអ័លេក្សានត្រុសដោយរបៀបណា? ________________________________________

________________________________________________________________

១០. ស្ទើរគ្រប់គ្នាទៅហើយ ដែលបានបោះបង់ប៉ុលចោល (២ធីម៉ូថេ ១:១៥, ៤:១៦), ប៉ុន្តែតើអ្នកណាខ្លះ ដែលបានឈរជាមួយគាត់ យោងតាម ២ធីម៉ូថេ ៤:១៧-១៨? ________________________________________

________________________________________________________________

ហេតុអ្វី? ________________________________________________________
តើប៉ុលចង់ទទួលកិត្តិយស និងការយកចិត្តទុកដាក់ពីនរណា សម្រាប់ជីវិត និងការងាររបស់គាត់ (៤:១៨)? ____________

________________________________________________________________

***__ការអនុវត្តៈ__*** តើអ្នកមានលោក **បាណាបាស** នៅក្នុងជីវិតដែលឬទេ?______ ហេតុអ្វីបានជាអ្នកត្រូវការអ្នកលើកទឹកចិត្តនៅក្នុងជីវិតរបស់អ្នក (កិច្ចការ 4:៣៦; ៩:២៧)? ________________________________________

________________________________________________________________

________________________________________________________________

តើអ្នកមាន លោក **ប៉ុល** នៅក្នុងជីវិតឬទេ? _________ តើហេតុអ្វីបានអ្នកត្រូវការអ្នកដែលយល់ដឹងចាស់ទុំដូចជាប៉ុលនៅក្នុងជីវិតរបស់អ្នក? ________________________________________

________________________________________________________________

តើអ្នកមានលោក **ធីម៉ូថេ** នៅក្នុងជីវិតឬទេ? ________ ហេតុអ្វីបានជាអ្នកត្រូវសិស្ស ឬធីម៉ូថេ នៅក្នុងជីវិតរបស់អ្នក? _____

________________________________________________________________

________________________________________________________________

តើអ្នកមានលោក **ម៉ាកុស** នៅក្នុងជីវិតឬទេ? _______ តើអ្នកអាចទទួលបានម៉ាកុសដែលមានប្រយោជន៍ម្តងទៀតដោយរបៀបណា? ________________________________________

________________________________________________________________

________________________________________________________________

តើអ្នកធ្លាប់មានលោក **ដេម៉ាស** នៅក្នុងជីវិតឬទេ? ________ តើអ្នកអាចរៀនបានអ្វីខ្លះ ពីការដែលចាកចេញរបស់សិស្ស? _

________________________________________________________________

តើអ្នកធ្លាប់មានបទពិសោធន៍នឹងលោក **អ័លេក្សានត្រុស** នៅក្នុងជីវិតឬទេ? _____ តើអ្នកអានរៀនបានអ្វីខ្លះ ពីប៉ុលក្នុងការដោះស្រាយបញ្ហាជាមួយមនុស្ស ដែលចង់ធ្វើបាបអ្នក (២ធីម៉ូថេ ៤:១៤)? ____________________

________________________________________________________________

________________________________________________________________

បើទោះជាគ្រប់គ្នាបោះបង់អ្នកចោល តើនរណាដែលអ្នកអាចទុកចិត្តបាន និងតែងតែនៅខាងអ្នក ចាំជួយអ្នក និងនាំអ្នកត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព? ____________________________ សូមអាន ២ធីម៉ូថេ ៤:១៧-១៨ ម្តងហើយ ម្តងទៀត។

## IV. *ព្រះទ្រង់ប្រើអ្នកដឹកនាំដែលជាអ្នកបម្រើ*

ភាពជាអ្នកដឹកនាំដែលជាអ្នកបម្រើ គឺជាគំនិតបែបជាបរទេសនៅក្នុងពួកជំនុំបច្ចុប្បន្ន។ វាពិតជាគួរឲ្យចាប់អារម្មណ៍អំពីពួកជំនុំ ដែលជាកន្លែងយ៉ាងសុភាពរាបសារនៃគ្រប់ជំនឿ តែការទាំងនោះបានអន់ថយយ៉ាងច្រើន ដោយប្រែពីការស្រែកឃ្លាននូវចេស្ដានៃព្រះ បែរទៅជាពោពេញដោយការស្វែងរកតែប្រយោជន៍សម្រាប់ស្ថាប័នផ្ទាល់ខ្លួនកាន់តែធំទៅ និងប្រសើរឡើង។ ឥឡូវនេះយើងនឹងបានឮព្រះសូរសៀងនៃព្រះ និងរៀនសូត្រអំពីអត្ថន័យនៃពាក្យ ភាពជាអ្នកដឹកនាំតាមបទគម្ពីរ យ៉ាងពិតប្រាកដ។

១. តើគោលការណ៍សំខាន់អំពីអ្នកដឹកនាំដែលជាអ្នកបម្រើ ដែលយ៉ូហាន-បាទីស្ទបានបង្រៀនយើងនៅក្នុង យ៉ូហាន ៣:៣០ ជាអ្វី? ______________________________

បើអ្នកអនុវត្តការនេះនៅថ្ងៃនេះ តើវានឹងទៅជាយ៉ាងណានៅក្នុងជីវិតរបស់អ្នក និងការងារបម្រើ? ______________________________

______________________________

______________________________

______________________________

២. តើអ្នកអាចរៀនសូត្រពីព្រះយេស៊ូវអ្វីខ្លះ អំពីភាពជាអ្នកដឹកនាំដែលជាអ្នកបម្រើនៅក្នុងម៉ាថាយ ១១:២៨-៣០? __________

______________________________

______________________________

______________________________

៣. តើអ្នកណា ក្នុងចំណោមសិស្សរបស់ព្រះយេស៊ូវ ដែលជាសិស្សដំបូង ហើយអស្ចារ្យ យោងតាមម៉ាថាយ ២០:២៥-២៨; ម៉ាកុស ១០:៣៥-៤៥; លូកា ២២:២៤-២៧? ______________________________

______________________________

______________________________

______________________________

និង ហេតុអ្វីបានជាព្រះយេស៊ូវយាងមក (លូកា ២២:២៧)? ______________________________

៤. តើអ្នកណាដែលអស្ចារ្យជាងគេក្នុងចំណោមពួកគេ យោងតាមម៉ាថាយ ២៣:១១-១២? ______________________________

______________________________

______________________________

តើមានអ្វីកើតឡើងចំពោះអ្នកដឹកនាំណា ដែលលើកដំកើងខ្លួនឯង (២៣:១២)? ______________________________

______________________________

៥. បើសិនជាអ្នកណាដែលចង់ទៅជាទីមួយ តើគាត់ត្រូវតែធ្វើអ្វី យោងតាមម៉ាកុស ៩:៣៥-៣៧? ______________________________

______________________________

តើសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវជាអ្វី នៅពេលដែលអ្នកណាទទួលក្មេងនៅក្នុងឈ្មោះទ្រង់ (៩:៣៧)? ______________________________

______________________________

៦. យោងតាមយ៉ូហាន ១៣:១២-២០ ហេតុអ្វីបានជាព្រះយេស៊ូវលាងជើងឲ្យពួកសិស្ស? ______________________________

______________________________

តើអ្នកធ្លាប់មានបទពិសោធន៍ក្នុងពិធី "លាងជើង" ដែរឬទេ? ______ ហេតុអ្វីបានជាការនេះមិនសូវជាអនុវត្តទៅក្នុងពួកជំនុំសព្វថ្ងៃ? ______

៧. នៅក្នុង ១ថែស្សាឡូនីច ២:២-១២ បានរៀបរាប់ពី របៀបដែលប៉ុលបានរស់នៅក្នុងចំណោមពួកគេ? ______

______

៨. យោងតាម ១កូរិនថូស ១:២៦-២:៥ តើព្រះតែងហៅនរណា? ______

ហេតុអ្វី (១:២៩)? ______

តើប៉ុលបានសម្រេចចិត្តស្គាល់អ្វី (២:២)? ______

តើប៉ុលរស់នៅក្នុងចំណោមពួកគេដោយរបៀបណា (២:៣-៥)? ______

______

៩. យោងតាម ភីលីព ២:៣-១១ តើប៉ុលបានបង្ហាញអំពីភាពជាអ្នកដឹកនាំដែលជាអ្នកបម្រើដោយរបៀបណា? ______

______

តើប៉ុលមានគំនិតដូចនរណា (២:៥-១១)? ______

ចូរពិពណ៌នាអំពីគំនិតរបស់ព្រះគ្រីស្ទ ______

______

______

១០. តើព្រះទ្រង់តតាំងនឹងអ្នកណា យោងតាម ១ពេត្រុស ៥:៥-៧? ______

តែទ្រង់ផ្តល់ព្រះគុណដល់ (៥:៥)? ______

ដូច្នេះ តើយើងគួរតែឆ្លើយតបយ៉ាងដូចម្តេច (៥:៦-៧)? ______

______

______

**ការពិភាក្សា៖** តើនៅក្នុងស្ថានភាពមួយចំនួន ការដែលមានភាពសុភាពរាបសារនៃគ្រប់ជំនឿ បានធ្វើឲ្យអន់ថយដល់ការប្រែក្លាយដល់សព្វថ្ងៃនេះឬទេ? ______

______

______

**ការអនុវត្ត៖** តើសព្វថ្ងៃនេះ អ្នកអាចធ្វើការអ្វីបានខ្លះ ដើម្បីឲ្យនឹកឃើញឡើងវិញនូវភាពជាអ្នកដឹកនាំដែលជាអ្នកបម្រើ នៅក្នុងជីវិត និងពួកជំនុំរបស់អ្នក? ______

______

______

______

នៅទំព័របន្ទាប់ យើងទាំងអស់គ្នានឹងពិចារណាអំពីកត្តាទាំងបួន នៃការធ្លាក់ចុះនូវការដឹកនាំពួកជំនុំសព្វថ្ងៃ ដែលជាជាតុរួមផ្សំក្នុងការបង្អាក់ និងធ្វើឲ្យប្រែទៅជាខ្សោយក្នុងការពង្រីកនូវឥទ្ធិពលរបស់ខ្លួន។

**គម្រោង** E "អ៊ី"

# ភាពផ្ទុយគ្នារវាងការហ្វឹកហ្វឺនអ្នកដឹកនាំបច្ចុប្បន្ន និងពួកជំនុំមុនដំបូង

1. នៅក្នុងជំពូក១ យើងបានសរុបនូវការដែលព្រះបានប្រទានមកយើងរាល់គ្នានូវគ្រប់ការទាំងអស់ដែលយើងត្រូវការ ដើម្បីបង្កើតពួកជំនុំ និងអ្នកដឹកនាំដែលរឹងមាំឲ្យបានច្រើន។ ២ធីម៉ូថេ ៣:១៦-១៧ បានបញ្ជាក់ថា បទគម្ពីរដែលមួយគត់គឺគ្រប់គ្រាន់ និងអាចបំពេញគ្រប់គ្រាន់សម្រាប់បំពាក់អ្នកសំណព្វនៃព្រះ(១៧)។ តើការបរាជ័យរបស់ពួកជំនុំ ក្នុងការអនុវត្ត និងការទទួលស្គាល់ពីភាពគ្រប់គ្រាន់នៃបទគម្ពីរតែមួយគត់ បានរួមចំណែកក្នុងភាពទន់ខ្សោយនៃការដឹកនាំនៅក្នុងពួកជំនុំសព្វថ្ងៃបាន ដោយរបៀបណា? ______________________________

______________________________

______________________________

2. ពួកជំនុំជាច្រើនសព្វថ្ងៃ បានបរាជ័យក្នុងការទទួលស្គាល់គំនិតជាគ្រួសារ និងតួនាទីតាមបទគម្ពីររបស់ពួកគេ។ តើការអនុវត្តអាជីវកម្ម និងការរៀបចំរបស់ពួកជំនុំសព្វថ្ងៃបានរួមចំណែកក្នុងភាពទន់ខ្សោយនៃការដឹកនាំដោយរបៀបណា? ________

______________________________

______________________________

______________________________

3. ហេតុអ្វីបានជាការដឹកនាំដែលផ្អែកលើអប់រំដោយស្ថាប័ន និងការមានវោហារល្អច្រើនតែអាចទទួលយកបានក្នុងពួកជំនុំសព្វថ្ងៃ ជាងការដឹកនាំដែលពោរពេញដោយព្រះវិញ្ញាណ និងបែបជាអ្នកបម្រើព្រះនៅក្នុងពួកជំនុំសម័យដើមទៅវិញ?________

______________________________

______________________________

______________________________

4. តើយុទ្ធសាស្ត្ររបស់ព្រះយេស៊ូវ និងប៉ុលគឺដើម្បី <u>រារាំង</u> ឬ <u>ដោះលែង</u> ពួកសិស្ស?____________________

5. ពួកជំនុំជាច្រើនសព្វថ្ងៃនេះ ដែលសម្រេចចិត្តក្នុងរារាំងពួកសិស្ស ជួសឲ្យការដោះលែងពួកសិស្សដូចទៅនឹងព្រះយេស៊ូវ និងការដែលពួកសិស្សបានធ្វើនៅក្នុងពួកជំនុំអាន់ទីយ៉ូក។ ហេតុអ្វីបានជាអ្នកយល់ថាការរារាំងពួកសិស្សគឺត្រូវបានជ្រើសរើស និងទទួលយកសម្រាប់ពួកជំនុំសព្វថ្ងៃ? ______________________________

______________________________

______________________________

______________________________

**ចំណាំ៖** ពាក្យដែលគួរប្រយត្ន័៖ នៅពេលដែលអ្នកធ្វើការតាមបទគម្ពីរ ជាពិសេសការអភិវឌ្ឍន៍ការដឹកនាំបែបជាអ្នកបម្រើ ហើយការដោះលែងអ្នកដែលបានបង្ហាត់រួច អ្នកត្រូវតែរាវស់ស្ទង់ផលផ្លែតាមបទគម្ពីរដូចគ្នា។ អ្នកនឹងត្រូវខកចិត្ត ហើយអស់សង្ឃឹម បើអ្នកធ្វើការវាស់ស្ទង់ការអភិវឌ្ឍន៍ការដឹកនាំតាមបទគម្ពីរ ដោយតាមរយៈស្តង់ដាររបស់លោកីយនេះ។

*សូមលោកអ្នករំលឹកឡើងវិញពីជំពូកទី ១ ២ ៣ និង៤ និងបំពេញចន្លោះដែលមាននៅក្នុងរូបខាងក្រោមដោយមិនមើលមេរៀនខាងមុខ មុននឹងយើងទៅកាន់មេរៀនជំពូកទី៥៖ (បើអ្នកសរសេរមិនគ្រាន់ អាចសរសេរនៅកន្លែងផ្សេងបាន)។*



## ជំពូកទី ៥ ៖

## ការប្រឈមមុខរបស់យើង

# ការអភិវឌ្ឍន៍ពួកជំនុំរឹងមាំ

*ផែនការព្រះសម្រាប់ឲ្យពួកជំនុំរឹងមាំ*




សាវកប៉ុល គឺជាជាងសាងសង់ពួកជំនុំដ៏ចំណាន ជាអ្នកដែលសង់លើគ្រឹះដែលអ្នកដ៏ទៃបានសង់។ លោកមិនគ្រាន់តែព្រួយបារម្ភនឹងការចាប់ផ្ដើមឡើងនូវពួកជំនុំថ្មីនោះទេ តែលោកក៏ចង់ឲ្យពួកជំនុំដែលបានកើតហើយឲ្យរឹងមាំដូចគ្នា។ សូមមើលដំណើរបេសកកម្មរបស់ប៉ូលនៅក្នុង **ជំនួយបន្ថែម** ទំព័រ 189-223 អ្នកនឹងឃើញថា លោកបានធ្វើដំណើរទៅកាន់អ៊ីកូនាម លីស្ត្រា និងឌើបេជាច្រើនដង។ ដូចដែលយើងបានដឹងហើយថា លើកទីមួយលោកបានទៅដើម្បីផ្សាយដំណឹងល្អ ប៉ុន្តែហេតុអ្វីបានជាលោកត្រឡប់ទៅវិញម្ដងហើយម្ដងទៀតដូច្នេះ?

ត្រូវហើយ ប៉ុលបានត្រឡប់ទៅកាន់ទីក្រុងទាំងបីនេះច្រើនដងណាស់សរុបគឺ បួនដង។ នៅលើកទីមួយដែលលោកទៅធ្វើការផ្សាយដំណឹងល្អ និងបីលើកទៀតលោកទៅគឺ ដើម្បីពង្រឹក និងបង្កើតពួកសិស្ស និងពួកជំនុំឲ្យបានច្រើន។ ប៉ុលគឺព្រួយបារម្ភ

សម្រាប់ការពង្រឹកបណ្ដាពួកជំនុំក៏ជាតឹកតាងបញ្ជាក់ដោយលូកា និងប៉ុលបានប្រើពាក្យ *ចំរើនកម្លាំង ឬ តាំងមាំមួន* នៅក្នុងបទគម្ពីរខាងក្រោម៖

ដោយលូកា៖ កិច្ចការ ១៤:២១-២២, ១៥:៤១, ១៦:៥, ១៨:២៣

ដោយប៉ុល៖ រ៉ូម ១:១១-១២, ១៦:២៥-២៧, ១ថែស្សាឡូនីច ៣:១-៣, ២ថែស្សាឡូនីច ២:១៦-១៧

ពាក្យថា "*ចំរើនកម្លាំង*" *និង* "*តាំងមាំមួន*" គឺបានបកប្រែចេញពីភាសាក្រិច ដែលហៅថា ស្ដេរីហ្ស៊ូ "*stërizō*" និង អេពីស្ដេរីហ្ស៊ូ "*epistērizō*" ដែលមានន័យថា "ធ្វើឲ្យកាន់តែខ្លាំងឡើង ភ្ជាប់ឬចងភ្ជាប់នៅនឹងកន្លែង"។ ពាក្យទាំងនេះវាបានផ្ដល់នូវការយល់ដឹងយ៉ាងសំខាន់ទៅក្នុងបំណងចង់ឃើញរបស់ប៉ុលសម្រាប់ពួកជំនុំទើបបង្កើតថ្មីៗ។ លោកចង់ឲ្យពួកគេ "ភ្ជាប់" ឬ "ចងភ្ជាប់" នឹងសេចក្ដីបង្រៀនត្រឹមត្រូវ ជាមួយសេចក្ដីជំនឿរបស់ពួកគេ។ តាមអត្ថន័យពាក្យចំៗ គឺពាក្យនេះមានន័យថា "ការជួយទប់ ឬការភ្ជាប់អ្វីមួយ ដើម្បីឲ្យវាអាចឈរត្រង់បានដោយខ្លួនឯង ឬប្រែជាមិនអាចវង្វើបាន"។ ឧទាហរណ៍៖ អត្ថន័យពាក្យដើមឲ្យត្រូវន័យចំៗគឺ ពាក្យនេះបានប្រើប្រាស់សម្រាប់ពិពណ៌នាអំពីបង្គោលទប់ជួយដើមទំពាំងបាយជូ។ សូមមើលរូបនៅខាងក្រោម៖




ដូច្នេះហើយបានជាប៉ុលចង់ឲ្យពួកជំនុំដែលទើបតែបង្កើតថ្មីៗបាននឹងនរ និងអាចទ្រទ្រង់ដោយខ្លួនឯង ដោយមិនងាយនឹងរុះរើរ ឬវង្វើរដោយសារសេចក្ដីបង្រៀន ឬគោលលទ្ធិខុសឆ្គងនោះទេ។ ដើម្បីឲ្យការចម្រើនកម្លាំងដល់ពួកសិស្សថ្មីៗ សាវកប៉ុលមិនត្រឹមតែធ្វើដំណើរទៅសួរសុខទុក្ខពួកជំនុំទាំងនេះនោះទេ តែលោកក៏បានសេចក្ដីសំបុត្រទៅពួកគេផងដែរ។

យើងបានដឹងរួចមកហើយថា ប៉ុលគឺជាជាងសង់ពួកជំនុំដ៏ចំណាន ដូចនេះចូរយើងពិចារណាសំបុត្ររបស់គាត់ទៅនឹង "ឧបករណ៍ជាងធ្វើផ្ទះ" ដែលគេប្រើសម្រាប់ធ្វើការរកស៊ី មកនិយាយវិញម្ដង។ សម្រាប់មេជាងឈើ ឬមេជាងម៉ាស៊ីនត្រូវតែយល់ដឹងអំពីឧបករណ៍នីមួយៗដែលយកមកប្រើប្រាស់ទៅលើការងារនីមួយៗ ដូចទៅនឹងគ្រូនៃអ្នកបង្កើតពួកជំនុំផងដែរ គួរតែយល់ដឹងអំពីឧបករណ៍ណាដែលត្រូវប្រើប្រាស់ ដើម្បីឲ្យពួកជំនុំចម្រើន និងរឹងមាំឡើង។ សូមមើលឧបករណ៍នៅខាងក្រោម ហើយសូមកំណត់សម្គាល់ពីការប្រើប្រាស់របស់ឧបករណ៍នីមួយៗ៖




ទន្ទឹមនឹងការឧទាហរណ៍សាមាញ្ញនេះ វាក៏ជាការចាប់អារម្មណ៍មួយដែរ ដែលយើងមើលឃើញពីគ្រូគង្វាល អ្នកបម្រើការងារព្រះ និងគ្រូបង្រៀនមួយចំនួន ដែលកំពុងតែប្រើប្រាស់ញញួរដើម្បីនឹងអាដុំឈើ ឬប្រើរនារដើម្បីដំដែកគោល ឬម៉ាលេតមកបន្ធូរខ្ចៅទៅវិញ ។ល។ មិនខុសពីជាជាងឈើ និងជាងម៉ាស៊ីនប៉ុន្មានទេ ពួកគេក្លាយទៅជាចៅហ្វាយ ឬមេរបស់ជំនួយរបស់គេ ដូចទៅនឹងអ្នកដឹកនាំពួកជំនុំគួរតែប្រែក្លាយទៅជាអ្នកសង់ពួកជំនុំដ៏ចំណាន និងជាអ្នកតាំងឲ្យពួកគេមាំមួន ដោយប្រើឧបករណ៍របស់ព្រះ ជាព្រះបន្ទូលរបស់ទ្រង់។ ព្រះអាទិករបានប្រទានគ្រប់ឧបករណ៍មកយើងរាល់គ្នា ដែលត្រូវការដើម្បីប្រឈមមុខជាមួយនឹងបញ្ហា "ការសាងសង់ ឬជួសជុលគ្រឿងម៉ាស៊ីន" ណាមួយដែលនឹងកើតឡើងនៅក្នុងពួកជំនុំតាមរយៈព្រះបន្ទូលរបស់ទ្រង់ (ធីម៉ូថេ ទី២ ៣:១៦-១៧)។ ព្រះទ្រង់មានសេចក្ដីមេត្តាយ៉ាងច្រើនក្រៃលែង ដោយទ្រង់បានប្រទាននូវឧបករណ៍ដែលសំខាន់ៗ ដើម្បីឲ្យពួកជំនុំបានរឹងមាំឡើង។

ចាប់តាំងពេលដែលយើងយកឧបករណ៍ទាំងនេះជាតំណាងឲ្យសំបុត្ររបស់ប៉ុលទៅកាន់បណ្ដាពួកជំនុំ សូមមើលពីលំដាប់លំដោយនៅក្នុងព្រះគម្ពីរៈ






ឥឡូវនេះសូមយើងរៀបសំបុត្ររបស់ប៉ុលទៅតាមលំដាប់ពេលវេលា៖




ដូចដែរបានមើលឃើញហើយ នៅពេលយើងដាក់សំបុត្រនីមួយៗទៅតាមពេលវេលា យើងអាចធ្វើការបែងចែកជា ៣ផ្នែក ៖ សំបុត្រមុនរបស់ប៉ុល សំបុត្រកណ្ដាលរបស់ប៉ុល និងសំបុត្រចុងក្រោយរបស់ប៉ុល។ លំដាប់លំដោយនៃសម័យកាលនេះ បានផ្ដល់នូវការយល់ដឹងយ៉ាងធំធេងក្នុងយុទ្ធសាស្ត្ររបស់ប៉ុល ដែលបានប្រើដើម្បីបង្កើតពួកជំនុំថ្មីៗឲ្យរឹងមាំ។ ចំណាំ៖ អ្នកប្រាជ្ញព្រះគម្ពីរខ្លះបានអះអាងថា ថែស្សាឡូនីច ទី១ និងទី២ គឺត្រូវបានសរសេរមុនកណ្ឌគម្ពីរកាឡាទីទៅទៀត។

ជាឧទាហរណ៍ នៅក្នុងសំបុត្រមុនដំបូង ឬឧបករណ៍ដំបូងរបស់ប៉ុលគឺត្រូវបានសរសេរ ដើម្បីតាំងអ្នកជឿថ្មីៗឲ្យបានខ្ជាប់ខ្ជួននៅក្នុងដំណឹងល្អនៃព្រះគុណ។ នៅក្នុងការបែងចែកនូវលំដាប់លំដោយ និងការពិពណ៌នាអំពីសំបុត្រនីមួយៗតាមលំដាប់នៃសម័យកាល និងការសិក្សាពីព្រះ។ (ចំណាំ៖ នៅក្នុងឧបករណ៍ ឬសំបុត្ររបស់ប៉ុលនេះគឺជាព្រះវិញ្ញាណបណ្ដាលឲ្យសរសេរឡើងនូវចំនុចសំខាន់ ដែលពាក់ព័ន្ធនឹងបញ្ហាជីវិតជាក់ស្ដែងនៅក្នុងពួកជំនុំបង្កើតថ្មី និងពួកជំនុំដែលបានបង្កើតហើយ)

***<u>សំបុត្រមុនដំបូង</u>របស់លោកប៉ុល*** (ជាឧបករណ៍ត្រូវបានប្រើប្រាស់ដើម្បីការតាំងនៅនិងការពារដល់ដំណឹងល្អនៃព្រះគុណ)

- **<u>កាឡាទី</u>**៖ ការបែរត្រឡប់មករកព្រះវិញ្ញាណ សេចក្ដីជំនឿ និងដំណឹងល្អបរិសុទ្ធ
- **<u>១ថែស្សាឡូនីច និង២ថែស្សាឡូនី</u>**ច៖ ដំហររឹងមាំនៅក្នុងដំណឹងល្អ
- **<u>១កូរិនថូស</u>**៖ ការបែងចែក ត្រូវបានដោះស្រាយដោយជាប់ទាក់ទិនទៅនឹងដំណឹងល្អ
- **<u>២កូរិនថូស</u>**៖ ការពារដល់កិច្ចការបម្រើព្រះ និងអ្នកបម្រើការងារព្រះ
- **<u>រ៉ូម</u>**៖ ការប្រកាសប្រាប់ពីសេចក្ដីអធិប្បាយ និងការងាររបស់ដំណឹងល្អ

***<u>សំបុត្រកណ្ដាល</u>របស់លោកប៉ុល*** (ជាឧបករណ៍ត្រូវបានប្រើប្រាស់សម្រាប់ពួកជំនុំ ដើម្បីឲ្យមានគោលបំណងតែមួយនៅក្នុងផែនការរបស់ព្រះ)

- **<u>អេភេសូ</u>**៖ ការកាន់ខ្ជាប់នូវអាថ៌កំបាំងរបស់ពួកជំនុំ និងការសម្ដែងចេញនៃផែនការរបស់ព្រះគ្រីស្ទ
- **<u>ភីលីព</u>**៖ ការធ្វើឲ្យមានគំនិតតែមួយនៅក្នុងពួកជំនុំ និងការចូលរួមក្នុងដំណើរនៃដំណឹងល្អ

- **កូល៉ុស**៖ ការរក្សាការផ្ដោតសម្លឹងមើលទៅសិរសារបស់ពួកជំនុំ
- **ភីលេម៉ូន**៖ ទំនាក់ទំនង និងការជាប់ជំពាក់នូវគំនិតតែមួយនៅក្នុងដំណើរនៃដំណឹងល្អ

***សំបុត្រចុងក្រោយ*** ***របស់លោកប៉ុល*** (ជាឧបករណ៍ត្រូវបានប្រើប្រាស់ធ្វើឲ្យមានសណ្ដាប់ធ្នាប់ល្អត្រឹមត្រូវដល់គ្រួសារព្រះ)

- **១ធីម៉ូថេ**៖ ការរៀបចំសណ្ដាប់ធ្នាប់ឲ្យបានល្អត្រឹមត្រូវដល់ជីវិតសហគមន៍គ្រួសារព្រះ និងពួកជំនុំរបស់ទ្រង់
- **ទីតុស**៖ ការកំណត់ទុកនៅក្នុងសណ្ដាប់ធ្នាប់ ដែលនៅសេសសល់ក្នុងពួកជំនុំ ដោយការតាំងពួកជំនុំឡើងតាមសេចក្ដីបង្រៀនត្រឹមត្រូវ
- **២ធីម៉ូថេ**៖ ការផ្ទេរដំបងដល់អ្នកដែលបានហ្វឹកហ្វឺនបានល្អ និងអ្នកដឹកនាំដ៏ស្មោះត្រង់សម្រាប់ជំនាន់ក្រោយ

ឥឡូវនេះលោកអ្នកមិនចាំបាច់មើលក្រោយទេ ពិសោធន៍មើលថាតើអ្នកបំពេញចន្លោះតាមលំដាប់លំដោយនៃសំបុត្រទាំង ១៣ របស់ប៉ុល នៅក្នុងតារាងលំដាប់ពេលវេលានៅខាងក្រោមនេះ៖




**លំដាប់សម័យកាលនៃសំបុត្ររបស់ប៉ុល**

លោកអ្នកអាចរៀបរាប់អំពីសំបុត្ររបស់ប៉ុលដោយលំដាប់ដូចនឹងសង់ប្លុកឡើង ដែលជាការដាក់នូវពេលវេលាសម្រាប់ជាមូលដ្ឋានគ្រឹះនៃគ្រួសាររបស់ព្រះ។ សូមមើលរូបភាពខាងក្រោម៖



មេរៀនទី ១២

# ចំរើនកំលាំង ឬការតាំងមាំមួនដល់ពួកជំនុំ ៖ សាំបុត្រប៉ុល

សាវកប៉ុល គឺជាជាងសាងសង់ពួកជំនុំដ៏ចំណានម្នាក់ ជាអ្នកដែលសង់លើគ្រឹះដែលអ្នកដ៏ទៃបានសង់។ លោកមិនគ្រាន់តែព្រួយបារម្ភនឹងការចាប់ផ្តើមឡើងនូវពួកជំនុំថ្មីនោះទេ តែលោកក៏ចង់ឲ្យពួកជំនុំដែលបានកើតហើយឲ្យរឹងមាំ និងតាំងមាំមួនដូចគ្នា។ ជាការសបញ្ជាក់ឲ្យយើងបានឃើញពីការប្រើប្រាស់ពាក្យ "ចំរើនកម្លាំង ឬការតាំងមាំមួន" ក្នុងព្រះបន្ទូលនៃព្រះ។




<u>**ការសង្កេត៖**</u> សូមអ្នកអាន និងសង្កេតពីខគម្ពីរខាងក្រោម រួចធ្វើការសរសេរពីអ្វីដែលអ្នកបានរៀនសូត្រអំពីការចំរើនកម្លាំង និងការតាំងមាំមួនដល់ពួកសិស្ស និងបណ្តាពួកជំនុំចេញពីព្រះបន្ទូលនៃព្រះ។

លូកា ២២:៣២ ____________________________________________

____________________________________________

១ពេត្រុស ១:២២-២៥, ២ពេត្រុស ១:១២ ____________________________________________

____________________________________________

____________________________________________

កិច្ចការ ១៤:២១-២៣ ____________________________________________

____________________________________________

____________________________________________

កិច្ចការ ១៥:៣៦-១៦:៥ ____________________________________________

កិច្ចការ ១៨:២២-២៣ ____________________________________________

____________________________________________

រ៉ូម ១:៨-១២ ____________________________________________

____________________________________________

រ៉ូម ១៦:២៥-២៧ ____________________________________________

____________________________________________

១ថែស្សាឡូនីច ៣:១-៣ ____________________________________________

____________________________________________

១ថែស្សាឡូនីច ៤:១២ ____________________________________________

____________________________________________

២ថែស្សាឡូនីច ២:១៦-១៧ ____________________________________________

____________________________________________

២ថែស្សាឡូនីច ៣:៣ ____________________________________________

____________________________________________

វិវរណៈ ៣:១-២ ____________________________________________

____________________________________________

**<u>ការថ្លឹងគិត៖</u>** ផ្អែកតាមខគម្ពីរខាងលើ ចូរអ្នកសរសេរពីគោលការណ៍ និងមុខងារសំខាន់ៗ ដែលអ្នកបានសង្កេតពីព្រះបន្ទូលព្រះដែលអាចឲ្យមនុស្សម្នាក់ៗ គ្រួសារ និងពួកជំនុំអនុវត្តតាមនៅគ្រប់ពេលវេលា និងវប្បធម៌នៃការរស់នៅ។ (កត្តាដាច់ខាត)_

____________________________________________

____________________________________________

____________________________________________

**<u>ការពិភាក្សា</u>** ៖ ចូរអ្នករៀបរាប់ពីភាពផ្ទុយគ្នានៃគោលការណ៍ខាងលើទៅនឹងបទពិសោធន៍ក្នុងជីវិតរបស់អ្នក គ្រួសារអ្នក និងពួកជំនុំអ្នកបច្ចុប្បន្ន។____________________________________________

____________________________________________

____________________________________________

តើអ្នកត្រូវការការផ្លាស់ប្រែយ៉ាងដូចម្តេចខ្លះ នៅក្នុងជីវិតរបស់អ្នក គ្រួសារអ្នក និងពួកជំនុំអ្នក និងក្នុងពេលឥឡូវនេះ?

____________________________________________

____________________________________________

____________________________________________

**<u>ការអនុវត្ត៖</u>** តើអ្នកនឹងធ្វើការផ្លាស់ប្រែការទាំងនេះដោយរបៀបណា និងនៅពេលណានៅក្នុងជីវិត គ្រួសារ និងពួកជំនុំ?_____

____________________________________________

____________________________________________

____________________________________________

**មេរៀនទី ១៣**

# ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង - ៤៨-៥៧ គ.ស

*កាឡាទី* គឺជាសំបុត្រទីមួយក្នុងចំណោមសំបុត្រដំបូងរបស់ប៉ុល បានសរសេរដើម្បីតាំងពួកអ្នកជឿឲ្យមាំមួនឡើងនៅក្នុងដំណឹងល្អនៃព្រះគុណ។ នៅក្នុងសំបុត្រនេះបង្រៀនអំពីអស់អ្នកជឿគឺនឹងបានសេរីភាព និងបានរាប់ជាបរិសុទ្ធដោយការជឿតែមួយប៉ុណ្ណោះ។ វាបង្ហាញពីការពេញនិយមក្នុងផ្លាស់ប្តូរព្រះវិញ្ញាណនៅក្នុងពួកជំនុំសព្វថ្ងៃ ជំនួយដោយសាច់ឈាមវិញ។




**<u>ការពិភាក្សា និងការជញ្ជឹងគិត៖</u>** ចូរអ្នកអានសំណួរ និងបទគម្ពីរខាងក្រោម ហើយសូមអ្នកធ្វើការសង្ខេបពីអ្វីដែលអ្នកបានរៀន។

តើដំណឹងបរិសុទ្ធនៃព្រះគុណជាអ្វី? សូមអាន កាឡាទី ១:១-២៤ និងសង្ខេបចម្លើយរបស់អ្នក៖

តើរវាងដំណឹងល្អបរិសុទ្ធនៃព្រះគុណ និងក្រឹត្យវិន័យខុសគ្នាយ៉ាងដូចម្តេច? សូមអាន កាឡាទី ២:១-២១ និងសង្ខេបចម្លើយរបស់អ្នក៖

តើមនុស្សម្នាក់រាប់ជាសុចរិត ឬរាប់ជាបរិសុទ្ធនៅចំពោះព្រះដោយរបៀបណា? សូមអាន កាឡាទី ៣:១-២៩ និងសង្ខេបចម្លើយរបស់អ្នក៖

តើសាវកប៉ុលបានបញ្ជាក់ថា ការសង្គ្រោះគឺដោយដំណឹងល្អបរិសុទ្ធនៃព្រះគុណ មិនមែនដោយក្រឹត្យវិន័យដោយរបៀបណា? សូមអាន កាឡាទី ៤:១-៣១ និងសង្ខេបចម្លើយរបស់អ្នក៖

តើការដើរក្នុងព្រះវិញ្ញាណ និងការដើរក្នុងសាច់ឈាមខុសគ្នាយ៉ាងដូចម្ដេច? សូមអាន កាឡាទី ៥:១-២៦ និងសង្ខេបចម្លើយរបស់អ្នក៖

តើដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធមិនមែនជាការនាំសិរីល្អដល់មនុស្ស ឬខ្លួនឯង តែជាការនាំសិរីល្អថ្វាយព្រះ ដោយរបៀបណា? សូមអាន កាឡាទី ៦:១-១៨ និងសង្ខេបចម្លើយរបស់អ្នក៖

**<u>ការពិភាក្សា៖</u>** ចូរអ្នកធ្វើពីភាពផ្ទុយនៃដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធជាមួយនឹងក្រឹត្យវិន័យ។ ចូរធ្វើការប្រៀបធៀបដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធក្នុងកណ្ឌគម្ពីរកាឡាទី ជាមួយជីវិតអ្នក ក្រុមគ្រួសារអ្នក និងពួកជំនុំអ្នក។

តើអ្នកត្រូវការ ការផ្លាស់ប្រែអ្វីខ្លះ នៅក្នុងជីវិតអ្នក គ្រួសារ និងពួកជំនុំអ្នកដើម្បីបានការតាំងឡើងមាំមួនកាន់តែល្អនៅក្នុងដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ?

**<u>ការអនុវត្ត៖</u>** តើអ្នកនឹងធ្វើការផ្លាស់ប្រែការទាំងនេះដោយរបៀបណា និងនៅពេលណានៅក្នុងជីវិត គ្រួសារ និងពួកជំនុំ?

មេរៀនទី ១៤

# ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង - ៤៨-៥៧ គ.ស

*១ និង ២ ថែស្សាឡូនីច* គឺជាសំបុត្រទីពីរ និងទីបី ក្នុងចំណោមសំបុត្រដំបូងរបស់ប៉ុល ដែលបានសរសេរដើម្បីតាំងពួកអ្នកជឿឲ្យមាំមួនឡើងនៅក្នុងដំណឹងល្អនៃព្រះគុណ។ សំបុត្រទាំងពីរនេះបានលើកទឹកចិត្តពួកអ្នកជឿថ្មីឲ្យតស៊ូ និងលូតលាស់ក្នុងសេចក្តីជំនឿថ្មីរបស់ពួកគេ ហើយនិងរស់នៅបែបសមគួរទោះបីពួកគេត្រូវជួបការបៀតបៀន និងទុក្ខវេទនាក៏ដោយ។




**<u>ការពិភាក្សា និងការពិញ្ញក់គិត៖</u>** ចូរអ្នកអានសំណួរ និងបទគម្ពីរខាងក្រោម ហើយសូមអ្នកធ្វើការសង្ខេបពីអ្វីដែលអ្នកបានរៀន។

តើលទ្ធផលនៃដំណឹងល្អបរិសុទ្ធនៃព្រះគុណអ្វីខ្លះ ដែលបានមកពីពួកជំនុំថែស្សាឡូនីច? សូមអាន ១ថែស្សាឡូនីច ១:១-១០ និងសង្ខេបចម្លើយរបស់អ្នក៖ ________________________________

____________________________________________

____________________________________________

____________________________________________

តើសាវកប៉ុលបម្រើដល់ដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធដល់ពួកជំនុំថែស្សាឡូនីច ដោយរបៀបណា? សូមអាន ១ថែស្សាឡូនីច ២:១-៣:១៣ និងសង្ខេបចម្លើយរបស់អ្នក៖ ________________________________

____________________________________________

____________________________________________

____________________________________________

តើអ្វីជាទំនួលខុសត្រូវរបស់អ្នកក្នុងការទទួលបានដំណឹងល្អបរិសុទ្ធនៃព្រះគុណ? សូមអាន ១ថែស្សាឡូនីច ៤:១-៥:២៨ និងសង្ខេបចម្លើយរបស់អ្នក៖ ________________________________

____________________________________________

____________________________________________

____________________________________________

តើដំណឹងល្អបរិសុទ្ធនៃព្រះគុណជួយអ្នកឲ្យឈរយ៉ាងរឹងមាំក្នុងការស៊ូទ្រាំនឹងការរងទុក្ខ និងប្រឈមមុខនឹងការជំនុំជំរះដោយរបៀបណា? សូមអាន ២ថែស្សាឡូនីច ១:១-១២ និងសង្ខេបចម្លើយរបស់អ្នក៖ ____________________

តើដំណឹងល្អបរិសុទ្ធនៃព្រះគុណជួយអ្នកឲ្យឈរយ៉ាងរឹងមាំ នៅពេលថ្ងៃនៃព្រះអម្ចាស់ ក៏ជាថ្ងៃដែលមនុស្សគ្មានច្បាប់ត្រូវបានបើកសម្តែង ដោយរបៀបណា ? សូមអាន ២ថែស្សាឡូនីច ២:១-១៧ និងសង្ខេបចម្លើយរបស់អ្នក៖ ____________________

តើទិដ្ឋភាពជាក់ស្តែងអ្វីខ្លះ នៃដំណឹងល្អបរិសុទ្ធនៃព្រះគុណ? សូមអាន ២ថែស្សាឡូនីច ៣:១៨ និងសង្ខេបចម្លើយរបស់អ្នក៖_

**ការពិភាក្សា៖** តើមានឥទ្ធិពល និងទំនួលខុសត្រូវអ្វីខ្លះ នៃដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ? ប្រៀបធៀបដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ ដូចដែលបានឃើញនៅក្នុងថែស្សាឡូនីច ជាមួយនឹងជីវិតរបស់អ្នក ក្រុមគ្រួសារ និងពួកជំនុំរបស់អ្នក។____________

តើអ្នកត្រូវធ្វើការផ្លាស់ប្តូរអ្វីខ្លះក្នុងជីវិត គ្រួសារ និងពួកជំនុំរបស់អ្នក ដើម្បីត្រូវបានការតាំងឡើងមាំមួនកាន់តែល្អនៅក្នុងដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ?____________________

**ការអនុវត្ត៖** តើអ្នកនឹងធ្វើការផ្លាស់ប្រែការទាំងនេះដោយរបៀបណា និងនៅពេលណានៅក្នុងជីវិត គ្រួសារ និងពួកជំនុំ?

**មេរៀនទី ១៥**

# ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង - ៤៨-៥៧ គ.ស

***កូរិនថូស ទី១*** គឺជាសំបុត្រទីបួន ក្នុងចំណោមសំបុត្រដំបូងរបស់ប៉ុល ដែលបានសរសេរដើម្បីតាំងពួកអ្នកជឿឲ្យមាំមួនឡើងនៅក្នុងដំណឹងល្អនៃព្រះគុណ។ សំបុត្រនេះត្រូវបានសរសេរឡើងដើម្បីបង្រួបបង្រួម និងញែកពួកជំនុំថ្មីនេះឱ្យបរិសុទ្ធ ដោយជួយពួកគេឱ្យយល់អំពីអត្ថន័យនៃដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ និងដើម្បីអនុវត្តតួនាទីរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។




**<u>ការពិភាក្សា និងការថ្លឹងគិត៖</u>** ចូរអ្នកអានសំណួរ និងបទគម្ពីរខាងក្រោម ហើយសូមអ្នកធ្វើការសង្ខេបពីអ្វីដែលអ្នកបានរៀន។

តើឥទ្ធិពលនៃដំណឹងល្អនៃព្រះគុណបរិសុទ្ធ អាចរារាំងការបែកបាក់គ្នាក្នុងពួកជំនុំ ដោយរបៀបណា? សូមអាន ១កូរិនថូស ១:១-២១ និងសង្ខេបចម្លើយរបស់អ្នក៖ ______________________________

______________________________

______________________________

តើអត្ថន័យនៃដំណឹងល្អនៃព្រះគុណបរិសុទ្ធអាចកែកំហុសខាងសីលធម៌ក្នុងពួកជំនុំ ដោយរបៀបណា? សូមអាន ១កូរិនថូស ៥:១-៦:២០ និងសង្ខេបចម្លើយរបស់អ្នក៖ ______________________________

______________________________

______________________________

តើអ្វីទៅជាអត្ថន័យនៃដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ ទាក់ទងនឹងការឈរយ៉ាងរឹងមាំក្នុង៖ **<u>អាពាហ៍ពិពាហ៍</u>** (សូមអាន ១កូរិនថូស ៧:១-៤០ និងមេរៀនទី២៩)៖ ______________________________

______________________________

______________________________

**<u>រូបព្រះ</u>** (សូមអាន ១កូរិនថូស ៨:១-១១:១)៖ ______________________________

______________________________

______________________________

**ការជួបប្រជុំ** (សូមអាន ១កូរិនថូស ១១:២-៣៤)៖ ______

______

______

**អំណោយទានខាងវិញ្ញាណ** (សូមអាន ១កូរិនថូស ១២:១-១៤:៤០)៖ ______

______

______

**ការស្លាប់ និងការរស់ឡើងវិញ** (សូមអាន ១កូរិនថូស ១៥:១-៥៨)៖ ______

______

______

**ការរៃប្រាក់** (សូមអាន ១កូរិនថូស ១៦:១-២៤)៖ ______

______

______

**ចំណាំ៖** សូមមើលជំនួយបន្ថែមអំពី **ការផ្តល់ឲ្យ និងបញ្ហាប្រាក់កាក់** ទំព័រ ០០០។

**ការពិភាក្សា៖** តើដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធជួយទប់ស្កាត់ការបែកបាក់គ្នា និងកែបញ្ហាខាងសីលធម៌ និងបញ្ហាការប្រជុំដោយរបៀបណា? ប្រៀបធៀបដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ ដូចដែលបានឃើញនៅក្នុងកូរិនថូសទី១ ជាមួយនឹងជីវិតរបស់អ្នក ក្រុមគ្រួសារ និងពួកជំនុំរបស់អ្នក។ ______

______

______

______

តើអ្នកត្រូវធ្វើការផ្លាស់ប្តូរអ្វីខ្លះក្នុងជីវិត គ្រួសារ និងពួកជំនុំរបស់អ្នក ដើម្បីជួយពួកគេតាំងនៅយ៉ាងរឹងមាំនៅក្នុងដំណឹងល្អនៃព្រះគុណដ៏បរិសុទ្ធ ?______

______

______

______

**ការអនុវត្ត៖** តើអ្នកនឹងធ្វើការផ្លាស់ប្រែការទាំងនេះដោយរបៀបណា និងនៅពេលណានៅក្នុងជីវិត គ្រួសារ និងពួកជំនុំ?

______

______

______

______

______

## មេរៀនទី ១៦

# ការតាំងពួកជំនុំឡើង ៖ សំបុត្រប៉ុលមុនដំបូង - ៤៨-៥៧ គ.ស

*កូរិនថូស ទី២* គឺជាសំបុត្រទីប្រាំ ក្នុងចំណោមសំបុត្រដំបូងរបស់ប៉ុល ដែលបានសរសេរដើម្បីតាំងពួកអ្នកជឿឲ្យមាំមួនឡើងនៅក្នុងដំណឹងល្អនៃព្រះគុណ។ គ្រូក្លែងក្លាយបានបែងចែកពួកជំនុំថ្មី ដោយបង្ខូចកិត្តិយសប៉ុល និងការនាំសារជាព្រះបន្ទូលព្រះរបស់គាត់។ សំបុត្រនេះត្រូវបានសរសេរដើម្បីផ្ទៀងផ្ទាត់សាររបស់គាត់ និងដើម្បីការពារភាពជាសាវ័ករបស់គាត់។




**<u>ការពិភាក្សា និងការឆ្លុះគិត៖</u>** ចូរអ្នកអានសំណួរ និងបទគម្ពីរខាងក្រោម ហើយសូមអ្នកធ្វើការសង្ខេបពីអ្វីដែលអ្នកបានរៀន។

តើអ្នកបម្រើនៃដំណឹងល្អនៃព្រះគុណបរិសុទ្ធការពារ ការប្រព្រឹត្តរបស់គាត់យ៉ាងដូចម្ដេច? សូមអាន ២កូរិនថូស ១:១-២:១១ និងសង្ខេបចម្លើយរបស់អ្នក៖ ____________________

____________________

____________________

____________________

តើអ្នកបម្រើនៃដំណឹងល្អនៃព្រះគុណបរិសុទ្ធការពារ ការងារបម្រើរបស់គាត់យ៉ាងដូចម្ដេច? សូមអាន ២កូរិនថូស ២:១២-៧:១៦ និងសង្ខេបចម្លើយរបស់អ្នក៖ ____________________

____________________

____________________

____________________

តើអ្នកបម្រើនៃដំណឹងល្អនៃព្រះគុណបរិសុទ្ធការពារ ការដាក់ ឬផ្ដល់តង្វាយរបស់គាត់យ៉ាងដូចម្ដេច? សូមអាន ២កូរិនថូស ៨:១-៩:១៥ និងសង្ខេបចម្លើយរបស់អ្នក៖

